ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance



ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jul-2012, 13:28
CMS/CFO: Uch Arun


# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៨៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វ៉ីស៊ែល រីស៊ើ

*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់

*(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក វ៉ាចាម តុន (TCW-564) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក វ៉ែចាម តុន ហៅ គី តួន** (TCW-564)
សួរបន្តដោយលោក សេង ប៊ុនឃាង ផ្ដើមពី៖ ..................................................................ទំព័រ ២
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី៖ ..........................................................................ទំព័រ១៥

# កិច្ចដំណើរការនីតិវិធី

[០៩:០១:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញចូលរួមនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធានគ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិ តាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេញមួយថ្ងៃ នៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណ។

[០៩:០២:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។ វេជ្ជបណ្ឌិត ស្ទួស សែម ដែលទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យឃើញថាលោក អៀង សារី មានអាការៈវិលមុខ និងហត់ខ្លាំងនៅពេលធ្វើចលនា និងបានផ្តល់អនុសាសន៍ថាលោក អៀង សារី គួរតែត្រូវបានអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយនៅក្រោមសាលសវនាការនេះ។

[០៩:០៣:៣៨]

អង្គជំនុំជម្រះយល់ឃើញថានាពេលនេះ ជនជាប់ចោទ អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងមេធាវីរបស់គាត់បានដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[០៩:០៥:៤២]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូង -- ជាបឋម ខ្ញុំសូមគោរពលោកប្រធាន លោកលោះស្រីចៅក្រម និងអរុណសួស្តីភាគីទាំងអស់ ដែលមានវត្តមាននៅទីនេះ ហើយនិងលោកសាក្សីផងដែរ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី កាលពីម្សិលមិញយើងបានបញ្ចប់ត្រឹម ដែលលោកឆ្លើយថា អំឡុងពេលនៅមន្ទីរស-២១ (ស៊ីក) ហ្នឹងគឺ ប៉ុល ពត គាត់បានធ្វើដំណើរតាមមូលដ្ឋាន ហើយគាត់ក៏បានទៅបង្រៀនឬក៏ឧទ្ទេសនាមនៅតាមកន្លែងនីមួយៗ ដែលគាត់បានទៅដល់។ អ៊ីចឹង ចង់ដឹងថា តើ ប៉ុល ពត គាត់ធ្លាប់ដែលចេញទៅខាងសមរភូមិដែរទេ?

**លោក វ៉ាចាម តុន៖**

**ឆ៖** គាត់ធ្លាប់ទៅតាមសមរភូមិដែរ កន្លែង ដូចជា កន្លែង សុន សេន កន្លែង កុយ ធួន កន្លែង

តាម៉ុក កន្លែង វន វ៉េត។

**ស៖** បាទ អរគុណ។

**លោក សុន អរុណ៖**

សូមៗលោកប្រធាន សូមជូនយោបល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក សុន អរុណ៖**

ខ្ញុំមិនមែនជំទាស់ទេ ប៉ុន្តែសូមជូនយោបល់។ សូមបញ្ជាក់សមរភូមិហ្នឹង មានន័យថាយ៉ាងម៉េច? សមរភូមិកន្លែងច្បាំងគ្នា សមរភូមិយ៉ាងម៉េច? សូមលោកព្រះរាជអាជ្ញាបញ្ជាក់ឲ្យច្បាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:០៦:៤១]

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន។ ហើយធម្មតាពាក្យថា សមរភូមិជាកន្លែងសមរភូមិប្រយុទ្ធគ្នា ប៉ុន្តែសំណួរនេះ គឺតំណាងសហព្រះរាជអាជ្ញានឹងមិនទាន់សួរដល់សំណួរនេះទេ ប៉ុន្តែដោយសារលោកមេធាវីគាត់ចង់ដឹង។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អ៊ីចឹងសូមសួរលោកសាក្សីតែម្តងទៅថា តើសមរភូមិដូចដែលលោកមេធាវីការពារហ្នឹងចង់ដឹងនោះ តើជាសមរភូមិនោះមានន័យថាយ៉ាងម៉េចដែរ?

**លោក រ៉ចាម តុន៖**

**ឆ៖** សមរភូមិនេះ គឺកន្លែងដែល គឺកន្លែងហ្វឹកហ្វឺនយោធា ដែលប្រយុទ្ធផ្ទាល់នៅសមរភូមិ ដូចកុយ ធួន គឺថាសមរភូមិកំពង់ធំ, វន វ៉េត គឺសមរភូមិ នៅភូមិភាគពិសេស។

**ស៖** បាទ អរគុណ។ ចុះ សុន សេន និង តាម៉ុក នៅទីណាដែរ?

**ឆ៖** សុន សេន គឺថានៅសមរភូមិកំពង់ធំដែរ គឺថា សុន សេន របស់មជ្ឈិម, ហើយ កុយ ធួន របស់ភូមិភាគ, ហើយនិង វន វ៉េត នៅភូមិភាគពិសេស, តាម៉ុក នៅភូមិភាគនិរតី។

**ស៖** បាទ អរគុណ។ ចុះលោកមានដឹងដែរទេថា ប៉ុល ពត ដែលទៅសមរភូមិជួបអ្នកទាំងនេះហ្នឹងគាត់ឧស្សាហ៍ទៅដែរទេ?

**ឆ៖** គាត់ឧស្សាហ៍ទៅដែរ គឺថាដើម្បីលើកទឹកចិត្តដល់អ្នកដែលប្រចាំនៅសមរភូមិផ្ទាល់។

**ស៖** បាទ អរគុណ។ ខ្ញុំវិលមកកន្លែងមន្ទីរស-២១ (ស៊ីក) ឡើងវិញ។ តើលោកអាចបញ្ជាក់បានទេថា នៅមន្ទីរស-២១ហ្នឹង មានថ្នាក់ដឹកនាំបក្សណាខ្លះ ដែលរស់នៅទីនោះ?

**ឆ៖** អ្នកដឹកនាំនៅស--

**ស៖** សូមៗកាត់លោកបន្តិច ប្រហែលជាមានការភ័ន្តច្រឡំ។ ខ្ញុំថា នៅមន្ទីរស-៧១ បាទ។

[០៩:១០:១៥]

**ឆ៖** នៅមន្ទីរ ស-៧១ ហ្នឹង គឺថាមានលោក អ៊ំ ប៉ុល ពត, លោកអ៊ំ នួន ជា ហើយនិងលោក អ៊ំ ខៀវ សំផន។ ហើយជាអចិន្ត្រៃយ៍គឺថា គាត់នៅជាអចិន្ត្រៃយ៍ប្រចាំថ្ងៃ គឺនៅបីនាក់ហ្នឹង។

**ស៖** បាទ អរគុណ។ ចុះលោកដឹងទេ ថាទាក់ទងទៅនឹងការធ្វើដំណើររបស់ ប៉ុល ពត ដែលគាត់ម្ដងទៅនេះ ម្ដងទៅនោះ ចោលកន្លែងធ្វើការអ៊ីចឹង។ តើមាននរណាជាអ្នកទទួលបន្ទុកជំនួសគាត់ដែរទេ នៅពេលដែលគាត់អត់នៅកន្លែងអ៊ីចឹង?

**ឆ៖** ពេលដែលគាត់ លោកអ៊ំ ប៉ុល ពត មិននៅ លោកអ៊ំ នួន ជា នៅប្រចាំនៅកន្លែង ហើយនិងលោកអ៊ំ ខៀវ សំផន នៅចាំកន្លែងដែរ។

**ស៖** បាទ អរគុណ។ កាលពីម្សិលមិញ លោកក៏បានជម្រាបជូនអង្គសវនាការផងដែរ ថាលោកធ្វើជាអ្នករត់សំបុត្រឲ្យ ប៉ុល ពត នៅពេលដែលនៅមន្ទីរស-២១ ហ្នឹង -- អ៎! ស-៧១ ហ្នឹង។ តើអំឡុងពេលនេះដែរ តើមានពេលណាខ្លះដែរទេ ដែលលោកធ្វើជានីរសារ ឬក៏ជាអ្នករត់សំបុត្រឲ្យថ្នាក់ដឹកនាំបក្សផ្សេងៗទៀត ដូចជាលោក នួន ជា អីជាដើមហ្នឹង?

[០៩:១២:០៤]

**ឆ៖** បើគាត់ នែ៎ នៅជុំគ្នា អត់មានរត់ទេ។ គាត់នៅជុំគ្នាហើយ អត់មានអីទេ។ ប៉ុន្តែបើលោកអ៊ំ នួន ជា នៅប្រចាំកន្លែង បានលោកអ៊ំ ប៉ុល ពត នៅសមរភូមិមុខ អាហ្នឹងគឺខ្ញុំមាននាំសារអ៊ីចឹង។ ពីអ៊ំ ប៉ុល ពត ទៅអ៊ំ នួន ជា។ ពីអ៊ំ នួន ជា ទៅអ៊ំ ប៉ុល ពត។ គឺមានអ៊ីចឹង។

**ស៖** បាទ អរគុណ។ ចុះលោកដឹងដែរទេ ថាលោក នួន ជា ហ្នឹង គាត់ធ្លាប់ធ្វើដំណើរទៅកន្លែងផ្សេងៗ នៅក្នុងប្រទេសកម្ពុជា ដូច ប៉ុល ពត អ៊ីចឹងដែរទេ?

**ឆ៖** ពីរនាក់ហ្នឹង ប្រហែលគ្នាៗ បាទ។

**ស៖** ចុះនៅពេលដែលលោក នួន ជា គាត់ចេញដំណើរទៅតាមកន្លែងផ្សេងៗ ម្ដងៗ តើគាត់ទៅត្រង់ ទៅកន្លែងនោះតែម្ដង ឬក៏គាត់ឈាងចូលកន្លែងណា ដើម្បីធ្វើការជាមុនសិន?

**ឆ៖** ត្រង់ចំណុចហ្នឹង គឺថាពេលខ្លះគាត់ទៅត្រង់។ ប៉ុន្តែពេលខ្លះទៀត ក៏មានចូលកន្លែងដែលត្រូវឆ្លងកាត់ គាត់មានចូលខ្លះដែរ។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំទេ ថាកន្លែងដែលគាត់ចូលខ្លះដែរហ្នឹង កន្លែងណាខ្លះ?

**ឆ៖** ឧទាហរណ៍ ដូចជាគាត់ចេញពី ស-៧១ ហ្នឹង មកកន្លែងភូមិភាគ៣០៤ ហ្នឹង គឺចន្លោះហ្នឹង គឺថាមានដំណាក់នីរសារមួយកន្លែងអីចឹង ទៅចូលនោះ។

**ស៖** ចុះលោក នួន ជា គាត់ធ្លាប់ចេញទៅសំឡូតដែរទេ?

[០៩:១៤:៤៣]

**ឆ៖** កាលឆ្នាំ៧២ គាត់បានទៅ។ ខ្ញុំក៏បានទៅជាមួយគាត់ដែរ ឆ្នាំ៧២។

**ស៖** លោកបានទៅដែរ អីចឹងតើលោកដឹងទេថា គាត់ទៅសំឡូតហ្នឹងទៅធ្វើអ្វី?

**ឆ៖** គាត់ទៅធ្វើដំណើរទៅសំឡូតហ្នឹងគឺថា ជួបមេភូមិភាគពាយ័ព្យ ដូចជា រស់ ញឹម, តាគី, តាកាតុល ហៅ ហេង ទាវ ហ្នឹងហើយ តាស៊ូ ហើយនិង តាសម័យ, តាវ៉ាញ ឃើញប្រជុំគ្នានៅហ្នឹង ហើយជួប ហ៊ូ យន់ ដែរ។

**ស៖** នៅពេលនោះលោកមានដឹងទេថា គាត់ទៅជួបអ្នកទាំងនេះហ្នឹង ដើម្បីធ្វើអ្វីដែរ លោកមានដឹងទេ?

**ឆ៖** ខ្ញុំឃើញរូបភាពហ្នឹង គឺថាធ្វើការដូចខ្ញុំបានបញ្ជាក់បន្តបន្ទាប់ហ្នឹង គាត់ប្រជុំក្នុងដឹកនាំហ្នឹង ឃើញគាត់ -- ឃើញៗរូបភាពឃើញធ្វើការដូចគ្នា កន្លែងណាដូចកន្លែងណាដែរ។

[០៩:១៦:២៩]

**ស៖** បាទ អរគុណ។ ការពីម្សិលមិញលោកបានជម្រាបជូនអង្គសវនាការថា លោកបានស្ដាប់តាមការផ្សាយរបស់វិទ្យុប៉េកាំង ដែលបញ្ជាក់ថាលោក អៀង សារី គឺជាបេសកជនពិសេសនៅប៉េកាំងអមសម្ដេច សីហនុ។ តើលោកដឹងទេថា វិទ្យុនោះផ្សាយជាភាសាអី? ហើយមាននរណាជាអ្នកគ្រប់គ្រងដែរ?

**ឆ៖** វិទ្យុហ្នឹងគឺថា ផ្សាយតាមសំឡេងគឺថា ភាសាខ្មែរយើង ភាសាខ្មែរ។ វិទ្យុប៉េកាំងរាល់ថ្ងៃ

ហ្នឹង នែ៎អង្គាល់នុ៎ងក៏ផ្សាយដូចតែគ្នាហ្នឹង។ អារាល់ថ្ងៃក៏គាត់មាន កាលនោះ ក៏គាត់មានដែរ។

**ស៖** បាទ អរគុណ។ ចុះលោកដឹងទេថា ហេតុអីបានជាលោក អៀង សារី គាត់ទៅអមសម្តេច សីហនុ យ៉ាងដូច្នេះ ហើយមានហេតុផលអ្វីដែរ លោកអាចបញ្ជាក់បានទេ?

[០៩:១៧:៤២]

**ផ៖** ខ្ញុំមិនអាចលម្អិតបានទេ ប៉ុន្តែឃើញតាំងពីនុ៎ងមកគឺថា ផ្សាយតាមវិទ្យុបន្តបន្ទាប់មក។ តាមវិទ្យុហ្នឹងផ្សាយបន្តបន្ទាប់អ៊ីចឹង។

**ស៖** បាទ អរគុណ។ បើយោងតាមការរៀបរាប់របស់លោកកន្លងមកឃើញថា លោកគឺជាអ្នកដែលនៅក្បែរ ហើយនិងជាអ្នកដែលធ្វើការឲ្យថ្នាក់ដឹកនាំបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា តាំងពីយូរមកហើយ ពោលគឺតាំងពីឆ្នាំ១៩៦៧មកម្លេះ។ អ៊ីចឹងចង់ដឹងថា តើលោកដឹងទេថាតំបន់រំដោះរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងមានកន្លែងណាខ្លះរហូតមកដល់ឆ្នាំ៧៥? តើលោកដឹងទេ?

**ផ៖** តាមបទឧទ្ទេសនាមរបស់អ៊ំៗដឹកនាំនោះផង ហើយតាមការស្តាប់វិទ្យុតំបន់រំដោះពេលនុ៎ងគឺថា នៅជនបទហ្នឹងស្ទើរតែថាៗទាំងស្រុងតែម្តង ហៅថាតំបន់ជនបទហ្នឹង គឺថានៅតែតាមទីរួមខេត្តខ្លះ នៅទីប្រជុំជនខ្លះហ្នឹង។ អាហ្នឹងគឺតាមការស្តាប់ ហើយតាមការឧទ្ទេសនាមរបស់គាត់ គឺអ៊ីចឹង។

**ស៖** បាទ អរគុណ។ ចុះលោកមានដឹងដែរទេថា នៅតំបន់រំដោះហ្នឹងគេអនុញ្ញាតឲ្យមានការចាយលុយ ឬក៏មានទីផ្សារអីដែរទេ?

**ផ៖** តាំងពីខ្ញុំបានចូលរួមគឺថា ចាប់ពី៦៧ មក ពេលនុ៎ងមានប្រាក់ខែដែរ។ ខ្ញុំក៏មានប្រាក់ខែដែរ។ ហើយដល់ពី៦៧ មកដល់រំដោះ៧៥ មក គឺចន្លោះហ្នឹងចាយលុយគ្រប់ភូមិភាគក៏ចាយដែរ។ ចាយចាយលុយទាំងអស់ មិនទាន់មានអីទេ។

[០៩:២០:២៨]

**ស៖** បាទ អរគុណ។ ចុះលោកមានដឹងដែរទេថា នរណាខ្លះដែលបក្សចាត់ទុកជាខ្មាំង?

**ផ៖** តាមគាត់អប់រំជាបន្តបន្ទាប់មក គឺថាកាលនោះ យើងបានកំណត់ថា យើងធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។ ប្រជាជាតិហ្នឹង គឺបញ្ជាក់ច្បាស់ថា គឺចក្រពត្តិអាមេរិកហ្នឹងហើយ។ អាហ្នឹង អាហ្នឹងគឺមេខ្លោងបំផុតហើយ អាហ្នឹងគឺដើរតែឈ្លានពានគ្រប់ប្រទេស។ ហើយនៅកម្ពុជានេះមកទម្លាក់២០០ថ្ងៃ ២០០យប់ ៧៣ហ្នឹងធ្វើឲ្យ -- អាហ្នឹងគឺថាបញ្ជាក់ភស្តុតាងជាក់ស្តែងឃើញអ៊ីចឹងម្តង ឃើញអ៊ីចឹង។ ហើយដល់អ៊ីចឹងចេះតែអប់រំហើយ អប់រំហ្នឹងគឺថាខ្មាំងរបស់យើង គឺអាហ្នឹងហើយ

អាហ្នឹង។ ហើយអ្វីដែលខ្មាំងមួយទៀត គឺថាអ្វីដែលថាប្រឆាំងបដិវត្តន៍ អាហ្នឹងខ្មាំងដែរ បើមិនចូលរួមបដិវត្តន៍ហ្នឹង គឺថាប្រឆាំងបដិវត្តន៍ គឺខ្មាំងដែរហ្នឹង។ ខ្មាំងសម្ងាត់នេះ ចង់និយាយកាលហ្នឹង ប្រើពាក្យដូចថា សេ.អ៊ី.អា ផង កា.ហ្សេ.បេ ផង។ វាមានដែរ អាហ្នឹងគេមានដែរ មានអប់រំហ្នឹងហើយ ឲ្យយល់ពីបញ្ហាហ្នឹងឲ្យច្បាស់ បែងចែកខ្មាំងហ្នឹងឲ្យច្បាស់កុំឲ្យស្រពេចស្រពិល។

[០៩:២២:៣៤]

**ស៖** ចុះលោកមានដឹងទេថា បក្សមានវិធានការយ៉ាងណាដែរចំពោះអ្នកដែលចាត់ទុកថាជាខ្មាំងហ្នឹង?

**ឆ៖** ពីចន្លោះនៃ រដ្ឋប្រហារមក ១៨ មីនា ឆ្នាំ៧០ រហូតដល់ ៧៥ ហ្នឹង ឃើញៗ ជាក់ស្តែងហ្នឹង គឺថាក្នុងសមរភូមិហ្នឹង គឺថារវាងអ្នកតស៊ូ ហើយនិងសេនាប្រមុខលន់ នល់ ហ្នឹងហើយ ដែលក្នុងជាតិយើងឃើញហ្នឹង។ ហើយអាមេរិកជាអ្នកគាំទ្រ ឃើញអ៊ីចឹង។

**ស៖** បាទ អរគុណ។ ចុះលោកអាចបញ្ជាក់បានទេថា លោកបានដឹងទេ ថាតើបក្សមានវិធានការយ៉ាងដូចម្តេចខ្លះចំពោះអ្នកដែលបក្សចាត់ទុកថា ជាខ្មាំង?

**ឆ៖** ក្នុងសង្គ្រាម គឺថាសង្គ្រាមហ្នឹងគឺថាពន្យល់ច្បាស់ គ្រប់នៃភូមិភាគ គ្រប់តំបន់ គ្រប់ស្រុក គឺ គឺដូចខ្ញុំថាហ្នឹងគឺថា បើក្នុងសមរភូមិ គឺថាត្រូវវ៉ៃគ្នាហ្នឹងហើយ ក្នុងសមរភូមិ។ បើក្រៅពីសមរភូមិហ្នឹង គឺថា បើថាអ្នកដែល ដែលប្រឆាំងបដិវត្តន៍ហ្នឹង គឺថាក្នុងរយៈហ្នឹង ខ្ញុំក៏មិនឃើញ មិនឃើញជាក់ស្តែងអីទេ ប៉ុន្តែនិយាយថា អ្នកដែលប្រឆាំងបដិវត្តន៍ មិនដឹងជាមានវិធានការយ៉ាងម៉េច ខ្ញុំក៏អត់ដឹងដែរ។ ប៉ុន្តែឃើញ ដែលឃើញនៅ បើក្នុងសមរភូមិ ឃើញតែមានតែរឿងវ៉ៃគ្នាហ្នឹងហើយ មួយឈ្នះដៃដែរ វ៉ៃគ្នាមួយឈ្នះដៃសមរភូមិមួយៗ។

[០៩:២៥:០៩]

**ស៖** បាទ អរគុណ។ មុននេះបន្តិចលោកបានជម្រាបជូនអង្គសវនាការថា គាត់អប់រំអំពីថា អ្នកណាជាខ្មាំង តើលោកអាចបញ្ជាក់បានទេ តើគាត់ហ្នឹងជាអ្នកណាដែរ?

**ឆ៖** គាត់អប់រំ គឺថាក្នុងថ្នាក់ដឹកនាំខាងលើៗហ្នឹង គឺមានមតិដូចគ្នាហ្នឹង។ អ៊ំប៉ុល ពត ក៏មានមតិអ៊ីចឹង អប់រំអ៊ីចឹង។ អ៊ំនួន ជា ក៏អ៊ីចឹង, អ៊ំខៀវ សំផន ក៏អ៊ីចឹង, អ៊ំសុន សេន ក៏អ៊ីចឹង, យុន យ៉ាត ក៏អ៊ីចឹង, អ៊ំអៀង ធីរិទ្ធ ក៏អ៊ីចឹង គាត់មានមតិដូចៗគ្នា ៗ។

**សៈ** បាទ អរគុណ។ ចំណុចមួយទៀត ទាក់ទងទៅនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិម ឬក៏ប្រជុំសន្និបាតបក្ស។ នៅក្នុងពេលដែលថ្នាក់ដឹកនាំ បក្សបានផ្លាស់ទីមកកាន់មន្ទីរ ស-៧១ នៅស្ទឹងត្រង់ហ្នឹងពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ តើក្នុងអំឡុងពេលនេះ តើធ្លាប់មានការប្រជុំរវាងថ្នាក់ដឹកនាំបក្សដែរទេ? ហើយបើមានតើការប្រជុំនោះញឹកញាប់ដែរឬទេ?

[០៩:២៦:៤៩]

**ឆៈ** ខ្ញុំឃើញជាក់ស្តែងគឺថា មានប្រជុំក្នុងសមាជិកមជ្ឈិមទាំងអស់ ដែលគេនៅគ្រប់ភូមិភាគហ្នឹងមកចូលរួមប្រជុំគេមានដែរ។ ឆ្នាំ៧១ នេះមានម្តងប្រជុំ ប្រជុំរួម។ មិនញឹកញាប់ទេអាហ្នឹង បីបួនឆ្នាំប្រជុំម្តង។

**សៈ** បាទ អរគុណ។ លោកបានបញ្ជាក់ថា ឆ្នាំ៧១ ប្រជុំរួម ហើយបីបួនឆ្នាំប្រជុំម្តង ប្រជុំធំ។ តើក្រៅពីប្រជុំធំ មានប្រជុំតូចៗអីទៀតដែរទេ?

**ឆៈ** ប្រជុំតូចជាអចិន្ត្រៃយ៍ហ្នឹងមាន។ មានប្រជុំតាមភូមិភាគផង ប្រជុំតាមសមរភូមិផង គឺមាន មិនថាប្រាំង មិនថាវស្សាទេ។ ពិសេសក្នុងរដូវវស្សាហ្នឹង គឺថា អប់រំហ្នឹងគឺច្រើនតែម្តង ប្រជុំទាំងអស់។

**សៈ** បាទ អរគុណ។ អម្បាញ់មិញលោកបានបញ្ជាក់ថា ឆ្នាំ៧១ មានការប្រជុំរួម ប្រជុំធំ តើការប្រជុំធំហ្នឹងមានអ្នកណាខ្លះចូលរួមដែរ?

**ឆៈ** ប្រជុំក្នុងឆ្នាំ៧១ ហ្នឹង គឺថាជាអចិន្ត្រៃយ៍ តែបើកវគ្គរៀនសូត្រហ្នឹង គឺថា កាលនោះជួនហៅអ៊ំទី១ ហើយអ៊ំទី២ ហ្នឹងហើយ ជាអចិន្ត្រៃយ៍គឺគាត់ពីរនាក់។ ពីរនាក់ហ្នឹងជាអចិន្ត្រៃយ៍។ ព្រោះអាហ្នឹងកម្មាភិបាលទូទាំងប្រទេសមក មកជុំគ្នា គឺគាត់ពីរនាក់ហ្នឹងហើយជាអ្នកឧទ្ទេសនាម។ អាហ្នឹងប្រជុំធំ។

[០៩:២៩:១៥]

**សៈ** ចុះលោកនៅចាំទេថា ការប្រជុំដែលមានកម្មាភិបាលទូទាំងប្រទេសមកចូលរួម ហើយដែលឧទ្ទេសនាមដោយលោក ប៉ុល ពត និងលោក នួន ជា តើនេះជាកិច្ចប្រជុំសន្និបាត ប្រជុំមជ្ឈិមបក្ស ឬក៏ប្រជុំអីផ្សេង?

**ឆៈ** ប្រជុំហ្នឹងគឺថាមានពីរផ្នែក ដែលគណៈតំបន់ គណៈស្រុក ដែលមកផ្តុំ មកប្រជុំ អង្គាល់ហ្នឹងប្រជុំនៅភូមិភាគ៣០៤។ ទូទាំងប្រទេសហ្នឹងប្រជុំនៅហ្នឹង។ ហ្នឹងគឺៗតែគាត់ពីរនាក់ឧទ្ទេសនាម។

បន្ទាប់ពីប្រជុំហ្នឹងចប់ហើយ បានទៅប្រជុំដោយឡែកនេះ គឺគេប្រជុំក្នុងមជ្ឈិម គេហៅមជ្ឈិមពេលនុ៎ង គេថាប្រជុំៗគ្នាច្រើនដែរ គេថាសមាជិកទូទាំងប្រទេសហ្នឹង គឺមកចូលរួម អាហ្នឹងអត់មានគណៈតំបន់ គណៈស្រុកទេ មានតែៗថ្នាក់ភូមិភាគ ទាំងៗស៊ីវិល ទាំងយោធាចូលរួមទាំងអស់ពេលហ្នឹង។ គ្រប់ភូមិភាគទាំងអស់។

**ស៖** ចុះលោកចាំបានទេថា ការប្រជុំហ្នឹងអស់រយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ការប្រជុំចុងក្រោយហ្នឹងគឺថាជាងមួយអាទិត្យទេ អត់យូរទេ។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំដែរទេថា ក្នុងចំណោមការប្រជុំទាំងអស់ដែលមាននៅមន្ទីរស-៧១ ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ តើមានវត្តមានរបស់លោក អៀង សារី បានចូលរួមនៅពេលណាខ្លះដែរទេ?

[០៩:៣១:៤៧]

**ឆ៖** ប្រជុំនៅឆ្នាំ៧១ អត់មានវត្តមានអ៊ំ អៀង សារី ទេ ព្រោះគាត់ទៅក្រៅនោះហើយ គាត់ទៅក្រៅ។ អត់មានទេ។

**ស៖** ក្នុងឆ្នាំ៧១ អត់មានទេ ចុះពីចន្លោះពី៧១ ដល់៧៥ តើការប្រជុំទាំងអស់ដែលមានក្នុងចន្លោះនេះ តើមានពេលណាខ្លះដែលលោក អៀង សារី មានវត្តមានក្នុងកិច្ចប្រជុំហ្នឹង?

**ឆ៖** លោកអ៊ំ អៀង សារី មានវត្តមាន គឺថាប្រជុំឆ្នាំ៧៤។ អាហ្នឹងបានមានវត្តមានគាត់។ ព្រោះអ៊ំ អៀង សារី ឆ្នាំ៧៣ អមសម្ដេចឪមកទស្សនកិច្ចតំបន់រំដោះដែរ។ តំបន់រំដោះ ពេលហ្នឹងគាត់មកម្ដង គឺថាមកជូនដំណើរហ្នឹងហើយ ហើយត្រឡប់ទៅវិញ។ ហើយ៧៤ ក៏មក ៧៤ បានគាត់ចូលរួមប្រជុំធំ។

**ស៖** កាលដែលលោក អៀង សារី គាត់មកចូលរួមប្រជុំធំនៅឆ្នាំ១៩៧៤ ហ្នឹង តើលោកដឹងទេថា ការប្រជុំនេះ គេប្រជុំពីបញ្ហាអ្វីដែរ?

[០៩:៣៣:៣៣]

**ឆ៖** ការប្រជុំនេះ គឺថាមិនខុស ពីការប្រជុំរាល់ដងទេ ដូចខ្ញុំបានជម្រាបបន្តបន្ទាប់ហ្នឹង។ ប្រជុំប្រហែលៗៗគ្នាហ្នឹង ដូចគ្នាហ្នឹង។ គេទៅឧទ្ទេសនាម ទស្សនៈសភាពការណ៍ក្នុងប្រទេស ក្រៅប្រទេស ហើយឃើញសភាពការណ៍ដែលចលនាយើងតស៊ូហ្នឹង គឺថាវាៗបានតំបន់រំដោះប៉ុនណាៗៗហ្នឹង គឺថាបញ្ជាក់ ដោយសារថា តាមភូមិភាគមកនេះបញ្ជាក់ច្បាស់ទៅ ហើយធ្វើជីវទស្សនៈបដិវត្តន៍ហ្នឹងហើយៗ

បានលើកវិធានការបន្តតទៅទៀត សម្រាប់តៗទៅទៀត។ គាត់ឃើញធ្វើតែធ្វើតែប៉ុណ្ណឹង។ ចែកគ្នាត្រឡប់ទៅវិញតាមភូមិភាគវិញទៅ។

**ស៖** បាទ អរគុណ។ តើលោកអាចបញ្ជាក់បានទេថា ហេតុអ្វីបានជាលោកដឹងថាគេប្រជុំពីបញ្ហាអស់នេះ?

[០៩:៣៤:៤៥]

**ឆ៖** ខ្ញុំៗដឹងហ្នឹងគឺថាតាមរយៈដែលខ្ញុំយាមហ្នឹងតែម្តង។ ហើយតាមរយៈខ្ញុំៗអ្នកនៅផ្ទះបាយ ខ្ញុំលើកបាយ ឮគាត់និយាយគ្នាត់ហ្នឹង ប្រាជ្ញជុំវិញសភាពការណ៍ក្នុងប្រទេស ក្នុងសភាពការណ៍ក្រៅប្រទេស។ ហើយយើងយាមហ្នឹង យើង -- ព្រោះការយាមហ្នឹងមួយផ្នែកយាមការពារ ប៉ុន្តែមួយផ្នែកក៏ក្តាប់ខ្លឹមសារដែរ ឧទ្ទេសនាមដែរ គាត់គួសវាសនឹងក្តារខៀនហ្នឹង ឃើញៗឃើញដែរ។ ឃើញហ្នឹង គឺឃើញអ៊ីចឹងតាមអ៊ីចឹង។ ហើយដូចៗថា រូបខ្ញុំផ្ទាល់បើថាចំពេលខ្ញុំយាមហ្នឹង ខ្ញុំពិនិត្យហ្មត់ចត់ណាស់ ខ្ញុំតាមដានអ៊ំៗធ្វើម៉េច។ ខ្ញុំក៏រៀនសូត្រ លួចរៀនសូត្រពីគាត់អ៊ីចឹងដែរ។ មួយផ្នែកឯកសារ មួយផ្នែកដូចគាត់ឧទ្ទេសនាមឯកសាររស់ ឃើញថាវាល្អដែរ ដូចជាមានកម្លាំងក្នុងការធ្វើការងារដែរ ដល់អ៊ីចឹងចេះតែចង់ៗស្តាប់ដែរ។ ចង់ស្តាប់ ចង់យល់ ចង់ចេះដែរអ៊ីចឹង។

**ស៖** បាទ អរគុណ។ លោកធ្លាប់ -- លោកបានទៅយាមនៅទីនោះ តើលោកធ្លាប់បានទៅយាមនៅ ឬក៏ទៅការពារនៅកិច្ចប្រជុំណាមួយដែរទេនៅក្នុងឆ្នាំ១៩៧៥?

[០៩:៣៦:២៣]

**ឆ៖** ចាប់ពីរំដោះ១៧ មេសា ៧៥ មក ការងារមមាញឹកណាស់។ ការងារមមាញឹក ខ្ញុំត្រូវតែធ្វើការងារជាក់ស្តែងដែរ មិនសូវបានយាមផ្ទាល់ទេ គឺថាខ្ញុំពេលហ្នឹងខ្ញុំត្រូវទទួលខុសត្រូវខាងការងារទទួលភ្ញៀវ ខាងរដ្ឋបាលហ្នឹង គេទទួលភ្ញៀវហ្នឹង ទៅមើលអាហ្នឹង។ ដូច្នេះថាអត់សូវបានចូលយាមទេ ដល់ហ្នឹងចូលឋានៈត្រូវទទួលខុសត្រូវមួយផ្នែកអ៊ីចឹងដែរ។

**ស៖** បាទ អរគុណ។ ចុះមុនពេលរំដោះ នៅក្នុងឆ្នាំ១៩៧៥ហ្នឹង មុនពេលរំដោះ១៧ មេសា ៧៥ តែមុនហ្នឹង តើមានកិច្ចប្រជុំណាមួយដែរទេ ដែលលោកបានទៅយាមនៅទីនោះ?

**ឆ៖** ខ្ញុំបានទៅយាមអង្គាល់ប្រជុំឆ្នាំ៧៤ នេះ ខ្ញុំបានទៅយាមដែរនៅ៧៤។ ហើយចាប់ពី៧៤ហ្នឹង គឺថាមកសមរភូមិនៅ សមរភូមិជុំវិញភ្នំពេញនេះ ប៉ុន្តែនៅមន្ទីរ១ គេហៅមន្ទីរប-៥ ១ហ្នឹង អាហ្នឹងខ្ញុំបានយាមដែរ។

**សះ** បាទ អរគុណ។ តើមន្ទីរប-៥ហ្នឹងជាកន្លែងអ្វីដែរ លោកអាចជម្រាបជូនអង្គសវនាការបានទេ?

**ឆះ** កន្លែងប-៥ នោះ ជាកន្លែងបញ្ជាសមរភូមិទូទាំងប្រទេស គឺវៃរំដោះទីក្រុងភ្នំពេញហ្នឹងឯង។

[០៩:៣៨:៣៣]

**សះ** លោកបានជម្រាបថា នៅប-៥ មានការប្រជុំ តើប្រជុំហ្នឹងគេប្រជុំពីបញ្ហាអ្វីដែរលោកនៅចាំទេ?

**ឆះ** ជាអចិន្ត្រៃយ៍គឺថា នៅកន្លែងហ្នឹងអ៊ំ ប៉ុល ពត ហ្នឹងគាត់នៅជាអចិន្ត្រៃយ៍។ ពេលខ្លះ អ៊ំ នួន ជា ក៏អញ្ជើញមកដែរ រួចពេលខ្លះអ៊ំ ខៀវ សំផន គាត់អញ្ជើញមកដែរ។ អញ្ជើញមក។ អង្កាល់ហ្នឹងគេប្រជុំក្នុងគ្នាគាត់បីនាក់ហ្នឹងគាត់ប្រជុំជាអចិន្ត្រៃយ៍ក៏ប្រជុំដែរ។ ហើយកម្មាភិបាលតាមសមរភូមិទៀត គឺប្រជុំជាអចិន្ត្រៃយ៍ ដូចជា៖ សុន សេន, តាម៉ុក, វន វ៉េត, ចេង អន, កុយ ធួន, កែ ពក, សោ ភឹម, ហើយនិង តាភួង១ ដែរនៅខាងបូព៌ាហ្នឹង តាទុំ ហើយ តាភួង មកប្រជុំ។ ហើយកំណត់គ្នាគាត់ បើគាត់ថាប្រាំថ្ងៃជួបគ្នាម្តង គឺប្រាំថ្ងៃមកជួបគ្នាម្តង ប្រាំថ្ងៃ ឬក៏ ១០ថ្ងៃ ឬមួយកន្លះខែហ្នឹង តាមសភាពការណ៍ជាក់ស្តែងនៅសមរភូមិ។

[០៩:៤០:១០]

**សះ** នៅមន្ទីរប-៥ ហ្នឹង នៅក្នុងឆ្នាំ១៩៧៥ តើមានការប្រជុំអីដែលមានលក្ខណៈជាទ្រង់ទ្រាយធំដែរទេ?

**ឆះ** ក្នុង -- ដើមឆ្នាំដើមឆ្នាំ៧៥ នៅមន្ទីរហ្នឹងគឺថា ប្រជុំធំដំមិនមានទេ ប៉ុន្តែប្រជុំ ដូចខ្ញុំថាប្រជុំជាអចិន្ត្រៃយ៍ ការងារប្រចាំថ្ងៃហ្នឹង គឺមានបន្តបន្ទាប់អ៊ីចឹង។ ហើយក្នុងនុំង ខាងពាយ័ព្យ ហើយខាងលិចហើយនិងខាងកើត អាហ្នឹងគឺញឹកញាប់ជាងគេគឺថា ដូចជា កុយ ធួន គាត់ទទួលមុខកំពូល ដូចជា សុន សេន គាត់ទទួលនៅចន្លោះផ្លូវលេខ៤ មកផ្លូវលេខ៥ ហើយតាម៉ុក គាត់នៅរបផ្លូវលេខ៤ និងផ្លូវលេខ៣ ហ្នឹង ដូចថា វន វ៉េត គាត់នៅទន្លេមេគង្គក្រោម ទន្លេបាសាក់ អាហ្នឹងឃើញគាត់។ គាត់ហៅគ្នាប្រជុំជាបន្តបន្ទាប់អ៊ីចឹង។

[០៩:៤១:២៥]

**សះ** ចុះនៅក្នុងការប្រជុំនៅប-៥ ហ្នឹង តើមានពេលណាមួយដែលគេប្រជុំលើកឡើង អំពីបញ្ហា

ទាក់ទងទៅនឹងការជម្លៀសប្រជាជនដែរទេ?

**ឆ៖** ដូចតាមការខ្ញុំចាំ គឺថា ដើមខែ៤ នៅឆ្នាំ៧៥ ហ្នឹង អ៊ំៗគាត់ប្រជុំពិគ្រោះពិភាក្សា ពីរឿងជម្លៀសប្រជាជនដែរ។ មានៗ អ៊ំ ប៉ុល ពត គាត់លើកឡើង ហើយអង្គប្រជុំនោះ កាលហ្នឹងអ៊ំ នួន ជា ក៏នៅហ្នឹង អ៊ំ ខៀវ សំផន ក៏នៅហ្នឹង តាម៉ុក ក៏នៅហ្នឹង សុន សេន, កុយ ធួន, វន វ៉េត, ចេង អន អីហ្នឹង ហើយនិង តាភឹម អីហ្នឹង សោ ភឹម អីហ្នឹង នៅហ្នឹងទាំងអស់។ មានប្រជុំម្តងដែរហ្នឹង។

**ស៖** នៅក្នុងការប្រជុំហ្នឹង តើហេតុអីបានជាលោកដឹងថា គេនិយាយពីបញ្ហាហ្នឹង?

**ឆ៖** ថ្ងៃហ្នឹងចំថ្ងៃដែលខ្ញុំត្រូវយាមដែរ យាម ព្រោះប្រជុំកណ្តាលវាល គិតទៅដំបូលហ្នឹងប្រក់ស្លឹក រោងហ្នឹងប្រក់ស្លឹកត្នោតអីចឹង ជុំគ្នាហ្នឹង។ ផែនទីសម្រាប់ទូទាំងប្រទេសក៏មាន ផែនទីសម្រាប់សមរភូមិក៏មាន ហើយនិងលាតផែនទីមើលហ្នឹង ឮគាត់ពិគ្រោះពិភាក្សាគ្នា។ បើសន្និដ្ឋានពិភាក្សា គេថា លន់ នល់ មិនអាចទប់យើងបានទេ ប៉ុណ្ណេះយើងជាន់មួយរយៗហើយ។ ហ្នឹងពេលហ្នឹង គឺអីចឹងហើយ សភាពការណ៍វាអនុគ្រោះឲ្យយើងហើយ។ ដល់ៗមករាយការណ៍តាមសមរភូមិនោះ ឃើញថា វាជាន់គ្រប់កន្លែងហើយ វាគ្មានទៅហក់រួចទេ នៅតែថ្ងៃចាញ់យើងតែប៉ុណ្ណឹង។ ដល់ហ្នឹងចុងក្រោយចាញ់មែន មិនយូរប៉ុន្មានចាញ់បះជើងអីចឹងទៅ។

[០៩:៤៣:៥៦]

**ស៖** នៅពេលនោះតើលោកបានឮដែរទេថា តើគេត្រូវចាត់វិធានការយ៉ាងម៉េចខ្លះ ចំពោះប្រជាជនដែលគេបម្រុងនឹងជម្លៀសហ្នឹង គេមានលើកពីវិធានការ ដែលត្រូវចាត់ការដែរទេនៅពេលនុ៎ង?

**ឆ៖** លើកជាគោលការណ៍ គេថា បើយើងចូល កាន់កាប់ទីក្រុងភ្នំពេញនេះ យើងត្រូវជម្លៀសប្រជាជន។ កាលហ្នឹងគេថា គេជម្លៀសចេញតែរយៈកាលមួយអាទិត្យទេអីចឹង។

**ស៖** ចុះពេលនោះ លោកមានបានឮដែរទេថា វាមានភាពចាំបាច់អ្វីខ្លះដែរទេ ដែលធ្វើឲ្យគេលើកឡើងអំពីបញ្ហាជម្លៀសប្រជាជនហ្នឹង?

[០៩:៤៥:០៣]

**ឆ៖** រឿងហ្នឹង វាមានពិសោធន៍ជាបន្តបន្ទាប់មកដែរ មុនដែលយើងរំដោះភ្នំពេញ គឺថាតាមទីប្រជុំខ្លះ យើងរំដោះ បានរំដោះហ្នឹង។ ឃើញអ្នកដែលដឹកនាំប្រយុទ្ធសមរភូមិនីមួយៗ គាត់មានមតិថា គាត់ថា បើនៅប្រជាជន យើងពិបាក ពិបាកគ្រប់គ្រងណាស់ ហើយបើគេនៅនុ៎ង រាប់សិបឆ្នាំហើយ យើងទៅដឹងកន្ទុកកន្ទៀត គេម៉េចកើត។ អានេះ ខ្ញុំឃើញកម្មាភិបាលដែលធ្វើជាក់ស្តែងនៅសមរភូមិ

គាត់ថា អាហ្នឹង ទាល់តែជម្លៀសចេញបានស្រួល បានស្រួលក្តាប់។ បើពួកហ្នឹងនៅបង្កប់ខាងនុ៎ង យើងក្តាប់មិនបានទេ អាហ្នឹង។ បើយើងចង់រស់ ទាល់តែៗដាច់ខាតអាហ្នឹង។ បើយើងអ្នកតស៊ូហ្នឹងចង់រស់ ទាល់តែយើងដាច់ខាត ដឹងថាត្រូវជម្លៀសចេញឲ្យអស់។ ហើយនៅតែអ្នកធ្វើបដិវត្តន៍ហ្នឹង ចូលទៅទៅវាស្រួលជាង ស្រួលគ្រប់គ្រង។ អាហ្នឹង បងប្អូននៅខាងក្រោម គេនិយាយគ្រប់គ្នាៗអ៊ីចឹង។ អាហ្នឹងខ្ញុំស្តាប់ហ្នឹង ហើយតែផែនការពីលើ វាឃើញសមស្របគ្នាអ៊ីចឹងដែរ។

**ស៖** បាទ អរគុណ។ ចុះលោកបានឮទេ នៅក្នុងកិច្ចប្រជុំហ្នឹង បានលើកអំពីការជម្លៀសប្រជាជននៅតំបន់ផ្សេងៗទៀត ក្រៅពីទីក្រុងភ្នំពេញដែរទេ?

[០៩:៤៦:៣៨]

**ឆ៖** ពេលនោះ ខ្ញុំគ្មានឮទេ។ ប៉ុន្តែខ្ញុំថាមុនៗនោះ ដូចកាល៧៤ នោះ មិនរំដោះឧដុង្គ ទីរួមឧដុង្គហ្នឹង រំដោះ៧៤ អង្កាល់ហ្នឹង។ ដល់យកៗពិសោធន៍ហ្នឹងហើយ ហើយទីប្រជុំខ្លះ ជនខ្លះ ដូចជានៅត្រាំខ្នាដូចជានៅអ្នកលឿង អ្នកអីហ្នឹង ដូចជានៅស្គន់ ដូចនៅនេះហ្នឹង គឺថាលើកពិសោធន៍ទៅ វាឃើញជាក់ស្តែងអ៊ីចឹង។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ ជាបន្តទៅទៀតនេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីផ្តល់ឯកសារជូនទៅសាក្សី ហើយនិងសូមដាក់មកលើអេក្រង់ផងដែរ នូវឯកសារលេខ ដែលជាកំណត់ហេតុយកចម្លើយរបស់អ្នកស៊ើបអង្កេត នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានឯកសារលេខ E3/63 ត្រង់ ERN ជាភាសាខ្មែរ គឺ 00228844 ហើយជាភាសាអង់គ្លេសគឺ 00231439 ដល់ 10 ហើយជាភាសាបារាំងគឺ 00376054 ដល់ 55។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

[០៩:៤៩:៣១]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាន នៅត្រង់ -- បើលោកសាក្សី បើលោកមើលនៅត្រង់ទំព័រ ERN ជាភាសាខ្មែរហ្នឹង គឺ

00228844។ ហើយនៅក្នុងនោះ លោកបានថា នៅដើមខែមេសា ឆ្នាំ១៩៧៥ មានកិច្ចប្រជុំមួយ អំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលបានធ្វើនៅមន្ទីរ ប-៥ ហើយដែល ប៉ុល ពត ជាអ្នកដឹកនាំប្រជុំ។ លោកបានបញ្ជាក់ដែលថា សមាជិកនៃកិច្ចប្រជុំនេះ មានឡើងធ្វើចំណាប់អារម្មណ៍ និងលើកយោបល់ផ្ទាល់ខ្លួនលើផែនការនៃការជម្លៀស ហើយយល់ព្រមតាមផែនការនោះ។ ហើយលោកក៏បានលើកដែរថា នៅពេលនោះមានលោក ខៀវ សំផន និងលោក នួន ជា ក៏បានលើកមានយោបល់និងចំណាប់អារម្មណ៍ ហើយនិងឯកភាពតាមផែនការជម្លៀសប្រជាជននោះដែរ។ សំណួររបស់ខ្ញុំចង់ដឹងគឺថា សូមឲ្យលោកជួយបញ្ជាក់ជម្រាបជូនអង្គសវនាការថាតើពេលនោះលោក ខៀវ សំផន ឬក៏ដូចជាលោក នួន ជា ហ្នឹង គាត់មានយោបល់នឹងចំណាប់អារម្មណ៍យ៉ាងណាខ្លះដែលទើបឲ្យគាត់ឯកភាពទៅនឹងផែនការនៃការជម្លៀសប្រជាជននេះ?

[០៩:៥១:០៣]

**ឆ៖** ក្នុងពេលហ្នឹង ខ្ញុំឃើញថាអ៊ំ នួន ជា គាត់មានមតិមុនគេ។ គាត់ថា ចាំបាច់ ហើយនិងឯកភាព។ គាត់មានមតិអ៊ីចឹងជូនអង្គប្រជុំហ្នឹង។ ព្រោះសភាពការណ៍ឃើញវាចាំបាច់ហើយដែលថាជម្លៀសចេញហ្នឹង វាចាំបាច់ហើយ។ អាហ្នឹងគឺថា គាត់បញ្ជាក់ថា គាត់ជាទស្សនៈគោលជំហររបស់គាត់បញ្ជាក់ថា គាត់ឯកភាព។

**ស៖** ចុះលោក ខៀវ សំផន វិញ គាត់មានមតិយ៉ាងម៉េចដែរ បានគាត់ឯកភាព?

**ឆ៖** អ៊ំ ខៀវ សំផន គាត់ឯកភាពដែរ។ ឯកភាព។ ហើយអង្គប្រជុំទាំងមូលហ្នឹងឯកភាពទះដៃតើ។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយក៏សូមអរគុណលោកសាក្សីផងដែរ ដែលបានឆ្លើយនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាយ៉ាងក្បោះក្បាយ ដើម្បីឲ្យអង្គជំនុំជម្រះស្វែងរកការពិត និងយុត្តិធម៌ជូនដល់អ្នករងគ្រោះទាំងឡាយ។ ហើយជាកិច្ចបន្តនេះ សូមអនុញ្ញាតលោកប្រធានដើម្បីឲ្យសហការីខ្ញុំសួរសំណួរបន្តទៀត។ បាទ សូមអរគុណ។

[០៩:៥២:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រម។ អរុណសួស្ដីលោកសាក្សី ខ្ញុំឈ្មោះ ឌេល លីសាក់។ ខ្ញុំក៏ជាសហព្រះរាជអាជ្ញានៅក្នុងការិយាល័យសហព្រះរាជអាជ្ញាផងដែរ។ ហើយខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរលោកនៅក្នុងថ្ងៃនេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំចាប់ផ្ដើមសួរដោយបន្តសំណួរត្រង់ប្រធានបទ ដែលលោកទើបតែឆ្លើយជូនសហសេវិករបស់ខ្ញុំពាក់ព័ន្ធទៅនឹងការប្រជុំដើម្បីធ្វើការជម្លៀសទីក្រុងភ្នំពេញ។ ខ្ញុំសូមបញ្ជាក់ថា តើការប្រជុំនេះគឺដូចគ្នានឹងការប្រជុំនៅ ប-៥ នោះមែនដែរឬទេ? គឺគេប្រជុំលើបញ្ហាហ្នឹងតែមួយទេ តើអ៊ីចឹងដែរឬទេ?

[០៩:៥៣:៣៦]

**លោក វ៉ាចាម តុន៖**

**ឆ៖** បាទ ដូចគ្នា។

**ស៖** តើមន្ទីរ ប-៥ នេះនៅទីតាំងឯណាដែរក្នុងភូមិអ្វី? ក្នុងស្រុកអ្វី? ហើយនៅកន្លែងណា?

**ឆ៖** បាទ មន្ទីរ ប-៥ ហ្នឹងគឺនៅភូមិតាំងពោន ន៎ែ ឃុំខ្ញុំមិនចាំ ប៉ុន្តែនៅហ្នឹងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

**ស៖** តើលោកចាំដែរឬទេ? តើមន្ទីរ ប-៥នេះ បើកដំណើរការដំបូងនៅក្នុងពេលណាដែរ? តើលោកចាំដែរឬទេ?

**ឆ៖** គឺមន្ទីរហ្នឹងបើកដំបូងគឺថា ចុងឆ្នាំ៧៣។

[០៩:៥៥:០៤]

**ស៖** តើលោកទៅមន្ទីរ ប-៥ នោះលើកទីមួយនៅក្នុងពេលណា ក្នុងឆ្នាំណាដែរ? តើលោកចាំដែរឬទេ?

**ឆ៖** ខ្ញុំមកសមរភូមិហ្នឹង គឺថា ៧២ម្ដង។ ៧២ហ្នឹង អង្កាល់ហ្នឹងមិនទាន់កើតមន្ទីរ ប-១ ទេ គ្រាន់តែពេលហ្នឹង ៧២ហ្នឹងជូនដំណើរអ៊ំ នួន ជា គាត់ទៅសំឡូត។ អាហ្នឹង ខ្ញុំចង់និយាយថា ដែលៗ អ្នកទីមួយ ខ្ញុំបានឆ្លងកាត់កន្លែងហ្នឹង។ អាហ្នឹងគឺត្តុំហ្នឹង ក៏នៅជិតស្រុកកំណើតខាងគ្រួសារអ៊ំ នួន ជា ដែរ។ ដល់តែទីពីរ គឺថាឆ្នាំ៧៣ន៎ែ ៧៣គឺថា មុនដំបូងទៅដល់ភ្លាម គឺទៅនៅ គេហៅថា ច្រកស្ដេចទេ។ ទៅនៅច្រកស្ដេច ដល់ទៅនៅច្រកស្ដេចហ្នឹង កន្លែងហ្នឹងវាពិបាកចេញចូលដែរ វាចូលទៅជ្រៅ។ វា ទៅ

ជាចូលជ្រៅពេក វាពិបាក។ ប៉ុន្តែនៅត្រង់ភូមិក្រាំងស្រម៉ ហ្នឹងចូលទៅ ច្រកស្តេច ហ្នឹងវាពិបាក។ ដល់ក្រោយមក គឺថាចុង៧៣ហ្នឹង គឺថាគាត់ផ្លាស់ពីហ្នឹង មកបង្កើតកន្លែងប-៥ ហ្នឹងនៅភូមិតាំងពោនហ្នឹង។

[០៩:៥៦:៤៣]

ខ្ញុំចាំច្បាស់ ត្រង់ថាខ្ញុំ ខ្ញុំអ្នកទៅមើលដែរកន្លែងហ្នឹង ទៅមើល ទៅមើលជាមួយនែ៎ អង្គាល់ហ្នឹងនែ៎ លោកមេឃុំ អង្គាល់ហ្នឹងគេហៅលោកមេឃុំអង្គាល់ហ្នឹង។ លោកមេឃុំហ្នឹង គាត់ទៅមើល គាត់ឲ្យទៅមើល ទៅមើល។

**ស៖** លោកបាននិយាយថា លោកលើកដំបូងនោះ គឺលោកទៅកន្លែងនោះជាមួយនឹង នួន ជា នៅក្នុងឆ្នាំ១៩៧២ ពេលដែលជូនទៅ-- ជូន នួន ជា ទៅសំឡូត ហើយលោកក៏បានឈប់នៅភូមិកំណើតរបស់ប្រពន្ធ នួន ជា ផងដែរ។ តើភូមិកំណើតរបស់ប្រពន្ធ នួន ជា ឈ្មោះភូមិអ្វីដែរលោក?

**ឆ៖** ភូមិហ្នឹង គេហៅ ភូមិស្រែអណ្តូង។

**ស៖** នៅពេលដែលយើងនិយាយអំពីទីតាំងខេត្តកំពង់ឆ្នាំង និងទីតាំងឧដុង្គ។ តើមានមេដឹកនាំផ្សេងទៀតមានមូលដ្ឋានទីតាំងនៅក្នុងតំបន់ទាំងនោះដែរឬទេ នៅចុងឆ្នាំ៧៤ និងដើមឆ្នាំ៧៥នោះ?

**ឆ៖** ខាងលិចហ្នឹង ខាងលិចហ្នឹងបន្តិច គេថាមន្ទីររបស់ភូមិភាគនិរតី តាម៉ុក ដែលនៅហ្នឹងខាងលិចមន្ទីរ ប-១ ហ្នឹង។

[០៩:៥៨:៥៦]

**ស៖** តើ សុន សេន មានមន្ទីរនៅក្បែរឧដុង្គដែរឬទេ?

**ឆ៖** សុន សេន មាន១ មានមន្ទីរក្បែរហ្នឹងដែរ។

**ស៖** តើលោកចាំទេថា ទីតាំងមន្ទីររបស់ សុន សេន នោះនៅម្តុំណាដែរ?

**ឆ៖** នៅម្តុំគេហៅថា វ៉ាស្នាច់ ដែលផ្លូវចូលទៅទីរួម -- នែ៎ទីប្រជុំជនឧដុង្គ។ វ៉ាស្នាច់ហ្នឹងនៅខាងលិចឧដុង្គបន្តិច ជាប់នឹងផ្លូវរទេះភ្លើង។

[១០:០០:០៤]

**ស៖** តើបក្សមានមន្ទីរពេទ្យសម្រាប់ទាហានយោធានៅកន្លែងនោះដែរឬទេ?

**ឆ៖** មានតើ! ហ្នឹងហើយមាន។

**ស៖** តើនរណាគេដែលជាអ្នកទទួលបន្ទុកកាន់កាប់មន្ទីរពេទ្យយោធាកង -- សម្រាប់យោធាសម្រាប់កងទ័ពនោះ?

**ឆ៖** មន្ទីរហ្នឹងដែលធំជាងគេ គឺលោកតា ជួន ជឿន ដែលវេជ្ជបណ្ឌិត គាត់ហ្នឹងគឺនៅពេលលើ។ ឯអ្នកជាក់ស្តែងហ្នឹង គឺកាលហ្នឹងគឺឈ្មោះ១ន៉ែ ហុង។ ហុង បុរស ឈ្មោះ ហុង នៅប្រចាំនឹងកន្លែងហ្នឹង មន្ទីរពេទ្យហ្នឹង។

**ស៖** ចុះ វន វ៉េត។ តើ វន វ៉េត នេះមានមន្ទីររបស់គាត់នៅម្តុំខេត្តកំពង់ឆ្នាំងដែរឬទេ ឬក៏នៅជិតម្តុំៗហ្នឹងដែរឬទេ?

[១០:០១:៣៥]

**ឆ៖** មន្ទីរ វន វ៉េត នៅជាមួយ ចេង អន នៅៗជិតៗគ្នាហ្នឹង គេហៅនៅៗក្រាំងក្តីប។ ភូមិក្រាំងក្តីប។

**ស៖** តើនេះជាមន្ទីរសម្រាប់ភូមិភាគពិសេសនោះមែនដែរឬទេ?

**ឆ៖** អាហ្នឹងសម្រាប់ភូមិភាគពិសេស ព្រោះកាលហ្នឹងគាត់នៅគ្នាបីនាក់ វន វ៉េត, ចេង អន ហើយម្នាក់ទៀតស្លាប់ហើយ ខ្ញុំភ្លេចឈ្មោះគាត់ហើយ។ នៅម្នាក់ទៀត។

**ស៖** លោកបាននិយាយឈ្មោះ ចេង អន ពីរបីដងដែរ នៅព្រឹកនេះ ដែលថាជាមេដឹកនាំម្នាក់ចូលរួមក្នុងការប្រជុំ។ តើលោកដឹងទេ គាត់កាន់កាប់តួនាទីអ្វីដែរនៅក្នុងបក្ស?

**ឆ៖** ក្នុងបក្ស ខ្ញុំមិនដឹងល្អិតថាគាត់កាន់កាប់អីទេ ប៉ុន្តែគាត់ហ្នឹងគឺថានៅជាប់ជាមួយ វន វ៉េត។ គឺខាងយោធាផ្ទាល់ហ្នឹង គឺថាគាត់នោះហើយជាមួយ វន វ៉េត ហ្នឹងហើយ។

**ស៖** តើមានពេលមួយនោះ ដែលមេដឹកនាំដែលពួកគេនៅ ស-៧១ ដែលនៅជិតស្ទឹងត្រង់នោះ បន្ទាប់មកគេបានរើទីតាំងរបស់គាត់មក ប-៥ ឬក៏ទៅតំបន់ផ្សេង។ តើមានពេលមួយនោះដែលមេដឹកនាំស្ទើរតែទាំងអស់នោះ ផ្លាស់ប្តូរទីតាំងមកនៅ ប-៥ ដែរឬទេ?

[១០:០៣:៥៩]

**ឆ៖** អត់ៗមកទាំងអស់គ្នាទេ អត់មក -- កន្លែង ប-៥ ជាកន្លែងបញ្ជាការសមរភូមិមុខ។ ដូច្នេះដូចថានៅ ស-៧១ ក៏នៅ ហើយកន្លែងផ្សេងៗទៀតនៅចល័តច្រើន។

**ស៖** តើខ្ញុំយល់ដូច្នេះថា នៅចុងឆ្នាំ៧៤ និងដើមឆ្នាំ៧៥ គឺលោកនៅបន្តធ្វើការងារនៅមន្ទីរ ស-៧១ ហើយនិងក៏ធ្វើការនៅមន្ទីរ ប-៥ ដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ឆ្នាំ៧៤ ដើមឆ្នាំ៧៥ នេះ ខ្ញុំមកនៅជាមួយគាត់ជាអចិន្ត្រៃយ៍គឺនៅមន្ទីរ ប-៥ នោះហើយ។

[១០:០៥:០០]

 

**ស៖** តើ ប៉ុល ពត នោះនៅមន្ទីរប-៥ នៅចុងឆ្នាំ៧៤ និង ៧៥ នោះ យូរប៉ុនណាដែរ?

**ឆ៖** ខែ ហៅថារដូវប្រាំង គាត់នៅជាអចិន្ត្រៃយ៍នៅកន្លែងហ្នឹង រដូវវស្សាគឺមកស-៧១ វិញ។

**ស៖** ចុះចំពោះ នួន ជា វិញ តើគាត់នៅមន្ទីរប-៥ នោះរយៈពេលប៉ុន្មានដែរនៅចុងឆ្នាំ៧៤ និង ដើមឆ្នាំ៧៥?

**ឆ៖** ចំពោះលោកអ៊ំ នួន ជា គឺថាគាត់នៅកន្លែងមន្ទីរប-៥ គាត់នៅមិនបានយូរទេ យ៉ាងយូរ ណាស់មួយអាទិត្យ ឬមួយតិចជាងហ្នឹង គាត់ត្រឡប់មកសមរភូមិក្រោយវិញហើយ។

**ស៖** ចុះ ខៀវ សំផន វិញ? តើ ខៀវ សំផន នេះ គាត់មកមន្ទីរប-៥ នេះញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ចំពោះលោកអ៊ំ ខៀវ សំផន គាត់មកមិនសូវញឹកទេ ជាអចិន្ត្រៃយ៍គាត់នៅមន្ទីរនៅសមរ ភូមិក្រោយជាអចិន្ត្រៃយ៍។

[១០:០៧:២៦]

**ស៖** នៅពេលដែលលោកនិយាយថា គាត់នៅសមរភូមិក្រោយនោះ តើលោកចង់សំដៅលើទី តាំងកន្លែងណាដែរ?

**ឆ៖** ខ្ញុំបញ្ជាក់ថា សមរភូមិក្រោយហ្នឹងគឺថា មន្ទីរដែលសម្រាប់ចល័តនោះវាច្រើន ហ្នឹងច្រើន មិនមែនតែស-៧១ ទេ។ ច្រើន ដូច្នេះគឺថាគាត់នៅសមរភូមិខាងក្រោយហ្នឹង វាមានកន្លែងទីតាំងចល័តជា ច្រើនទៀត។

**ស៖** តើមន្ទីរចល័តនោះមានឈ្មោះអ្វីខ្លះទៅ? គេមានដាក់លេខកូដសម្គាល់ដែរឬទេបាទ?

**ឆ៖** មានៗលេខសម្គាល់ដែរតើ! គឺថាលេខ មន្ទីរ-២៤ ក៏មាន, មន្ទីរ-២២ ក៏មាន, មន្ទីរ-៣៥ ក៏ មាន, មន្ទីរ-៧៤ ក៏មាន, ប-១៧ ក៏មាន, ប-១៩ ក៏មាន, ប-២០ ក៏មាន អ៊ីចឹង។

**ស៖** សូមអរគុណដែលលោកបានជម្រាបបន្ថែមទៅលើមន្ទីរប-៥។ នៅពេលនេះយើងនិយាយ អំពីអំឡុងពេលខែមេសា ឆ្នាំ១៩៧៥ ដែលលោកបានជម្រាបសហព្រះរាជអាជ្ញាជាតិ។ លោកអាច ជម្រាបបន្ថែមទៀតបានដែរឬទេថា តើកិច្ចប្រជុំនោះប្រហែលជាជួបប្រជុំគ្នានៅក្នុងឆ្នាំណាដែរ នៅការ ប្រជុំថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នោះ? បាទ ការប្រជុំហ្នឹងគឺមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នោះតើ ប្រជុំហ្នឹងប្រហែលជានៅអំឡុងពេលណាដែរ?

[១០:០៩:៥៥]

**ឆ៖** អង្កាល់ហ្នឹង គឺមកខិតមកមុនបន្តិច គេហៅថា នៅភូមិស្តុកគោល១ ហើយចុងក្រោយ

ហើយហ្នឹង។ មុននឹងចូលភ្នំពេញ គឺនៅ -- ថយពីប-៥ មកនៅភូមិស្តុកគោល។

**ស៖** ប្រហែលជាមានចំណុចបកខុសបន្តិចបន្តួចទៅលើចំណុចនេះ។ កិច្ចប្រជុំដែលលោកនិយាយអំពីកិច្ចប្រជុំស្តីអំពីការជម្លៀសទីក្រុងភ្នំពេញនោះ តើតាមអ្វីដែលលោកចាំល្អបំផុតនោះ កិច្ចប្រជុំដែលលើផែនការជម្លៀស គេប្រជុំនៅពេលណាដែរ?

**ឆ៖** អំមិញខ្ញុំបញ្ជាក់ថា ប្រជុំដើមខែមេសា នៅមន្ទីរប-៥ហ្នឹង។

**ស៖** តើកិច្ចប្រជុំនោះរយៈពេលយូរប៉ុនណាដែរ? តើលោកអាចជម្រាបបានដែរទេ?

**ឆ៖** រយៈពេលប្រជុំហ្នឹង មិនយូរទេមួយព្រឹកតូច តែវាមិនពេញទេ។ ម៉ោងប្រាំពីរជាង ដល់ម៉ោងប្រហែលម៉ោងដប់ជាង ហ្នឹងសម្រាកហើយ។

**ស៖** លោកបានជម្រាបថា កិច្ចប្រជុំនោះ គឺធ្វើឡើងប្រជុំនៅក្រោមដើមដូង ម្លប់ក្រោមដំបូលបាទ តើកិច្ចប្រជុំនោះធ្វើឡើងនៅក្រោមដំបូលស្លឹក តើលោកពេលដែលប្រជុំនោះ លោកនៅចូលរួមជាមួយគេនៅខាងក្នុង ឬក៏នៅខាងក្រៅ?

[១០:១២:០៧]

**ឆ៖** កន្លែងប្រជុំហ្នឹង គឺថាអត់មានដើមដូងទេ មិនមែននៅក្នុងភូមិគេទេ គឺនៅកណ្តាលវាលគេហៅវាលស្រែ គឺថា មានដើម ដឹងដើមអីខ្លះទេ មានដើមន៉ែ ដើមខ្លុង ដើមត្បែងអីហ្នឹងៗដល់យើងគងអីចឹងទៅ យើងដាក់ស្លឹកនេះទៅស្លឹកត្នោត នៅក្បែរហ្នឹងៗយាមក្បែរហ្នឹង។

**ស៖** ដូច្នេះ ដើម្បីឲ្យលោកយល់បន្ថែមនោះ ថាតើកន្លែងប្រជុំនោះ គឺគេជាកន្លែងមួយ ដែលមានអគារ មានជញ្ជាំងជុំវិញដែរឬទេ? តើវាគេប្រជុំហ្នឹង នៅម្តុំណានៅកន្លែងណាដែរ?

**ឆ៖** ដូចខ្ញុំបញ្ជាក់បន្តបន្ទាប់មកហើយកន្លែងហ្នឹងអត់មានផ្ទះទេ ហើយអត់មានជញ្ជាំងទេកណ្តាលវាល គ្រាន់តែប្រក់ពីលើឲ្យម្លប់អីអីចឹង ហើយល្ហល្ហេវ វាលស្រែជុំវិញនេះ សុទ្ធតែស្រែគេនុំងនៅគុម្ពោតៗដំបូកនៅលើដំបូកហ្នឹងអីចឹង។ សូម្បីតែកន្លែងអ៊ំ ប៉ុល ពត សម្រាកហ្នឹងក៏មិនមានព្រៃដែរ គឺថានៅនឹងដំបូកមួយអីចឹងទៅ កន្លែងអ៊ំ នួន ជាដំបូកមួយអីអីចឹងទៅ ហើយកន្លែងប្រជុំដំបូកមួយអីចឹងទៅ អត់មានជញ្ជាំង អត់មានអីទេ កណ្តាលវាល។

[១០:១៣:៥៥]

**ស៖** នៅពេលមេដឹកនាំប្រជុំគ្នា ពិភាក្សាអំពីផែនការជម្លៀសទីក្រុងភ្នំពេញនោះ តើលោកអង្គុយនៅជិតពួកគេហ្នឹងរយៈចម្ងាយប៉ុនណាដែរ? នៅជិត ឬក៏នៅឆ្ងាយពីពួកគេ ពួកមេដឹកនាំគេប្រជុំនោះ?

**ឆ៖** ម្ខាងដំបូកម្នាក់ ខ្ញុំម្ខាងដំបូកហ្នឹង ខាងគាត់ម្ខាងដំបូកអ៊ីចឹងទៅ។ ដំបូកហ្នឹងតូចដែរទេ។

**ស៖** ទីកន្លែងដែលលោកយាម តើលោកអាចស្តាប់ឮអ្វីដែលគេពិភាក្សា រវាងមេដឹកនាំក្នុងកិច្ចប្រជុំនោះដែរឬទេ?

**ឆ៖** ខ្ញុំស្តាប់ទៅគាត់គណៈសមរភូមិដែលមកនោះ ទីមួយ គេរាយការណ៍សភាពការណ៍ៗ ហើយនិងទីពីរ នោះដែលគេរាយការណ៍អស់ទៅ អ៊ំទី១នោះ គាត់សរុបយោបល់ ហើយបានគាត់លើកវិធានការ។ លើកវិធានការ ទាំងវិធានការយោធា ទាំងវិធានការក៏ត្រូវតែជម្លៀសប្រជាជនចេញ បើថាចូលហើយ។ ពីព្រោះសមរភូមិហ្នឹង វាសមរភូមិចុងក្រោយ ហើយអ្នកដឹកនាំសមរភូមិនីមួយៗ គេរាយការណ៍ទៅ គេថាគឺ តាមវិធានការជាក់ស្តែង គឺថាបើរំដោះភ្នំពេញហើយ បើមិនជម្លៀស គឺពិបាកធ្វើការតែម្តង។ បើជម្លៀសចេញអស់ បានស្រួលធ្វើការ។

**ស៖** នៅពេលដែលគេធ្វើសេចក្តីសម្រេច ថាតើត្រូវជម្លៀស ឬក៏មិនត្រូវជម្លៀស ថាតើមេដឹកនាំ ដែលចូលប្រជុំនោះ ថាផ្តល់យោបល់ថា គេយល់ព្រម ឬមិនយល់ព្រម ទៅលើការជម្លៀស ឬមិនជម្លៀសភ្នំពេញដែរឬទេ?

[១០:១៦:១៨]

**ឆ៖** អម្បាញ់មិញ ខ្ញុំបានបញ្ជាក់ហើយថា គាត់លើកវិធានការហ្នឹង អ៊ំទី២ គឺអ៊ំ នួន ជាហ្នឹង គាត់ឯក -- គាត់ចាប់អារម្មណ៍ គឺថាគាត់ឯកភាព។ អ៊ំ ខៀវ សំផន គាត់ថា ឯកភាព ហើយអង្គភាពគ្រប់សមរភូមិនោះ គឺថាឯកភាពហើយ ទះដៃ តែប៉ុណ្ណឹង។ ទះដៃ បានន័យថា ឯកភាពហើយ មិនមានអីទៀតទេ អត់មានអីត្រូវជំទាស់អីទៀតទេ។

**ស៖** លោកបានប្រាប់សហព្រះរាជអាជ្ញាជាតិថា អ្នកដែលចូលរួមក្នុងអង្គប្រជុំនោះ បានពិភាក្សាអំពីបទពិសោធន៍ដែលថាទីក្រុងផ្សេងទៀត ដែលបានរំដោះមុននោះ។ តើលោកចាំទេ ថាតើអ្នកណាខ្លះ ដែលវត្តមាននៅពេលនោះ នៅក្នុងការពិភាក្សានិយាយពីបទពិសោធន៍ ដែលថាត្រូវជម្លៀសទីប្រជុំផ្សេងៗទៀត នៅពេលដែល -- នៅក្នុងតំបន់ដែលគេរំដោះបាន មុនរំដោះភ្នំពេញនោះ តើលោកនៅចាំទេ?

**ឆ៖** មុន រំដោះទីក្រុងផ្សេងៗ វាមានការរំដោះតាមទីប្រជុំជនមួយចំនួន ហើយអាហ្នឹង គាត់ឧទ្ទេសនាម ក្នុងឯកសារ គេថា ជាពិសោធន៍ដែលយើងបានរំដោះទីប្រជន (ទីប្រជុំជន) មួយចំនួន ដែលយើងធ្វើបានល្អទៅ គាត់ អ៊ំ ប៉ុល ពត គាត់ឧទ្ទេសនាមដែរ។ អ៊ំ នួន ជា ក៏គាត់ឧទ្ទេសនាមដែរ។ ឧទ្ទេស

នាមលទ្ធផលល្អ គឺចំណុចល្អៗហ្នឹង គាត់ឧទ្ទេសនាម ហើយចំណុចដែលធានាសន្តិសុខ គាត់ឧទ្ទេសនាម ទាំងអស់ ដើម្បីការពារកម្លាំង។ ឧទ្ទេសនាមហ្នឹង អង្គប្រជុំធំៗ ក៏ឧទ្ទេសនាមដែរ យកពិសោធន៍ហ្នឹង សម្រាប់ទូទាំងប្រទេសតែម្តង។

**ស៖** ដើម្បីឲ្យប្រាកដថា ខ្ញុំយល់ពីចម្លើយរបស់លោកនោះ មាន ប៉ុល ពត, មាន នួន ជា ដែល និយាយអំពីការជម្លៀសពីទីក្រុងផ្សេងៗទៀត តើអ៊ីចឹងដែរឬទេ?

**ឆ៖** ពិតប្រាកដហើយ។

**ស៖** នៅក្នុងការប្រជុំនោះ តើមានការណែនាំអ្វីទេដែលៗគេណែនាំទៅមេបញ្ជាសមរភូមិ ដែល វត្តមាននៅក្នុងការប្រជុំនោះ ដែលប្រាប់ទៅ ៗមេទាំងអស់នោះ ថាតើត្រូវធ្វើដូចម្តេច នៅពេលជម្លៀស? តើលោក -- ពេលដែលលោកយាមនោះ លោកបានឮទេ ពីការណែនាំទៅដល់មេកងទ័ពក្នុងសមរភូមិ កាលណោះ?

[១០:១៩:៤៨]

**ឆ៖** ខ្ញុំឃើញគាត់ នែ៎ គូសវាសក្នុងក្ដារៗខៀនហ្នឹង គឺថាមុខសញ្ញាណាៗ ដែលសុទ្ធតែមាន កម្មាភិបាលទទួលខុសត្រូវគ្រប់សញ្ញាទាំងអស់។ គាត់គូសៗ ព្រួញហ្នឹង ព្រួញណាត្រូវចេញទៅណាៗ គាត់គូសក្នុងក្ដារខៀនហ្នឹង ឃើញគាត់នែ៎ អ៊ំទី១ អ៊ំ ប៉ុល ពត ហើយគាត់អ្នកគូសហ្នឹង ឲ្យគេអនុវត្ត តាមៗព្រួញដែលគាត់បានគូសហ្នឹង។

**ស៖** តើលោកបានឮថាមាននរណាម្នាក់នៅក្នុងការប្រជុំលើកឡើងអំពីការព្រួយបារម្ភ អំពីការ ជម្លៀសមនុស្សទាំងអស់ចេញពីភ្នំពេញទេ? តើអ្នកណាម្នាក់លើកឡើងពីការព្រួយបារម្ភថា មានបញ្ហាអី បើជម្លៀសហ្នឹងទេ? តើលោកបានឮទេ?

**ឆ៖** អង្គប្រជុំពេលនោះ ដូចអត់មានទេៗ។ អត់មាននរណាមានយោបល់អ៊ីចឹង អត់មានតែ ម្តង។

**ស៖** សូមអរគុណ។ លោកក៏បានជម្រាបទៅសហព្រះរាជអាជ្ញាជាតិដែរថា ទីក្រុង ឬក៏ទីប្រជុំ ជនមួយដែលត្រូវបានជម្លៀសមុនភ្នំពេញនោះ គឺទីក្រុងឧដុង្គ តើលោកនៅចាំអ្វីខ្លះអំពីការរំដោះ ហើយ និងការជម្លៀសប្រជាជនចេញពីឧដុង្គដែរឬទេ? ជាបឋមនោះ តើលោកនៅកន្លែងណានៅពេលដែលគេ រំដោះក្រុងឧដុង្គដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យ លោកនៅកន្លែងណា?

[១០:២១:៤៦]

**ឆ៖** ខ្ញុំនៅមន្ទីរ ប-៥ហ្នឹងហើយ។ ហើយរំដោះភ្លាមខ្ញុំចូលតាមឧដុង្គហ្នឹងមកតាមព្រែកក្តាម មកស្គន់ មកកំពង់ថ្ម មកទៅស្ទឹងត្រង់វិញ ខ្ញុំទៅតាមហ្នឹង។ ខ្ញុំជិះម៉ូតូតាមហ្នឹង។

**ស៖** ការបកប្រែនោះ ដូចមិនសូវច្បាស់ តើលោកនិយាយថា ក្រោយពីការរំដោះក្រុងឧដុង្គ លោកធ្វើដំណើរទៅកន្លែងហ្នឹង ទៅស្ទឹងត្រង់ឬ? លោកធ្វើដំណើរឆ្លងកាត់តាមហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** មែនហើយ អ៊ីចឹងហើយ។

**ស៖** តើលោកនៅចាំទេ ថាគេរំដោះក្រុងឧដុង្គហ្នឹងរំដោះនៅពេលណា ដោយកាលបរិច្ឆេទផង បើលោកចាំ?

[១០:២២:៥២]

**ឆ៖** ខ្ញុំមិនចាំថ្ងៃទេ ប៉ុន្តែខ្ញុំចាំក្នុងខែ៤៧។ ចាប់ពីវៃសម្រុកតាំងពីខែ១ មក ប៉ុន្តែដល់ខែ៤ ហ្នឹង បាន១រំដោះ។ ប៉ុន្តែដល់ខែ៧ មកយកវិញ។

**ស៖** តើលោកចង់និយាយថា ខែមេសា ឆ្នាំ១៩៧៥ឬ?

**ឆ៖** ខ្ញុំចង់និយាយ ៧៤ ព្រោះរំដោះឧដុង្គហ្នឹងគឺថា ៧៤។

**ស៖** ចាតើប្រជាជនដែលនៅក្នុងក្រុងឧដុង្គហ្នឹង នៅពេលដែលគេរំដោះ ពេលដែលកងទ័ពបក្ស កម្មុយនីស្តកម្ពុជារំដោះ គេចាត់ការម៉េចចំពោះប្រជាជនហ្នឹង?

[១០:២៤:០៣]

**ឆ៖** ខ្ញុំចូលទៅស្ងាត់ជ្រាប អត់មានប្រជាជនទេ ស្ងាត់ជ្រាបតែម្តង។ ដល់ឃើញគាត់នែ៎ -- ភាគច្រើនបើខាងលិចទន្លេគឺថា មកតាមផ្លូវអមលាំងហ្នឹង ផ្លូវអមលាំង នែ៎អមលាំង ត្រពាំងជោរឱរ៉ាល់ ហ្នឹង គាត់មកផ្លូវនុ៎ងច្រើន។ ហើយមកក្បែរ១ហ្នឹង គឺថាគ្រាន់តែចេញពីទីរួម -- ទីប្រជុំជនហ្នឹងគាត់នៅ ចូលតាមភូមិគេនៅក្បែរ១ហ្នឹង ហើយនិងមួយចំនួនហ្នឹង គឺមកតាមផ្លូវហ្នឹង។

**ស៖** ចាតើរយៈពេលឆាប់ប៉ុនណាដែលលោកធ្វើដំណើរមកទីក្រុងហ្នឹងក្រោយពីរំដោះឧដុង្គរួច មកនោះ?

[១០:២៥:០០]

**ស៖** តាមខ្ញុំចាំ ជិតមួយអាទិត្យដែរ ពីព្រោះទីប្រជុំហ្នឹងយើងរំដោះហ្នឹងហើយ ប៉ុន្តែដែល ទាហានហ្នឹង ទាហាន លន់ នល់ ហ្នឹងគឺថានៅក្រាញនៅកន្លែង គេហៅនៅវិទ្យាល័យទេពប្រណម្យ ហ្នឹង។ វៃកន្លែងហ្នឹង ហើយឈ្នះអស់ហ្នឹង នៅកន្លែងហ្នឹង គឺវៃមួយអាទិត្យទៀតបានឈ្នះ។ ក្រាញ

ជាងគេ គឺក្រាញនៅវត្តទេពប្រណម្យហ្នឹងឯង។ កន្លែងហ្នឹងវាជាប់វត្តពេក វាជាប់វិទ្យាល័យទេពប្រណម្យហ្នឹងផង។ វាក្រាញកន្លែងហ្នឹង។

[១០:២៥:៥៧]

**ស៖** ចាតើលោកទៅជាមួយអ្នកណានៅពេលដែលលោកធ្វើដំណើរកាត់តាមក្រុងឧដុង្គ គឺថាមួយសប្តាហ៍ក្រោយពីរំដោះនោះ។

**ឆ៖** ខ្ញុំទៅម្នាក់ឯងទេ ដែលថា ខ្ញុំបញ្ជាក់កន្លងមក ខ្ញុំមានម៉ូតូមួយ ខ្ញុំទៅម្នាក់ឯងទេ។ អត់មានគ្នាច្រើនទេ ក្រុមខ្ញុំនោះ។

**ស៖** លោកបាននិយាយថា លោកនៅមន្ទីរប-៥ នៅពេលដែលគេរំដោះនោះ។ តើមេដឹកនាំបក្សនៅមន្ទីរប-៥ ដែរឬទេនៅពេលនោះ ដែលលោកនៅមន្ទីរប-៥ នោះ?

**ឆ៖** គាត់នៅដែរតើ! គាត់នៅ នៅអចិន្ត្រៃយ៍។

**ស៖** ចាតើអ្នកណាខ្លះនៅមន្ទីរនោះ នៅពេលដែលលោកថានៅនោះ?

**ឆ៖** ជំនាន់នុំង ជាអចិន្ត្រៃយ៍មានតែអ៊ំ ប៉ុល ពត ហ្នឹងហើយកាលហ្នឹង នៅតែគាត់ទេ។ ចង់បញ្ជាក់បន្តិច ត្រង់ហ្នឹងគឺថា គាត់នៅប-៥ ហ្នឹង គឺថាគាត់ចាត់ឲ្យខ្ញុំទៅមើលផ្លូវហ្នឹង ដើម្បីឆ្លងមកៗស្ទឹងត្រង់វិញ មកតាមផ្លូវហ្នឹង។ អង្កាល់ហ្នឹង គឺគាត់ចាត់អ៊ីចឹង។

[១០:២៧:៥១]

**ស៖** មូលហេតុដែលលោកបានចាកចេញពី ប-៥ ឆ្លងកាត់តាមឧដុង្គទៅស្ទឹងត្រង់ ដោយសារប៉ុល ពត ចាត់តាំងឲ្យលោកធ្វើដូច្នេះ តើអ៊ីចឹងឬ?

**ឆ៖** អ៊ីចឹងហើយ មែនហើយ។

**ស៖** ចាតើហេតុអីបានជា ប៉ុល ពត ចង់ឲ្យលោកចេញដំណើរមកឧដុង្គ ហើយទៅស្ទឹងត្រង់? តើគាត់ចង់ឲ្យលោកពិនិត្យមើលអ្វី ឬក៏ពិនិត្យសភាពការណ៍អ្វី?

**ឆ៖** គាត់ចាត់ឲ្យខ្ញុំមកតាមហ្នឹង គឺថាទី១ ទៅមើលសភាពការណ៍តាមហ្នឹង តាមផ្លូវហ្នឹងហើយទី២ គឺថាយកសារមួយទៅឲ្យ កុយ ធួន ដែរ។ កុយ ធួន នៅ -- អង្កាល់ហ្នឹងនៅ នៅភ្នំបាធាយអង្កាល់ហ្នឹង។ កុយ ធួន គាត់នៅប្រចាំ -- នៅចាំនៅហ្នឹង។ ឲ្យសារទៅឲ្យគាត់នៅនុំង។

[១០:២៩:០៩]

**ស៖** បន្ទាប់ពីលោកបញ្ចប់ភារកិច្ចហ្នឹង តើលោករាយការណ៍ទៅ ប៉ុល ពត វិញអំពីស្ថានភាព

ឬស្ថានការណ៍ដែលលោកបានធ្វើឃើញទេ?

**ឆ៖** ខ្ញុំទៅដល់ទិសដៅ អ៊ីចឹងហើយ ទៅដល់ជួប កុយ ធួន ហ្នឹងហើយ។ ខ្ញុំហួសទៅស្ទឹងត្រង់ទៅ -- មានសំបុត្រមួយទៀត នាំសំបុត្រហ្នឹងជូនអ៊ំ នួន ជា នៅ -- អង្គាល់ហ្នឹងគាត់នៅនេះ នៅមន្ទីរគេហៅ មន្ទីរ៧៤ទេ។ យកឯកសារហ្នឹងឲ្យគាត់។

**ស៖** ថាតើមន្ទីរ៧៤ ឬក៏ ស-៧៤នោះ តើមន្ទីរហ្នឹងមានមុខងារសំខាន់ ឬក៏មន្ទីរអ្វី?

[១០:៣០:០០]

**ឆ៖** មន្ទីរ ស-៧១ នោះវាជិតស្ទឹងជីនិត ដល់មន្ទីរ ៧៤ នេះវានៅមាត់ទន្លេឯនេះ ជិតទៅមាត់ទន្លេនៅស្ទឹងត្រង់តែម្តង នៅភូមិមាយនេះ។ ភូមិមាយ ចន្លោះភូមិមាយ ហើយភូមិដីក្រហមនេះ គេហៅមន្ទីរ ៧៤ ហ្នឹង គឺនៅត្រង់ហ្នឹង។ នៅកៀកទីរួមស្រុកស្ទឹងត្រង់តែម្តង។

**ស៖** ខ្ញុំចង់សួរលោកឥឡូវនេះ អំពីចម្លើយដែលយើងទទួលបានពីលោក នៅក្នុងបទសម្ភាសន៍ពីមុន គឺថាច្រើនឆ្នាំមុនពេលដែលលោកជួបជាមួយសហចៅក្រមស៊ើបអង្កេត។ នៅក្នុងទីមួយ តើលោកនៅចាំដែរឬទេ ថាមានគេសម្ភាសដោយអ្នកសារព័ត៌មានអង់គ្លេស ហើយនិងលោក ហ្វីលីព ស្បូត ក្រោយកមកគេយកមកបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩០ ហើយនិងឆ្នាំ២០០០ តើលោកនៅចាំថា អ្នកសារព័ត៌មានអង់គ្លេសម្នាក់ឈ្មោះ ហ្វីលីព ស្បូត បានទៅសម្ភាសលោកដែរឬទេ?

**ឆ៖** បាទ គាត់មកសម្ភាសមែន ពេលនុ៎ង។ បានឲ្យឯកសារ ឲ្យខ្ញុំដែរ ជាភាសា -- ភាសាអង់គ្លេស ឬបារាំង ខ្ញុំមិនចាំទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បី បន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលយើងសម្រាក មុនសម្រាកនោះ យើងបាននិយាយអំពីការជម្លៀសនៅក្រុងឧដុង្គ ហើយលោកបានបញ្ជាក់ប្រាប់តុលាការថា លោកបានចាំថា លោក ហ្វីលីព ស្សូត បានសម្ភាសលោក។

លោកប្រធានឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចង់បង្ហាញជូនឯកសារជូនសាក្សីនូវសេចក្តីដកស្រង់សៀវភៅរបស់ ហ្វីលីព ស្សូត ដែលមានសេចក្តីដកស្រង់ចេញពីសាក្សីរូបនេះ។ ឯកសារនោះ គឺ E3/9។ អង់គ្លេស ERN 00396465, បារាំង ERN 00639786, ខ្មែរ ERN 00755582 ហើយខ្ញុំមានឯកសារលើក្រដាសជូនសាក្សី ដើម្បីអាន ហើយនិងសូមអនុញ្ញាតតុលាការដើម្បីបង្ហាញឯកសារនេះលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

[១១:៥៥:៤១]

**លោក អាកទ្សួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំសូមជំទាស់ទៅនឹងរបៀបដែលសហព្រះរាជអាជ្ញាធ្វើនេះ។ ខ្ញុំមិនមែនធ្វើការជំទាស់នេះ ដោយសារការផ្តល់លេខយោងដែលនាំមុខនោះទេ។ ពីព្រោះថា យើងដឹងហើយ ថាសាក្សីនេះអាចអានឯកសារមុននឹងចូលមកទីនេះ។ ប៉ុន្តែផ្ទុយទៅវិញ វាហាក់ដូចជាសហព្រះរាជអាជ្ញា កំពុងតែរំឭកការចងចាំសាក្សី ដោយនិយាយអំពីសៀវភៅរបស់លោក ហ្វីលីព ស្សូត

ដោយមិនបានសុំឲ្យគាត់បញ្ជាក់ជាមុន អំពីចំណុចដែលសហព្រះរាជអាជ្ញាចង់ចោទសំណួរ។ ដូច្នេះ ខ្ញុំសូមជំទាស់ ព្រោះថារបៀបធ្វើនេះ វាមានលក្ខណៈនាំមុខ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាមានអីឆ្លើយតបទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា ដែរឬទេ?

[១០:៥៧:០២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការឆ្លើយតប។ មិនមែនជាការសួរនាំមុខនោះទេ អំពីសំណួរនេះនោះ។ សាក្សីលោកបានបញ្ជាក់ហើយ ថាគាត់បានដឹងអំពីការជម្លៀសក្រុងឧដុង្គ ហើយគាត់បាននិយាយពីបញ្ហានេះ។ សៀវភៅនេះ មានសេចក្ដីដកស្រង់ចេញពីសាក្សីរូបនេះ ដែលបំភ្លឺបន្ថែមអំពីរឿងនេះ។ ហើយខ្ញុំយល់ថា អាចនឹងសមស្រប ដើម្បីនឹងឲ្យសាក្សីបំភ្លឺបន្ថែម ហើយខ្ញុំប្រើសេចក្ដីដកស្រង់ពីសៀវភៅនេះ ដែលតុលាការបានទទួលយកហើយ។ ដើម្បីផ្ដល់សេចក្ដីលម្អិតអំពីហេតុការណ៍ជម្លៀសនៅឧដុង្គនោះបាទ។

[១០:៥៧:៥២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៩:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ ហើយសេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់ ដែលធ្វើឡើងដោយមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន ធ្វើឡើងមិនមានមូលដ្ឋានសមស្របទេ។ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះចាំបាច់ត្រូវការស្ដាប់ចម្លើយរបស់សាក្សីតបទៅនឹងសំណួរ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យមុនពេលតាំងសំណួរសួរដេញដោលអំពីបញ្ហានេះ។

**លោក ឌេល លីសាក់៖**

ឥឡូវនេះ លោកប្រធានយើងបានសេចក្ដីដកស្រង់បញ្ហាលើអេក្រង់រួចហើយបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីនៅពេលដែលលោកកំពុងអានឯកសារនេះ ខ្ញុំសូមអានដើម្បីតុលាការកត់ត្រានូវផ្នែកដែលពាក់ព័ន្ធ ដែលខ្ញុំចង់សួរលោកអំពីសៀវភៅរបស់លោក ហ្វីលីព ស្សូត ផ្នែកនោះដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

[១១:០១:៣៦]

សូមដកស្រង់៖ “នៅទីបំផុត នៅខែមីនា ឆ្នាំ១៩៧៤ មានការជម្លៀសប្រជាជនចេញពីឧដុង្គ។ តាមសម្ដីរបស់ជំនួយការរបស់ ប៉ុល ពត។ ភី ភួន និយាយថា វាដំណើរការយ៉ាងរលូនក្នុងន័យមួយដែលថា មិនមានបញ្ហាធំដុំអ្វីចំពោះពួកយើងក្នុងការជម្លៀសប្រជាជនចេញពីឧដុង្គឲ្យទៅរស់នៅជនបទទេ។ ហើយចំពោះពួកគេវិញ ពួកគេរស់នៅទីក្រុងក៏មិនបានបង្កឲ្យមានការលំបាកអ្វីខ្លាំងណាស់ដែរ។ នេះគឺជាដំណោះស្រាយដំបូង ដែលត្រូវបានផ្ដើតដើម្បីទប់ទល់នឹងការប៉ុនប៉ងណាមួយពីសំណាក់ខ្មាំងសត្រូវដើម្បីធ្វើឲ្យជ្រួលច្របល់ដល់កងកម្លាំងរបស់យើង ហើយជាមួយគ្នានេះដែរ វាក៏ជាវិធានការផ្ទៃក្នុងដែរ។ ហើយវាមានហានិភ័យដែលទាក់ទងទៅនឹងបញ្ហានយោបាយ ប្ដូរនយោបាយ និងមនោគមន៍វិជ្ជា។ ពួកគេអាចនឹងមានឥទ្ធិពលលើបរិស្ថានថ្មីនៃទីក្រុង ប្រសិនបើពួកគេរស់នៅក្នុងទីក្រុងត្រូវបានជម្លៀសនោះ។ គ្រោះថ្នាក់ប្រភេទនេះអាចនឹងចៀសផុត។ អ្នកត្រូវយល់ថា គោលចុងក្រោយរបស់យើង គឺរំដោះក្រុងភ្នំពេញ។ ហើយសម្រេចគោលដៅនេះ ពួកយើងត្រូវដុសខាត់គោលជំហររបស់យើងទាំងផ្នែកនយោបាយ និងមនោគមន៍វិជ្ជា។ បើមិនដូច្នោះទេ កម្មាភិបាលរបស់យើងនឹងចៀសផុតពីគ្រាប់កាំភ្លើង ស្រោបដោយស្ករពីខាងក្រៅនោះទេ”។ សំណួរ ថាតើលោកយល់ថានេះជាសេចក្ដីដកស្រង់ចម្លើយត្រឹមត្រូវដែលលោក ហ្វីលីព ស្សូត សួរលោកអំពីការជម្លៀសទីក្រុងភ្នំពេញនោះ -- ឧដុង្គនោះដែរឬទេ?

[១១:០៣:២៤]

**លោក វ៉ាចាម តុន៖**

**ឆ៖** គាត់បានសួរ ហើយខ្ញុំបានឆ្លើយប្រាប់គាត់ពិតអ៊ីចឹងមែន។

**ស៖** នៅពេលដែលលោកនិយាយថា គោលបំណងនៃការជម្លៀសក្រុងឧដុង្គនោះ គឺដើម្បីកុំឲ្យខ្មាំងមាន -- ប៉ុនប៉ងធ្វើឲ្យកងទ័ពយើងខ្សោយនោះ ហើយដើម្បីៗកុំឲ្យកម្មាភិបាលរងឥទ្ធិពលនយោបាយ ឬក៏មនោគមពីអ្នកក្រុង។ តើលោកដឹងពីគោលបំណងនៃការជម្លៀសទីក្រុងឧដុង្គបែបនេះ? តើលោកដឹងពីអ្នកណា?

[១១:០៤:៣២]

**ឆះ** ដូចខ្ញុំបានបញ្ជាក់ពីព្រឹកមិញថា គឺខ្ញុំដឹងនោះ ដឹងតាមរយៈដែលគាត់ឧទ្ទេសនាមប្រាប់ក្នុងអង្គប្រជុំមួយៗ ឬវគ្គរៀនសូត្រមួយៗ ដូចអ៊ំ ប៉ុល ពត ក៏ដោយ អ៊ំ នួន ជា ក៏ដោយ, អ៊ំ ខៀវ សំផន ក៏ឧទ្ទេសនាមជាពិសោធន៍ល្អៗ ដើម្បីយើងឈានទៅរំដោះភ្នំពេញក៏យើងធ្វើ យកពិសោធន៍នេះល្អតទៅទៀត។ ខ្ញុំដឹងតាមរយៈអ៊ីចឹង រយៈអប់រំរួមហ្នឹង។

**សះ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់សួរលោក សំណួរមួយចំនួនទៀត អំពីការប្រជុំធំៗនៅឆ្នាំ ១៩៧១ ហើយនិងឆ្នាំ១៩៧៤ ដែលលោកបានជម្រាបទៅសហព្រះរាជអាជ្ញាជាតិពីខាងដើមនេះ។ មុនដំបូងហ្នឹង ការប្រជុំនៅឆ្នាំ១៩៧១ លោកនិយាយថា “ការប្រជុំហ្នឹងមានពីរផ្នែក។ ផ្នែកទីមួយនោះ គឺការប្រជុំនៅខាងឧត្តរ មន្ទីរនៅឧត្តរសម្រាប់កម្មភិបាលស្រុក និងតំបន់”។ ហើយបន្ទាប់មកលោកនិយាយថា “មានការប្រជុំរវាងមេដឹកនាំនៅថ្នាក់មជ្ឈិមហើយនិងថ្នាក់តំបន់”។ ហើយខ្ញុំនឹងផ្តល់ទៅលើការប្រជុំទីពីររវាងគណៈមជ្ឈិម ហើយនិងមេដឹកនាំតំបន់ -- មេដឹកនាំភូមិភាគ។ ថាតើលោកវត្តមាន ហើយលោកនៅកន្លែងណានៅពេលដែលលោកយាមការប្រជុំនោះបាទ?

[១១:០៦:៣២]

**ឆះ** ខ្ញុំបាទបានបញ្ជាក់ព្រឹកមិញខ្លះហើយចំណុចនេះ គឺថាប្រជុំហ្នឹង គឺថានៅមន្ទីរ មន្ទីរជិតភូមិត្រពាំងព្រៃ គេហៅថា ភូមិត្រពាំងព្រៃ ទៅពីភូមិត្រពាំងទៅបន្តិចទៅ នៅក្នុងព្រៃហ្នឹង។ អាហ្នឹង ខ្ញុំឃើញប្រជុំហ្នឹង គឺថាឃើញសមាជិកក្នុងភូមិភាគមួយៗ មានសមាជិកប៉ុន្មានចូលរួមទាំងអស់។ ហើយខ្ញុំថា ខ្ញុំថាប្រជុំពេលហ្នឹងមិនយូរប៉ុន្មានទេ មិនដល់១០ថ្ងៃទេ អ៊ីចឹង។ ហើយពេលហ្នឹងដែលៗ ប្រជុំពេលហ្នឹងព្រោះថាខ្ញុំនៅហ្នឹងដែរ ខ្ញុំយាមកាមនុំងដែរ។ បាទ ខ្ញុំយាមតែហ្នឹង បានថាខ្ញុំ ដូចខ្ញុំបានជម្រាបជាហូរហែមកថា ខ្ញុំក្តាប់គាត់ប្រជុំហ្នឹង គឺថាខ្លឹមសារវាប្រហែលៗគ្នាទាំងអស់។ សូម -- ប្រជុំធំក៏ដូចគ្នា ប្រជុំថ្នាក់តំបន់ ថ្នាក់ស្រុក ក៏ដូចគ្នា ប្រហែលៗគ្នាទេ។

[១១:០៧:៥០]

**សះ** ថាតើអ្នកណាជាមេដឹកនាំមកពីមជ្ឈិមបក្ស ដែលវត្តមាននៅក្នុងការប្រជុំនោះ?

**ឆះ** ប្រជុំពេលហ្នឹងគឺថា មានអ៊ំ ប៉ុល ពត, អ៊ំ នួន ជា ប្រជុំពេលហ្នឹង។ ហើយភូមិភាគ៣០៤ ហ្នឹង គឺថាមាន កុយ ធួន, មាន កែ ពក, មាន ឌឿន។ ភូមិភាគ២០៣នេះមាន សោ ភឹម, មាន តាភួង, មាន តាទុំ ហ្នឹងបូព៌ា។ ឯភូមិភាគពិសេសនេះ ឃើញ វន វេត។ ភូមិភាគនិរតីហ្នឹង គឺមាន តាម៉ុក ហើយ

និង តាចុង ហើយនិង តាស៊ី។ ហើយភូមិភាគពាយ័ព្យនេះ មាន រស់ ញឹម, មាន តាគឹ, មាន តាខ្ពិល។ ហើយនិងខាងតំបន់ គេហៅតំបន់ ១០៣ នៅព្រះវិហារហ្នឹង គឺថា បងម៉ាន គាត់មកចូលរួមដែរ អាហ្នឹង។ ហើយភូមិភាគព្ឈិសាន ក៏មានដែរមាន យ៉ា, មាន បងវ៉ង់។ ហើយនៅមណ្ឌលគិរីមាន បងឡាំង អ៊ីចឹង មកចូលរួមដែរ។ អាហ្នឹងអ៊ីចឹង។

**ស៖** តើលោក ខៀវ សំផន វត្តមាននៅក្នុងការប្រជុំនោះទេ?

**ឆ៖** ប្រជុំកាលហ្នឹង ដូចខ្ញុំដូចចន្លោះ ទេគាត់មិនបាន -- ដូចអត់បានឃើញគាត់ទេ កាលហ្នឹង។ គាត់កាលហ្នឹង គាត់នៅមន្ទីរស-៧១ កាលហ្នឹង។ នៅម្ខាងស្ទឹងម្នាក់ ហ្នឹងគឺថាមួយខាងកើតស្ទឹងជីនិត មួយនៅខាងលិចស្ទឹងជីនិត។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនឯកសារនូវរូបថតមួយចំនួន ដែលតុលាការបានទទួល រួចហើយអំពីគំនិតមួយ ដើម្បីថាតើសាក្សីនៅចាំរូបថតនោះដែរឬទេ? អ្វីដែលខ្ញុំចង់បង្ហាញជូនសាក្សីនោះ គឺរូបថត E3/136, E3/137 ហើយ E3/1595។

[១១:១១:០១]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសជូនទៅសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:១១:៥៧]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី មុននឹងខ្ញុំសួរសំណួរជាក់លាក់ទៅលោកនោះ ហើយខ្ញុំបានបង្ហាញឯកសារ លើអេក្រង់លើនេះ ខ្ញុំចង់សួរថាតើលោកស្គាល់ទីតាំងនៃកន្លែងថតរូបនេះដែរឬទេ? ដូចដែលលោកឃើញ រូបថតនេះៗ ហើយតើលោកធ្លាប់បានឃើញទីតាំងដែលគេថតរូបនេះពីមុនមកទេ?

**លោក រ៉ចាម តុន៖**

**ឆ៖** រូបថតនៃ ១៣៦ នេះគឺថតសន្និបាតដែលនៅ ខ្ញុំថាអំមិញហ្នឹង នៅៗ៧១ហ្នឹង គឺជិតភូមិ ត្រពាំងព្រៃហ្នឹង នេះរូបថតនេះ។ ព្រោះអានេះវាមានក្តារក្រាលនេះ ខ្ញុំចាំមានក្តារក្រាល នៅលើនេះ កន្លែងគណៈអធិបតីហ្នឹងគេមានក្តារក្រាលអ៊ីចឹងមែន។ ដល់ ១៣៧ នេះ មិនច្បាស់ៗ ប៉ុន្តែរូប ដែល

E1/97.1

ឃើញរូបន៉ែ ម៉ាក្ស, អង់ហ្គែល, ឡេនីន, ស្តាលីន នេះន៉ែៗ ឃើញមានដែរ មានអ៊ីចឹងដែរ។

ដែលរូបថតដែល ១៩៩៥ នេះ អានេះៗអត់ច្បាស់ទេ វាអត់ច្បាស់ទៀត។ ប៉ុន្តែចំណាំបាន ដំបូលៗស័ង្កសី ប្រហែលៗគ្នា ប៉ុន្តែថតនៅកន្លែងនុ៎ងហ្នឹងឯង រូបថតហ្នឹងថតនៅកន្លែងហ្នឹង កន្លែងប្រជុំហ្នឹងហើយ។ ទាំងបីហ្នឹងកន្លែងហ្នឹងទាំងអស់ ព្រោះមួយខ្ញុំចាំកន្លែងអាក្រាលនែ... គណៈអធិបតី ក្រាលក្តារ។ ដល់មួយទៀត ខ្ញុំចាំកន្លែងន៉ែ ប្រក់ស័ង្កសីពីលើ អ៊ីចឹង។ ពីរហ្នឹងច្បាស់ ប្រក់ស័ង្កសីពីលើ អ៊ីចឹង។

[១១:១៤:៣៣]

**សៈ** តើនៅចាំទេ អ្នកណាជាអ្នកថតរូបហ្នឹង?

**ឆៈ** ថតរូបនៅពេលនោះមានតែបង ប៉ង់ ទេ បងប៉ង់ ព្រោះបង ប៉ង់ គាត់នៅនុ៎ងដែរ។ អ្នកថតរូបមានតែគាត់ហ្នឹងមួយ អត់មានពីណាក្រៅពីហ្នឹងទេ។

**សៈ** សូមលោកត្រឡប់ទៅរករូបថតមួយគឺថា E3136។

**លោក ឌេល លីសាក់៖**

សូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញនៅលើអេក្រង់។ ហើយច្បាប់ដែលយើងអាចបង្ហាញលើអេក្រង់ហ្នឹង គឺយើងដាក់លេខទៅលើរូបមួយចំនួន ដើម្បីឲ្យសាក្សីលោកអាចងាយបញ្ជាក់ទៅតាមលេខណានៅចំមនុស្សណា ហើយដើម្បីឲ្យលោកសាក្សីគាត់បញ្ជាក់ ហើយខ្ញុំសូមអនុញ្ញាតសូមបង្ហាញរូបថតនេះនៅលើអេក្រង់ ហើយខ្ញុំនឹងជូនរូបថតដែលមានលេខបញ្ជាក់ ដើម្បីភាគី ហើយនិងក្រឡាបញ្ជី ដើម្បីនឹងកត់ត្រាឲ្យបានត្រឹមត្រូវនៅក្នុងប្រតិចារឹកតុលាការ។ ហើយយើងខ្ញុំដាក់លេខនេះ ដើម្បីឲ្យសាក្សីងាយស្រួលក្នុងការបញ្ជាក់សួរថា តើរូបនេះជានរណា? ដើម្បីឲ្យច្បាស់ ទាល់តែដាក់លេខដើម្បីឲ្យគាត់អាចនឹងងាយស្រួលក្នុងការបង្ហាញអត្តសញ្ញាបាទ។

[១១:១៦:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

សាក្សីមិនទាន់បើកក្បាលមីក្រូទេ ចាំៗស្តាប់សំណួរសិនណ៎ា!

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** លោកសាក្សី លោកចាប់ផ្តើម គឺថាមនុស្សដែលឈរនៅជួរខាងក្រោយនៅក្នុងរូបថត E3/136 ហើយសូមលោកកំណត់អត្តសញ្ញាណពួកគាត់ ហើយលោកអាចប្រើលេខដែលដាក់នៅ

តាមមនុស្សម្នាក់ៗនោះ ហើយប្រាប់ថាតើអ្នកនៅជួរខាងក្រោយនោះ តើអ្នកណាខ្លះនៅក្នុងរូបថតនេះតើលោកស្គាល់ទេតាមលេខហ្នឹង? លេខណា អ្នកណាឈ្មោះអ្វីបាទ?

**លោក វ៉ែថាម គុន៖**

**ឆ៖** លេខ១ ហ្នឹងគឺថា អ៊ំ ប៉ុល ពត, លេខ៦ នេះ គឺឈ្មោះ យ៉ា, លេខ៤ នេះអ៊ំ នួន ជា, លេខ៣ នេះ កុយ ធួន, លេខ២ នេះ តាម៉ុក, ហើយលេខ១៤ នេះ សោ ភឹម។ ហើយក្រៅពីហ្នឹងព្រិល ខ្ញុំចាំមិនអស់ទេ។ ចាំចោះៗ។ វាព្រិលអ៊ីចឹង ខ្ញុំមើលអត់ឃើញ។

**ស៖** មនុស្សដែលលោកថា ប៉ុល ពត នោះ តើមនុស្សដែលឈរនៅខាង នៅស្តាំគេបំផុតដែរឬទេនៅក្នុងរូបថត? លោកថាលេខ១ ប៉ុន្តែកន្លែងហ្នឹងលេខ១០ ទេ ប្រហែលជាលោកមើលលេខសូន្យមិនឃើញបាទ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា មិនអាចគប្បីតាំងសំណួរបែបនេះទេ។

បាទ សូមអញ្ជើញលោកមេធាវី!

[១១:១៨:៤៥]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ជាក់ស្តែងនេះ គឺគាត់មិនពេញចិត្តនឹងចម្លើយទេ គឺវិធីសាស្ត្រនេះមិនមែនវិធីសាស្ត្រដែលត្រូវប្រើទេ។ នេះគឺផ្តល់ចម្លើយទៅសាក្សី ដោយគួរឲ្យសោកស្តាយនោះ គឺជាវិធីសាស្ត្រមិនគប្បីយកមកប្រើក្នុងតុលាការនេះទេ ក្នុងគោលបំណងបែបនេះ។ ប្រសិនបើយើងធ្វើបែបនេះ គឺថា បើខាងខ្ញុំធ្វើបែបនេះ គឺថាសហព្រះរាជអាជ្ញានឹងជំទាស់។ ដូច្នេះ សូមឲ្យសាក្សីចង្អុលបង្ហាញតើអ្នកណាបន្ទាប់អ្នកណា ហើយដែលសហព្រះរាជអាជ្ញាសួរនេះ គឺមិនត្រឹមត្រូវទាល់តែសោះ ខុសនីតិវិធីបាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** យើងនិយាយអំពី ប៉ុល ពត គឺថា យើងឃើញថា មានចម្រូងចម្រាស ហើយសាក្សីមិនបានឃើញលេខទាំងស្រុងទេ នៅពេលដែលគាត់កំណត់អត្តសញ្ញាណ។ ដូច្នេះហើយសាក្សីលោកច្បាស់ណាស់អំពីរូបនេះ។ នេះហើយបើសិនជាបញ្ហា នេះចម្រូងចម្រាសខ្លាំង ខ្ញុំនឹងសួរឲ្យសាក្សីបំភ្លឺ។ ហើយខ្ញុំសួរថាតើមនុស្សដែលសាក្សីថា ប៉ុល ពត ហ្នឹង គាត់ឈរនៅកន្លែងណាក្នុងរូបថត? ខ្ញុំនឹងសួរបែបនេះ

វិញបាទ។

[១១:១៩:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីអាចឆ្លើយតបទៅនឹងសំណួរបែបនេះបាន។

**លោក វ៉ាចាម តុន៖**

**ឆ៖** ប៉ុល ពត នៅៗលេខ១០។ យ៉ា នោះនៅលេខ៦។ អ៊ំ នួន ជា លេខ៤។ កុយ ធួន លេខ៣។ សោ ភឹម នោះលេខ១៤។ ហើយក្រៅពីហ្នឹង ខ្ញុំអត់ចាំទេ ព្រោះវាព្រិល ក្នុងនេះវាអត់ឃើញច្បាស់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ យើងត្រឡប់ទៅរូបថតមួយសន្លឹកទៀត E3/5095 បាទជារូបថតហ្នឹង គឺ E3 595 ហើយសូមឲ្យលោកពិនិត្យមើល ហើយខ្ញុំនឹងសួរ។ ប៉ុន្តែខ្ញុំសូមឲ្យលោកមើលរូបនៅខាង ជួរខាងក្រោយ ថាតើលោកអាចជម្រាបតុលាការបានដែរឬទេ មនុស្សដែលមានតួលេខ ១១ បាទ តើគាត់ហ្នឹងឈ្មោះអ្វី? ជាអ្នកណា? បាទគឺនៅ E3/1595។

**ឆ៖** លេខប៉ុន្មាន? លេខ១១ ហ្នឹងដូចជា អ៊ំ ខៀវ សំផន ដូចមិនច្បាស់ណ៎ា។ ពិបាកមើលណាស់ក្នុងរូបនេះ ពិបាកៗមើលណាស់ វាអត់ច្បាស់។

[១១:២២:៥៩]

**ស៖** សូមអរគុណ។ ហើយៗខ្ញុំនឹងចង់បានរូបថតឲ្យច្បាស់ជាងនេះ តែយើងមិនអាចឲ្យច្បាស់ជាងនេះទេ ហើយនៅក្នុងរូបថតនេះ តើលោកធ្លាប់ឃើញរូបថតដូចគ្នានេះ ឬស្រដៀង -- ដូចគ្នានេះនៅកន្លែងណាផ្សេងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានតាមដានមិនដឹងនៅៗកន្លែងណាទេ។ អានេះគ្រួសារអ៊ំ ប៉ុល ពត លេខ៣៥ នេះឃើញ។ អានេះច្បាស់ គាត់ហ្នឹង។ លេខ៣៥ហ្នឹង។

**ស៖** ហើយលោកមើលរូបថតនេះ តើលោកអាចប្រាប់ខ្ញុំបានទេ នៅឆ្នាំ១៩៧១ នេះថាតើគេប្រជុំនៅពេលណា នៅក្នុងឆ្នាំ១៩៧១នោះ លោកចាំខែដែរឬទេ?

[១១:២៤:៣០]

**ឆ៖** កាលហ្នឹង គឺខែហ្នឹងគឺខែភ្លៀងៗកាលនុ៎ង។ ភ្លៀងខ្លាំងដែរ ដូចចន្លោះខែ៧ ខែ៨ហ្នឹង តាមមើល ភ្លៀងខ្លាំងកាលនុ៎ង។

**ស៖** សូមអរគុណ។ ហើយខ្ញុំមានសំណួរបន្ថែមទៀតអំពីរូបថតនេះ បាទ ប៉ុន្តែឥឡូវនេះ ខ្ញុំចូល

ទៅប្រធានបទផ្សេងមួយ ដែលអំពីការប្រជុំធំដែលលោកប្រាប់ទៅសហព្រះរាជអាជ្ញាជាតិព្រឹកមិញនេះ គឺការប្រជុំនៅឆ្នាំ១៩៧៤។ សំណួរដំបូងដែលខ្ញុំចង់សួរលោកនោះ ថាតើការប្រជុំនៅឆ្នាំ១៩៧៤ នោះ ធ្វើឡើងនៅកន្លែងដដែល ដូចដែលគេធ្វើនៅក្នុងឆ្នាំ១៩៧១ ឬក៏គេប្រជុំនៅកន្លែងផ្សេង?

**ឆ៖** ៧៤ ហ្នឹង គឺទីតាំងហ្នឹងឆ្ងាយពីគ្នា ទីតាំងទីមួយវានៅជិតស្ទឹងជីនិតឯណោះ។ ប៉ុន្តែទីតាំង ៧៤ នេះ វានៅមាត់ទន្លេមេគង្គឯណោះ ជិតស្រុកស្ទឹងត្រង់ នៅភូមិ -- គេហៅភូមិមាយ ខាងលើបន្តិច គេហៅភូមិដីក្រហមចន្លោះហ្នឹង។ នៅផ្លូវដើងភ្នំហ្នឹង ត្រង់ហ្នឹងវារាងទួលបន្តិច ៧៤ហ្នឹង ខុសគ្នា ទីតាំងខុសគ្នាឆ្ងាយណាស់។

**ស៖** តើមេដឹកនាំបក្សប៉ុន្មាននាក់ដែលបានមកចូលប្រជុំនៅក្នុងការប្រជុំឆ្នាំ១៩៧៤ តើលោកនៅចាំទេ?

**ឆ៖** អង្កាល់ប្រជុំឆ្នាំ៧១ ហ្នឹងច្រើនៗនៅពេលនោះ។ ដល់ប្រជុំ៧៤ តិចទេ។ ប្រជុំ៧៤ តិច។

[១១:២៧:០៦]

**ស៖** តើការប្រជុំនៅឆ្នាំ១៩៧៤ ហ្នឹងគឺរយៈពេលប៉ុន្មានថ្ងៃដែរ លោកនៅចាំទេ?

**ឆ៖** អង្កាល់ហ្នឹងជាងកន្លះខែ មិនដល់មួយខែទេ ជាងកន្លះខែ។

**ស៖** តើលោកនៅចាំទេ ពេលណា នៅក្នុងខែណា នៅក្នុងឆ្នាំ១៩៧៤ ដែលគេប្រជុំគ្នានោះ?

**ឆ៖** ៧៤ ហ្នឹង ឃើញ ក្នុងខែ៧ ខែភ្លៀងដែរ។ ខែ៧។

**ស៖** លោកប្រធាន នៅពេលនេះខ្ញុំសូមជួយឲ្យសាក្សីចងចាំ ហើយឲ្យគាត់បញ្ជាក់ ហើយខ្ញុំចង់បង្ហាញជូនសាក្សីអំពីបញ្ហាទង់បដិវត្ត ជាទស្សនាវដ្ដីខែកញ្ញា ឆ្នាំ១៩៧៧។ ឯកសារ E3/11 ហើយ ERN ដែលខ្ញុំយោងហ្នឹង ខ្មែរERN 00063162, អង់គ្លេស ERN 00486247, បារាំង ERN 00492836 ហើយខ្ញុំមានឯកសារលើក្រដាសជូនសាក្សីដែលទាក់ទង។ ហើយនិងសុំអនុញ្ញាតបង្ហាញឯកសារលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្ដីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ មុនចូលទៅដល់ការបង្ហាញនោះ ប្រហែលជាសហព្រះរាជអាជ្ញាចង់បង្ហាញមូលដ្ឋានដែលថា សាក្សីនេះប្រហែលជាមិនអាចបានឃើញទង់បដិវត្តនោះទេ គឺថា បើសិន

បង្ហាញខ្លឹមសារដើម្បីឲ្យគាត់មានការចងចាំ ឬក៏ចង់ឲ្យសាក្សីផ្តល់សុពលភាព ហើយនិងឲ្យឆ្លើយនោះ គឺមិនសមស្របទេ គឺទង់បដិវត្តនោះគឺថាបានដាក់ជូនហើយ ប៉ុន្តែមិនគប្បីយកមកប្រើនៅពេលនេះ បើសិនជាតាមពិតសាក្សីមិនបានឃើញឯកសារនេះ ឬក៏មិនបានឮ មិនបានដឹងពីខ្លឹមសារនេះជាមុនទេ។

ដូច្នេះសួរសំណួរមុនហ្នឹង មុននឹងបង្ហាញដើម្បីដូចថាគាត់មានគោលបំណងចង់បង្ហាញមូលដ្ឋានឲ្យសាក្សីឆ្លើយតាមហ្នឹង គឺថាៗ សូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាសួរថាគាត់បានឃើញ ហើយគាត់បានដឹងខ្លឹមសារហ្នឹងជាមុនដែរឬទេ?

**លោក ខេល លីសាក់៖**

មូលដ្ឋានហ្នឹងគឺត្រូវបានបញ្ជាក់ហើយ។ សាក្សីបានបញ្ជាក់ថា មានសមាជិកបក្ស គឺថាបានទទួលទង់បដិវត្ត ក្រោយពីរំដោះរួចមកនោះ។ ហើយលើសពីហ្នឹង ខ្ញុំចង់សួរគាត់ជាក់លាក់អំពីខ្លឹមសារយោងទៅរកការប្រជុំរបស់គណៈមជ្ឈិម ពាក់កណ្តាលឆ្នាំ១៩៧៤ ហើយលើសពីហ្នឹងទៀត គាត់បានបង្ហាញថា គាត់វត្តមាននៅក្នុងការប្រជុំរបស់មជ្ឈិមបក្ស។ ហើយខ្ញុំចង់ឲ្យគាត់បញ្ជាក់ថាតើការប្រជុំដែលយើង -- ដែលបញ្ជាក់នៅក្នុងទង់បដិវត្តនោះ ថាតើជាការប្រជុំដែលគាត់បានផ្តល់សក្ខីកម្មចំពោះតុលាការថ្ងៃហ្នឹងដែរឬទេ?

[១១:៣១:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោកអៀង សារី មិនមានមូលដ្ឋានសមស្របទេ។ សេចក្តីជំទាស់នោះគ្មានប្រសិទ្ធភាព។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យជាមុនសិន!

លោកតំណាងសហព្រះរាជអាជ្ញាទុកពេលវេលាឲ្យសាក្សីពិនិត្យឯកសារនេះជាមុនសិន យើងនឹងសួរពីបញ្ហាថាតើគាត់បានធ្លាប់ឃើញឯកសារនេះពីមុនដែរឬទេ ដើម្បីយើងដោះស្រាយបញ្ហាឯកសារដែលបង្ហាញចំពោះមុខសាក្សី លុះត្រាតែសាក្សីធ្លាប់បានឃើញនូវទម្រង់ ឬក៏ឯកសាររបៀបនេះពីមុនមក។

[១១:៣៤:៥២]

**លោក ខេល លីសាក់៖**

លោកប្រធាន គឺការបកប្រែជាភាសាអង់គ្លេស គឺថាលោកប្រធាននឹងសួរសំណួរមួយចំនួនជាមុនសិន ទៅកាន់សាក្សី។ តើពិតជាត្រឹមត្រូវដែរឬទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីតើឯកសារដែលលោកអានអម្បាញ់មិញនេះ លោកធ្លាប់បានឃើញ ឬក៏បានអានទេនៅក្នុងអំឡុងពេលដែលគាត់ -- ដែលលោកធ្វើការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្រោយមកទៀតនោះ?

**លោក វ៉ាចាម គុន ៖**

បានឃើញខ្លះដែរ។ កន្លែងគូសនេះ ក្នុងខែ១ មិថុនា។ សន្និបាតរបស់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៤។ បានមើលដែរ ឯកសារ ប៉ុន្តែវាមិនចាំទេ ឯកសារវាច្រើន ក៏បានមើលខ្លះដែរ។

[១១:៣៦:១៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីបានហើយ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួរដែលខ្ញុំចង់សួរទៅកាន់លោកសាក្សីនោះ គឺថា ទស្សនាវដ្ដីទង់បដិវត្ត នៅក្នុងនោះបាននិយាយអំពីការប្រជុំរបស់គណៈមជ្ឈិម ប្រជុំឡើង --ប្រជុំនៅខែមិថុនា ឆ្នាំ៧៤ ដែលសរសេរថែងដូចតទៅ៖ “គណៈមជ្ឈិមក្នុងសន្និសីទ ខែមិថុនា ឆ្នាំ៧៤ -- សន្និបាត ខែមីនា ឆ្នាំ៧៤ គឺតម្រូវឲ្យមានការជម្លៀសទីក្រុងភ្នំពេញចេញឲ្យអស់ រំដោះទីក្រុងភ្នំពេញ”។ ខ្ញុំសូមសួរលោក តើលោកនឹកឃើញដែរឬទេថាមានកិច្ចប្រជុំធំមួយ នៅក្នុងឆ្នាំ៧៤ ដែលនិយាយអំពីការរំដោះនោះ ទីក្រុងភ្នំពេញ? ហើយលោកបាននិយាយថា ការប្រជុំនោះ គឺក្នុងខែកក្កដា ហើយពេលវេលានោះ ហាក់ដូចជាវានៅកៀកៗគ្នា។ ដូច្នេះហ្នឹងជាការប្រជុំហ្នឹងមែនដែរឬទេ? ឬក៏មិនមែនជាការប្រជុំដែលលោកលើកឡើងនោះទេ?

[១១:៣៧:៥៣]

**លោក វ៉ាចាម តុន៖**

**ឆ៖** អម្បាញ់មិញ ខ្ញុំឆ្លើយថា ក្នុងខែ៧ ប៉ុន្តែមើលក្នុងឯកសារនេះ ដាក់ក្នុងខែ៦ ខ្ញុំទទួលស្គាល់ថា ខែ៦ ទៅចុះ ខ្ញុំក៏ភ្លេចភ្លាំងដែរ ចាំមិនអស់ទេ។ ខ្ញុំទៅតាមឯកសារនេះ។ ព្រោះខែនោះ ខែភ្លៀងដូចគ្នាទេ។

**ស៖** តើលោកនឹកឃើញដែរឬទេ មានប្រធានបទ ឬក៏ចំណុចមួយដែលយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំឆ្នាំ៧៤ នោះ ប្រធានបទដែលគេពិភាក្សានោះ គឺពាក់ព័ន្ធទៅនឹងការវាយសម្រុកដើម្បីរំដោះទីក្រុងភ្នំពេញ។ តើអ៊ីចឹងមែនដែរឬទេ?

[១១:៣៨:៤៦]

**ឆ៖** គេមានផ្ដោតទៅការវាយសម្រុករំដោះភ្នំពេញ ពេលនោះ។ ព្រោះនេះៗ គេថាបានរំដោះឧដុង្គរួចហើយ យកពិសោធន៍វាយរំដោះឧដុង្គនេះៗ ដើម្បីឈានទៅរំដោះភ្នំពេញចុងក្រោយនេះ គេមាន។

**ស៖** លោកបានប្រាប់សហព្រះរាជអាជ្ញាជាតិៗ រួចមកហើយថា លោក អៀង សារី បានវិលត្រឡប់មកវិញ នៅក្នុងពេលនោះ។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់បំភ្លឺឡើងវិញ តើការប្រជុំនុំង មានការចូលរួមដោយលោក អៀង សារី ដែរឬទេ? គឺនៅពេលនោះហើយ ដែលគាត់វិលត្រឡប់មកកម្ពុជាវិញហើយ ហើយបានចូលរួមប្រជុំនោះ នៅក្នុងឆ្នាំ១៩៧៤ ជាមួយគេនោះ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់ហ្នឹង គឺថាប្រជុំនៅឆ្នាំ៧៤ ហ្នឹង គឺក៏មានវត្តមានរបស់គាត់ដែរ។ គាត់អង្គាល់ហ្នឹង គាត់នៅមិនបានយូរទេ គឺថាប្រជុំចប់ហើយ គាត់ត្រឡប់ទៅវិញ។

**ស៖** លោកក៏បានលើកឡើងផងដែរ ថានៅក្នុងកិច្ចប្រជុំនោះមានអ្នកចូលរួមផ្សេងទៀត ក្រៅពីអៀង សារី តើលោកនឹកឃើញដែរឬទេ មាននរណាគេទៀតដែរ ដែលចូលរួមនៅក្នុងការប្រជុំនៅក្នុងឆ្នាំ១៩៧៤ ក្នុងខែមិថុនា នោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា គ្រប់ភូមិភាគមកចូលរួមប្រជុំទាំងអស់។ ដូចខ្ញុំរៀបរាប់ពីខាងលើហ្នឹង ហើយពេលហ្នឹងក៏គ្រប់ភូមិភាគ តែវាអត់បានគ្រប់ដូចអង្គាល់ឆ្នាំ៧០, ៧១ទេ។ ៧៤ ចំនួនកម្លាំងដែលមកតាមភូមិភាគវាតិចជាង មែនទែនមកតែមេៗសំខាន់មួយភូមិភាគមកតែពីរនាក់ៗទេ។

**ស៖** តើ ប៉ុល ពត, នួន ជា និង ខៀវ សំផន នោះបានចូលរួមប្រជុំនៅក្នុងឆ្នាំ៧៤នោះដែរឬទេ?

[១១:៤១:៣៧]

**ឆ៖** គាត់មានវត្តមាននៅទីនោះទាំងអស់គ្នា។ ទាំងបីរូបមានទាំងអស់។

**ស៖** លោកបាននិយាយហើយថា មេដឹកនាំភូមិភាគទាំងអស់មិនបានចូលរួមនោះទេ ក៏ប៉ុន្តែមានមេដឹកនាំភូមិភាគណាខ្លះដែលបានចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះ?

**ឆ៖** ពេលនោះ ខ្ញុំឃើញ ៧៤ នេះ សោ ភឹម ចូលរួមដែរ។ កុយ ធួន ចូលរួមដែរ។ តាម៉ុក ក៏ចូលរួមដែរ។ វន វ៉េត ចូលរួមដែរ។ រស់ ញឹម ក៏ចូលរួមដែរ។ សុន សេន ក៏ចូលរួមដែរ សន្និបាតនេះលោក អៀង សារី នេះចូលរួមទាំងអស់។

[១១:៤៣:១០]

**ស៖** តើលោកចាំដែរឬទេ នៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅឆ្នាំ៧៤នោះ? ចំណុចមួយដែលកើតចេញពីការពិភាក្សានោះ គឺពាក់ព័ន្ធទៅនឹងបាតុភាពស្ថានភាពទាក់ទងទៅនឹង ប្រសិទ្ធិ ដែលពាក់ព័ន្ធទៅនឹងហេតុការណ៍នៅកោះកុងនោះ តើលោកចាំទេ ថាមានការពិភាក្សាទៅលើបុគ្គលឈ្មោះ ប្រសិទ្ធិ ពាក់ព័ន្ធទៅនឹងបញ្ហាខេត្តកោះកុងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ។

**ស៖** តើលោកចាំដែរឬទេ? មានជោគវាសនា ឬមានអ្វីកើតឡើងដែរ ចំពោះ ប្រសិទ្ធិ និងកម្មាភិបាលផ្សេងទៀតនៅខេត្តកោះកុងឆ្នាំ៧៤នោះ?

**ឆ៖** ខ្ញុំគ្រាន់តែឮលស់ថាអ៊ីចេះនៅកោះកុងហ្នឹង គេ -- គាត់ហ្នឹងគឺឈ្មោះ តាចុង ដល់ប្រជុំពេលហ្នឹងគាត់អត់ឃើញទេ។ ហាក់បាត់ អវត្តមានរបស់គាត់ បាត់ដែរ មិនឃើញទេ។

[១១:៤៤:៤៤]

**លោក ឌេល លីសាក់៖**

លោកប្រធាន ដើម្បីរំឭកការចងចាំសាក្សី ខ្ញុំសូមយោងទៅលើអត្ថបទមួយដកស្រង់ចេញពីសៀវភៅ ហ្វីលីព ស្សូត ដែលពាក់ព័ន្ធទៅនឹងការដកស្រង់សម្តី ពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ។ ឯកសារនេះ គឺ E3/9 ការបកប្រែ ឬលេខ ERN ភាសាអង់គ្លេស គឺ 00396468, បារាំង គឺ 00639701 ទៅដល់ 10។ គឺយើងខ្ញុំសូមបញ្ជាក់ថា ខ្មែរនោះគឺអត់នោះទេ។ ដូច្នេះយើងហើយ ខ្ញុំសូមអនុញ្ញាតអានឲ្យសាក្សីស្តាប់ត្រង់ចំណុចដែលខ្ញុំសុំដកស្រង់នេះ។ សូមអរគុណលោកប្រធាន ហើយខ្ញុំសូមផ្តល់ឯកសារជាក្រដាសទៅដល់សាក្សី។

**ប្រធានអង្គជំនុំ៖**

ឯកសារជាក្រដាស ជាភាសាខ្មែរ?

**លោក ខេល លីសាក់៖**

លោកប្រធាន សៀវភៅនេះសរសេរដោយ ហ្វីលីព ស្សូត មាននៅក្នុងសំណុំរឿង មានតែផ្នែកពាក់ព័ន្ធមួយចំនួនតែប៉ុណ្ណោះដែលបកប្រែទៅជាភាសាខ្មែរ ហើយភាសាបារាំង និងភាសាអង់គ្លេសនោះគឺវាមានអត្ថបទនេះពេញលេញតែម្តង។ ខ្ញុំស្នើសុំអានការដកស្រង់សម្តីនោះជាភាសាអង់គ្លេស។ បន្ទាប់មកសុំអនុញ្ញាតឲ្យមានការបកប្រែផ្ទាល់តែម្តងទៅដល់សាក្សី។ យើងមិនមានឯកសារជាក្រដាសខ្មែរនោះពីសៀវភៅរបស់លោក ហ្វីលីព ស្សូត នោះផ្តល់ជូនសាក្សីនោះទេ។ សូមអនុញ្ញាតពីលោកប្រធាន។

[១១:៤៦:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ប៉ុន្តែអម្បាញ់មិញនេះ គឺមានការបកប្រែថា សូមប្រគល់ឯកសារជាក្រដាសជូនទៅសាក្សី។ ហើយលោកបាននិយាយពីខាងដើមថា មិនមានជាភាសាខ្មែរទេ។

អង្គជំនុំជម្រះអនុញ្ញាត ហើយសាក្សីទុកឯកសារនុំងម្តុំទៅ មួយអន្លើចុះ មិនមានការពាក់ព័ន្ធតទៅទៀតទេ រង់ចាំស្តាប់នូវសំណួរពាក់ព័ន្ធជាមួយនឹងបញ្ហាថ្មី បរិបទថ្មីទៀតដែលគេនឹងសួរ។

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំសូមអនុញ្ញាតអានជូនលោកស្តាប់។ អត្ថបទដកស្រង់ចេញពីសៀវភៅ ហ្វីលីព ស្សូត ដែលនិយាយអំពីហេតុការណ៍កើតឡើងចំពោះ ប្រសិទ្ធិ -- លោក ប្រសិទ្ធិ នៅក្នុងឆ្នាំ ១៩៧៤ ដកស្រង់សម្តី៖ “នេះគឺជាលើកទីមួយហើយ ដែលទំនាស់នៅក្នុងបក្សកើតមានឡើង នៅក្នុងជួរបក្ស។ នៅពេលនោះហើយ ដែលបក្សអនុញ្ញាតឲ្យមានការកាប់សម្លាប់កម្មាភិបាលមួយរូបនៅក្នុងភូមិភាគ។ នៅក្នុងពេលប្រជុំនោះ មានការពិភាក្សាគ្នាទៅលើបញ្ហា ប្រសិទ្ធិ។ គឺនៅពេលនោះ គឺមានការលើកឡើងថា ការតស៊ូវណ្ណៈនោះ ត្រូវធ្វើឡើងឲ្យបានខ្លាំងក្លា។ ហើយយើងត្រូវតែមានជំហររឹងប៉ឹងចំពោះខ្មាំង។ មានការលើកឡើងថា ការប្រឆាំងនឹងបដិវត្តន៍ យើងត្រូវតែដោះស្រាយឲ្យបានហ្មត់ចត់”។

ចំណុចនេះ គឺការដកស្រង់សម្ដីចេញពីលោកដែលលោកបានឆ្លើយ។ ភួន -- គាត់មិនបានបញ្ជាក់ទៅលើចំណុចនោះទេ។ ចំពោះចំណុចនេះហើយ ដែលគេគិតថា វាមានការពាក់ព័ន្ធទៅលើបញ្ហា ប្រសិទ្ធិ ហើយ ប្រសិទ្ធិ មិនបានមកចូលរួមប្រជុំនោះឡើយ។ ខ្ញុំបានលើកឡើងអំពីបញ្ហា ប្រសិទ្ធិ នេះ ហើយលោក ហ្វីលីព ស្សូត នេះក៏បានធ្វើសម្ភាសជាមួយលោកទៅលើបញ្ហាលោក ប្រសិទ្ធិ ដូចនេះដែរ។ ហើយលោកបានឆ្លើយនៅក្នុងសៀវភៅរបស់គាត់។ តើលោកមានចាំទេ?

**លោក វ៉ាចាម គុន៖**

**ឆ៖** ខ្ញុំដូចអត់ចាំទេចំណុចហ្នឹង។ ខ្ញុំដូចខ្ញុំបញ្ជាក់ខាងដើមអំមិញ គ្រាន់តែថា ប្រជុំពេលហ្នឹង វាអវត្តមានគាត់។ វាល់ដង វាដែលឃើញគាត់។ ដល់ហ្នឹងវាអវត្តមានគាត់។ ខ្ញុំបើគាត់សួរចំណុចហ្នឹងខ្ញុំឆ្លើយអ៊ីចឹង។ តាមដែលខ្ញុំចាំមានប៉ុណ្ណឹងទេ។ ប៉ុន្តែល្អិតទៅ ខ្ញុំមិនដឹងដែរ។

[១១:៤៩:៤៨]

**ស៖** សូមអរគុណច្រើន។ តើលោកបានដឹងដែរឬទេថា មេដឹកនាំបក្សនៅក្នុងអំឡុងឆ្នាំ៧៤នោះទទួលរងនូវការដាក់ពិន័យ ដោយសារតែអ្នកទាំងអស់នោះមួយចំនួនដែលគិតតែទទួលវិន័យនោះ គឺដោយសារតែមិនឯកភាពជាមួយនឹងគោលនយោបាយបក្ស។ តើលោកដឹងដែរឬទេចំណុចហ្នឹង?

**ឆ៖** ចំណុចហ្នឹង គឺជាល្អិត ជាឯកសារដូចខ្ញុំអត់បានមើល។ អត់បានមើល អត់បានចាំ អត់ដឹងទេ។

**ស៖** តើលោកចាំដែរឬទេថា ហ៊ូ យន់ នៅក្នុងឆ្នាំ១៩៧៤ គឺគាត់បានលើកឡើងការមិនឯកភាពជាមួយនឹងគោលនយោបាយក្ស? តើលោកនឹកឃើញទេ?

**ឆ៖** កាលណោះ ខ្ញុំឮៗអ៊ីចេះកាលហ្នឹង ឮអ្នកៗដែលនៅជាមួយគ្នាហ្នឹង គឺពេលអ្នកខ្លះគេបានដូចថាជួបគាត់ ហើយគាត់ពិភាក្សាជាមួយ ដូចថាមិនមែនពិភាក្សា ដូចជាប្រាជ្ញលេង។ ហ៊ូ យន់ ហ្នឹង គាត់ថា ន៎... កាលហ្នឹងគឺថា គាត់ជំទាស់ពីរឿងជម្លៀសប្រជាជនចេញ គាត់ជំទាស់។ អាហ្នឹងគឺចំពោះបុគ្គលគាត់ហ្នឹង គឺគាត់និយាយជាមួយអ្នកដែលពួកខ្ញុំធ្វើការនៅមន្ទីរហ្នឹងវាច្រើនគ្នាដែរ វា៨០នាក់ជាងនោះ។ កាលហ្នឹងពួកដែលទៅយាមនៅកន្លែងគាត់ហ្នឹង ឮគាត់ពិភាក្សាថា គាត់ជំទាស់ពីរឿងដែលជម្លៀសប្រជាជនចេញពីទីក្រុង។ តែខ្ញុំអត់បានជួបគាត់ផ្ទាល់ទេ ឮៗគេនិយាយអ៊ីចឹង។

[១១:៥២:២៨]

**ស៖** តើអ៊ំ ហ៊ូ យន់ នោះមានទទួលរងនូវការលត់ដំដែរឬទេ ដោយសារតែគាត់នោះបានលើក

ឡើងប្រាជ្ញអំពីការពុំឯកភាពជាមួយនឹងគោលនយោបាយបក្សនោះ?

**ប្រធានអង្គជំនុំ៖**

លោកសាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្តាប់សេចក្តីជំទាសរបស់តំណាង -- របស់មេធាវីជាតិការពារក្តីលោក អៀង សារី ជាមុនសិន។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការសួស្តីអស់លោកអ្នកទាំងឡាយ។ អំមិញសាក្សីបានឆ្លើយថា ទាក់ទងនឹងការប្រជុំ និងករណីលោក ហ៊ូ យន់ ហ្នឹងគាត់មិនបានឮ មិនបានឃើញផ្ទាល់ទេ គាត់ឮគេនិយាយប្រាប់ គាត់ឮអ្នកផ្សេងគេនិយាយប្រាប់។ អានេះជាភស្តុតាងបានមកពីអ្នកផ្សេង មិនមែនគាត់បានដឹងឮផ្ទាល់ទេ។ ខ្ញុំគួរតែជំទាស់នេះតាំងពីដំបូង ប៉ុន្តែឥឡូវព្រះរាជអាជ្ញាគាត់តសំណួរសួរទាក់ទងរឿងការដឹងឮហ្នឹងទៀត។ អ៊ីចឹងសំណួរ -- សាក្សីមិនបានដឹងឮបញ្ហានេះផ្ទាល់ទេ វាអាចជាភស្តុតាងដែលបានមកពីភាគីដទៃ អាចថាជាភស្តុតាងចចាមអារ៉ាម។ អ៊ីចឹងសូមជំទាស់សំណួរនេះ។ សូមអរគុណ។

[១១:៥៣:៥៤]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាមានអ្វីតបទៅនឹងសេចក្តីជំទាស់នេះទេ?

**លោក ឌេល លីសាក់៖**

គឺខ្ញុំសូមបញ្ជាក់ថា ការជំទាស់នេះមិនត្រឹមត្រូវនោះទេ។ នៅក្នុងវិធានរបស់យើងមិនមែនមានចែងអំពីភស្តុតាងចចាមអារ៉ាមនោះឡើយ។ ដូច្នេះហើយខ្ញុំគិតថា ការលើកឡើងការជំទាស់នេះគឺមិនមានលក្ខណៈសមហេតុផលនោះឡើយ។

[១១:៥៤:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៥:២២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីរបស់លោក អៀង សារី ធ្វើឡើងមិនមានមូលដ្ឋានសមស្របទេ។ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះ

ចាំបាច់ត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សី ទៅនឹងសំណួរចុងក្រោយ ដែលសួរដោយតំណាងសហព្រះរាជអាជ្ញា។ ទំនងជាសាក្សីភ្លេចហើយ សូមតំណាងសហព្រះរាជអាជ្ញាតាំងសំណួរនេះ សាជាថ្មីឡើងវិញ ដើម្បីឲ្យលោកសាក្សីស្តាប់បានឲ្យច្បាស់នូវខ្លឹមសារនៃសំណួរដើម្បីគាត់អាចឆ្លើយតបបាន។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំបានសួរថា តើ ហ៊ូ យន់ ត្រូវបានគេលត់ដំ ឬមានទទួលទណ្ឌកម្មអ្វីដែរឬទេ នៅពេលដែលគាត់និយាយជំទាស់ទៅលើគោលនយោបាយរបស់បក្សនោះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** កាលហ្នឹងបើជាខ្ញុំផ្ទាល់ហើយ ខ្ញុំដូចអត់ឃើញលត់ដំស្អីទេ ពីព្រោះគាត់កាលហ្នឹង គាត់ដើរធ្វើតាមៗមូលដ្ឋាន។ អាហ្នឹង គឺថា គាត់ធ្វើការតាមមូលដ្ឋាន។ គាត់ដើរធ្វើមីទិ្ទង ដើរធ្វើមីទិ្ទងតាមមូលដ្ឋាន ប្រជាជនយើងគ្រប់ កន្លែងដែលអាចទៅបានតំបន់រំដោះ កន្លែងណាដែលអាចទៅបានហ្នឹងឃើញគាត់ធ្វើការជាប់ដែរ។

[១១:៥៧:០៩]

**ស៖** សូមអរគុណ។ នៅពេលនេះ យើងសល់ពេលតែប៉ុន្មាននាទីតែប៉ុណ្ណោះមុនពេលឈប់សម្រាក។ ខ្ញុំចង់ចូលទៅដល់រយៈកាល១៧ មេសា ឆ្នាំ៧៥ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេថា នៅព្រឹកថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នោះ លោកនៅកន្លែងណាដែរ?

**ឆ៖** ថ្ងៃ១៧ មេសា ៧៥ ហ្នឹង គឺខ្ញុំនៅមន្ទីរ ដូចខ្ញុំថា មន្ទីរស្តុកគោលហ្នឹង នៅជាមួយអ៊ំទី១ហ្នឹងដែរ នៅជាមួយគាត់ហ្នឹង កាលហ្នឹង។

**ស៖** ដើម្បីឲ្យប្រតិចារឹកច្បាស់។ នៅពេលដែលលោកនិយាយថា អ៊ំទី១ នោះ គឺលោកសំដៅលើ ប៉ុល ពត ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ហ្នឹងហើយសំដៅលើអ៊ំ ប៉ុល ពត ហ្នឹងហើយ។

**ស៖** តើមន្ទីរនៅស្តុកគោលនេះ នៅកន្លែងណាដែរ បើប្រៀបធៀបជាមួយនឹងប-៥ នោះ ដូចដែលលោកជម្រាបនៅក្នុងថ្ងៃនេះ?

**ឆ៖** មន្ទីរនៅស្តុកគោលហ្នឹងវា វាឆ្ងាយពីគ្នាប្រហែលជាង១០គីឡូដែរ វានៅខាងមុខ អាហ្នឹងវា

មកជាប់នឹងរ៉ាវទេះភ្លើងស្នាច់ហ្នឹង វានៅខាងៗត្បូងរ៉ាស្នាច់ អាហ្នឹងវានៅកៀកមកសមរភូមិខាងមុខហ្នឹង បន្តិចដែរ។

[១១:៥៩:២៦]

**ស៖** ក្រៅពី ប៉ុល ពត និងលោក តើមាននរណាផ្សេងទៀតដែរឬទេ ដែលនៅមន្ទីរស្តុកតោល នៅថ្ងៃ១៧ មេសា ឆ្នាំ៧៥ នោះ?

**ឆ៖** នៅកន្លែងហ្នឹង គឺថាគណៈសមរភូមិដែលនៅដូចថា នៅកៀកនៅហ្នឹងមានតែ សុន សេន, កុយ ធួន, តាម៉ុក ហើយនិង វន វេត គាត់មកជុំគ្នានៅហ្នឹងដែរ។

**ស៖** ចុះ ខៀវ សំផន គាត់នៅទីនោះដែរឬទេ?

**ឆ៖** ថ្ងៃហ្នឹង អ៊ំ ខៀវ សំផន អត់នៅទេ។

**ស៖** តើលោកដឹងថា គាត់នៅកន្លែងណាដែរ នៅថ្ងៃ១៧ មេសា ឆ្នាំ៧៥ នោះ?

**ឆ៖** អង្កាល់ហ្នឹង គាត់នៅសមរភូមិក្រោយ គឺ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ។ ម្តងទៀត អំមិញនេះសំណួរសួររបស់តំណាងសហព្រះរាជអាជ្ញាមិនបានបើកក្បាលមីក្រូ។ សូមតាំងសំណួរសាជាថ្មី ម្តងទៀតសំណួរចុងក្រោយអម្បាញ់មិញនេះ!

**លោក ឌេល លីសាក់៖**

សូមអធ្យាស្រ័យលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរដែលខ្ញុំសួរនោះ ខ្ញុំចង់សួរថាតើលោកដឹងថា ខៀវ សំផន នៅឯណាដែរ នៅថ្ងៃ១៧ មេសា ឆ្នាំ៧៥ នោះ?

[១២:០១:៣៨]

**លោក រ៉ាចាម តុន៖**

**ឆ៖** ថ្ងៃនុំងខ្ញុំៗឃើញនៅក្នុងមន្ទីរស្តុកតោល ដូចអត់ឃើញគាត់ទេ។ បើអត់ឃើញគាត់បានន័យថាគាត់នៅៗសមរភូមិក្រោយហើយពេលនុំង។ អត់ឃើញ។

**ស៖** តើលោកចាំទេថា នួន ជា ហ្នឹងគាត់នៅមន្ទីរ នៅឯស្តុកតោល ហ្នឹងដែរឬទេនៅថ្ងៃនុំង?

**ឆ៖** អ៊ំ នួន ជា ដូចអត់ឃើញដែរ ថ្ងៃនុំង ដូចអត់ឃើញទេ។

**ស៖** តើ ប៉ុល ពត មានឲ្យលោកទៅទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដែរឬទេ?

**ឆ៖** ថ្ងៃ១៧ មេសា ហ្នឹង គឺថាខ្ញុំនៅជាមួយគាត់ទេ អត់មានចាត់ចែងទៅណាទេ។ ថ្ងៃ១៨ៗ ហ្នឹងគឺថា ថ្ងៃហ្នឹង គឺ សុន សេន ទៅចូលទៅមើលទីក្រុងភ្នំពេញ។ ថ្ងៃហ្នឹង ខ្ញុំបានខ្ញុំមកហើយ ខ្ញុំមកដែរ។ ថ្ងៃ១៩ ទេ។

[១២:០៣:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវហ្នឹងដល់ពេលសមល្មមសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះរហូតដល់ម៉ោងមួយសាមសិននាទីរសៀលនេះ ដើម្បីបន្តកិច្ចដំណើរការសវនាការ ដើម្បីពិសាអាហារថ្ងៃ។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំសូមជម្រាបដោយសង្ខេបថា កូនក្តីរបស់ខ្ញុំឈឺចង្កេះ ហើយគាត់មានការឈឺក្បាល មិនអាចផ្តង់អារម្មណ៍បាននោះទេ។ ដូច្នេះគាត់ស្នើសុំតាមដានពីបន្ទប់រង់ចាំខាងក្រោម។

[១២:០៤:០៩]

ខ្ញុំសូមជម្រាបថា ករណីនេះហើយដែលវារារាំងគាត់ជាដរាបមក មិនអាចឲ្យគាត់ចូលរួមតាមដានសវនាការជារៀងរាល់រសៀលថ្ងៃសវនាការ។ ដូច្នេះហើយ គឺខ្ញុំសូមបញ្ជាក់ឲ្យបានត្រឹមត្រូវនៅក្នុងប្រតិចារឹក ហើយខ្ញុំសូមបញ្ជាក់ថា គាត់មិនដែលមានការផ្តង់អារម្មណ៍បានពេញលេញនៅក្នុងសវនាការនេះនោះទេ ដោយសារតែបញ្ហានេះឯង។ សូមអរគុណលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៥:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពាររបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់កិច្ចដំណើរការសវនាការពេញនៅរសៀលនេះ។ អង្គជំនុំជម្រះយល់តាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែល

បានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំបន្តទៅតាមដានសវនាការពីចម្ងាយ។ ក្នុងរយៈពេលសវនាការនៅរសៀលនេះ ដោយគាត់បានលះបង់សិទ្ធិចូលរួមកិច្ចដំណើរការផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឱ្យក្រុមមេធាវីការពារក្តីលោក អៀង សារី -- អ៎! លោក នួន ជា សូមកែប្រែ គឺលោក នួន ជា ត្រូវប្រគល់មកឱ្យអង្គជំនុំជម្រះភ្ជាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួន ស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញមួយរសៀលថ្ងៃនេះ។

[១២:០៦:០៩]

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយនៅរសៀលនេះ ទុកឱ្យ នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំទុកស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់អាចគាត់ចូលរួម តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឱ្យនាំគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៣៩ នាទី)*

[១៣:៣៩:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅក្នុងពេលវេលាជាបន្តនេះ

អង្គជំនុំជម្រះនឹងផ្តល់ជូនវេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ប៉ុន្តែមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់ និងជម្រាបជូនទៅមេធាវីការពារក្តីអន្តរ -- មេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

សូមអញ្ជើញលោកក្រោកឈរ! ដោយមានបញ្ហាកាលពីព្រឹកមិញ មុននឹងសម្រាកពិសាអាហារថ្ងៃត្រង់នៅក្នុងសំណើរបស់លោក នៃមូលហេតុនៃការសុំឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ អង្គជំនុំជម្រះសូមជម្រាបលោកថា បន្ទប់ដែលបានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពិតណាស់វាមិនដូចគ្នានឹងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះទេ។

[១៣:៤១:០៥]

ប៉ុន្តែគឺវាមានលក្ខណៈសមស្របគ្រប់គ្រាន់ ដែលអាចឲ្យជនជាប់ចោទអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន និងអាចបង្កលទ្ធភាពនៅក្នុងការទំនាក់ទំនងរវាងមេធាវី និងជនជាប់ចោទដែលជាកូនក្តីរបស់ខ្លួនបាន។ ហើយបន្ទប់ដែលបានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយនេះ មេធាវីទាំងអស់សុទ្ធតែបានពិនិត្យ ហើយចាប់តាំងពីពេលនោះរហូតដល់ពេលនេះ មិនមានការជំទាស់តវ៉ាអ្វីអំពីការរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់តាមដានកិច្ចដំណើរសវនាការពីចម្ងាយ ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរៀបចំនោះទេ។

[១៣:៤១:៥៧]

នៅក្នុងករណីដែលមានបញ្ហាចំពោះកូនក្តីរបស់ខ្លួន ដូចដែលមេធាវីបានលើកឡើងកាលពីព្រឹកមិញនោះ គឺមិនមានមូលហេតុ -- និងមិនមានមូលដ្ឋានភស្តុតាងអីគាំទ្រដល់ពាក្យសម្តីដែលលោកនិយាយនោះឡើយ។ ក្នុងនាមជាមេធាវីការពារក្តី ក្នុងករណីមានបញ្ហាអ្វីកើតឡើងចំពោះកូនក្តីរបស់ខ្លួននោះ នោះភារកិច្ចជាមុខងាររបស់លោកមេធាវី គប្បីត្រូវបំពេញក្នុងការការពារដើម្បីកូនក្តីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ហើយនិងគប្បីការលើកឡើងនូវអ្វីៗទាំងអស់សុទ្ធតែគាំទ្រដោយមូលដ្ឋានសំអាងអង្គហេតុអង្គច្បាប់ និងភស្តុតាងឲ្យបានត្រឹមត្រូវ ចៀសវាងនិយាយដោយមិនមានមូលដ្ឋានភស្តុតាងគាំទ្រ។

[១៣:៤២:៤៩]

ហើយជាចុងក្រោយនេះ គឺបើសិនជាមានបញ្ហាអីចង់បន្ថែម អស់លោក លោកស្រីចៅក្រមមាន

អីបន្ថែមដែរទេ?

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីសង្ខេបនូវឧបករណ៍ដែលនៅក្នុងតុលាការនេះ គឺមានគ្រប់គ្រាន់សម្រាប់ជនជាប់ចោទទាំងអស់ក្នុងការចូលរួមនៅក្នុងវិធីមួយដែលថា ប្រហាក់ប្រហែល ឬក៏ដូចនឹងសវនាការក្នុងសវនាការ -- ក្នុងសាលសវនាការដែរ។ ដូច្នេះហើយភាគីក៏បានពិនិត្យ ហើយនិងយល់ស្របដែរ។ បើសិនជាថា មិនបម្រើគោលបំណងនោះទេ គឺជាការទទួលខុសត្រូវរបស់មេធាវីរបស់ជនជាប់ចោទម្នាក់ៗ ដើម្បីជម្រាបមកអង្គជំនុំជម្រះនៅពេលដែលមានបញ្ហា ហើយសូមលោកកុំធ្វើសេចក្ដីឬក៏យោបល់ជាទូទៅថា មិនសមស្របដល់តុលាការ។

[១៣:៤៤:០០]

**លោក អេនគ្រូ អ៊ីទូហ្ស៊ី៖**

សូមអរគុណលោកចៅក្រម។ សូមបំភ្លឺ ខ្ញុំមិនបានរិះគន់ក្នុងវិធីណាមួយនូវឧបករណ៍សម្ភារៈនោះទេ។ ខ្ញុំឃើញថា ឧបករណ៍សម្ភារៈហ្នឹងគឺគ្រប់គ្រាន់ដែលខ្ញុំកត់ត្រា -- ចង់ឲ្យកត់ត្រាហ្នឹង គឺជាក់ស្ដែងដោយសារការព្រួយបារម្ភដែលខ្ញុំលើកឡើងបញ្ហារបស់កូនក្ដីខ្ញុំហ្នឹង គឺកូនក្ដីរបស់ខ្ញុំ គឺតាមពិតមិនចូលរួមក្នុងសវនាការ -- ដំណើរការដោយសកម្មទេ។ ចំពោះលក្ខណៈបច្ចេកទេសដែលលោកបានលើកឡើងនេះ គឺថា ប្រហែលជាចំណុចដែលខ្ញុំលើកឡើងហ្នឹងគឺថា អាចនឹង ឬក៏ប្រហែលជាកំហុសខ្ញុំមិនបានបញ្ជាក់ឲ្យច្បាស់។ ខ្ញុំមិនមានបញ្ហាជាមួយឧបករណ៍សម្ភារៈនោះទេ។ លោកត្រូវហើយ ចំណុចដែលខ្ញុំជម្រាបនោះគឺថា កូនក្ដីរបស់ខ្ញុំដោយសារលក្ខខណ្ឌសុខភាពរបស់គាត់ គាត់មិនបានតាមដានដំណើរការនីតិវិធី ដោយសកម្ម និងមានប្រសិទ្ធភាពទេ។ ដូច្នេះចំណុចរបស់ខ្ញុំច្បាស់ប៉ុណ្ណឹងទេ លោកលោកស្រីចៅក្រមបាទ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះអង្គជំនុំជម្រះច្បាស់ហើយ គឺថាលោកចង់ដាក់ការទទួលខុសត្រូវដោយមិនច្បាស់លាស់ដល់តុលាការ ឬអង្គជំនុំជម្រះខ្លួនឯង។ ប៉ុន្តែការទទួលខុសត្រូវជារបស់លោកក្នុងការជម្រាបទៅកូនក្ដីរបស់លោក ឬក៏ជាមួយកូនក្ដីរបស់លោកថា គាត់មិនអាច ឬក៏អាចតាមដានដោយមានប្រសិទ្ធភាព ដោយសកម្ម ឬដូចម្ដេច។

ហេតុដូច្នេះ ខ្ញុំនឹងប្រគល់វេទិកាទៅលោកប្រធាន ដើម្បីបន្តនីតិវិធី ដើម្បីកុំឲ្យខាតពេល។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ ហើយចំណុចមួយទៀត អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះមិនធ្វើសវនាការទេ។ សវនាការចប់នៅថ្ងៃនេះ ហើយយើងនឹងធ្វើតាមធម្មតា គឺបន្តធ្វើនៅថ្ងៃចន្ទសប្តាហ៍ក្រោយ។ សូមភាគីជ្រាប។

បាទ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១៣:៤៦:១៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ យើងបានពិភាក្សាគ្នាអំពីកាលបរិច្ឆេទនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ មុនពេលសម្រាក។ សូមលោកជម្រាបតុលាការ ថាតើលោក តើលោកបានដឹងថាភ្នំពេញបានរំដោះហ្នឹង គឺដឹងដោយរបៀបណា?

**លោក វ៉ាចាម តុន៖**

**ឆ៖** ខ្ញុំដឹងតាម ពេលនោះគឺលោក សុន សេន គាត់មកកន្លែងលោក ប៉ុល ពត។ ហើយអាហ្នឹងមួយផ្នែក។ មួយផ្នែកទៀតមានវិទ្យុតាមដានមួយធំដែរនៅទីបញ្ជាការហ្នឹង។ វិទ្យុហ្នឹង គឺថាយកបានអង្គាល់រំដោះខដុង្គ គឺបានយកវិទ្យុហ្នឹង។ គេស្តាប់មួយសមរភូមិទូទាំងប្រទេស គេស្តាប់បានទាំងអស់ ឮរ៉ោកៗនៅកណ្តាលវាលហ្នឹងឯង។ ដល់ណា ដល់ណា ដឹងទាំងអស់។

[១៣:៤៧:៤៨]

**ស៖** សូមលោកប្រាប់ខ្ញុំឲ្យបានច្បាស់ថែមទៀត អំពីវិទ្យុដែលអាចឲ្យលោកស្តាប់បានទាក់ទងនឹងការផ្សាយ ការប្រកាសហ្នឹង ថាតើៗលោកអាចស្តាប់ការផ្សាយ ការប្រាស្រ័យទាក់ទងនឹងដោយរបៀបណា? តើលោកស្តាប់ពីខាងយោធារបស់បក្សកុម្មុយនីស្តកម្ពុជាឬពេលនោះ នោះ?

**ឆ៖** ជាធម្មតា គឺថាមានវិទ្យុទាក់ទងមកជាប់ទីបញ្ជាការហ្នឹង។ គេមានវិទ្យុទាក់ទងជាប់តាម

ដាន។ គេវើដល់សមរភូមិណា គេដល់កន្លែងណាៗ មុខសញ្ញាហ្នឹង។ បើថាខាងមុខសញ្ញា សុន សេន, សុន សេន រាយការណ៍មក។ មុខសញ្ញា តាម៉ុក, តាម៉ុក រាយការណ៍មក។ មុខសញ្ញា វន វេត, វន វេត រាយការណ៍មក។ ជាអចិន្ត្រៃយ៍តែម្តង។ បើ កុយ ធួន, កុយ ធួន រាយការណ៍មក។ ហើយ សោ ភឹម, សោ ភឹម រាយការណ៍មក។ ជុំវិញភ្នំពេញ គឺថាវិទ្យុ សេ-សែសិប -- សេ-៤៦ ហ្នឹងផង ហើយនិងវិទ្យុ ដែលយើងថា យកបាននៅឧដុង្គហ្នឹង ធំណាស់អាហ្នឹង មិនដឹងជា អាហ្នឹងចាប់បានទាំងអស់ វាច្បាស់តែម្តង។

[១៣:៤៩:២១]

**ស៖** តើរយៈពេលប៉ុនណា ដែលវិទ្យុទាក់ទងនឹងបានយកមកប្រើទាំងនៅស្តុកតោល ហើយនិងនៅមន្ទីរ ប-៥នោះ? តើលោកមានលទ្ធភាព ថាស្តាប់វិទ្យុទាក់ទងហ្នឹង គឺថាមានរយៈពេលហ្នឹងប៉ុន្មាន ដែលមានលទ្ធភាពស្តាប់វិទ្យុទាក់ទងហ្នឹងបាន?

**ឆ៖** វិទ្យុទាក់ទងនឹង គឺថាការឆ្លើយឆ្លង គឺថាចង់តែ២៤ម៉ោងនោះ គេតាំង២៤ម៉ោង។

**ស៖** ខ្ញុំចង់ឲ្យលោកបំភ្លឺសំណួររបស់ខ្ញុំ ខ្ញុំចង់សួរផងដែរថាតើៗលោកមានវិទ្យុទាក់ទង បានន័យថាមន្ទីរហ្នឹងមានវិទ្យុទាក់ទងហ្នឹងយូរមកហើយឬទេ ឬក៏ទាល់តែចាប់បានមកពីឧដុង្គបានយកមកប្រើ ឬក៏ធ្លាប់មានពីមុនហ្នឹងមកដែរ? បាទ នេះជាសំណួរ។ នេះជាឧបករណ៍ដែលគេប្រើនៅក្នុង ប-៥ ឬក៏មន្ទីរផ្សេងៗនៅក្នុងតំបន់ហ្នឹងទេ ចាប់តាំងពីចាប់យកវិទ្យុបានឧដុង្គមក ឬក៏មានមុនពីហ្នឹងមក?

[១៣:៥០:៥៩]

**ឆ៖** មុនហ្នឹងមានដែរ គេហៅថា វិទ្យុ គេហៅថា ពីរវ៉ាត់របស់ចិន របស់ចិនក៏មានដែរ។ ហើយវិទ្យុ ខ្ញុំមិនដឹងថាបានពីណាទេ ប៉ុន្តែវិទ្យុសេ-២៥ ហ្នឹងក៏មានដែរ គេមាន ទីបញ្ជាការមាន។ ប៉ុន្តែដល់រំដោះឧដុង្គហ្នឹងវាបាន៤៦ ហ្នឹងផង វាបានអាធំជាងហ្នឹងទៀត។

**ស៖** សូមអរគុណ។ ឥឡូវនេះត្រឡប់មកថ្ងៃទី១៧ មេសា ១៩៧៥ ក្រោយពីលោក ហើយនិងមនុស្សផ្សេងទៀតដែលបានដឹងថា ថាបានកាន់កាប់ភ្នំពេញហើយនោះ។ តើលោកទទួលបានការចាត់តាំងអ្វីដើម្បីឲ្យត្រៀមខ្លួន ដើម្បីចូលមកភ្នំពេញដែរឬទេ? ហើយបើគេចាត់តាំងលោក តើការចាត់តាំងហ្នឹងឲ្យលោកធ្វើអ្វី?

**ឆ៖** ពេលរំដោះភ្នំពេញហើយ ដូចខ្ញុំបានបញ្ជាក់អំពីព្រឹកមិញហើយ គឺថាថ្ងៃ១៩ ខ្ញុំចូលទៅជាមួយនែ លោក សុន សេន ខ្ញុំចូលទៅដល់ភ្នំពេញ។ ដល់ថ្ងៃ នៅថ្ងៃ២០ ហ្នឹងគឺទៅទាំងអស់គ្នា គឺឈប់

នៅស្តុកគោលហើយ។ ហ្នឹងគឺដឹកនាំទាំងអស់ គ្រប់មុខសញ្ញាហ្នឹងចូលភ្នំពេញទាំងអស់ ហើយនិង ប៉ុល ពត ក៏ចូលដែរ។ ខ្ញុំ ក៏ចូលទៅជាមួយគាត់ដែរ។

[១៣:៥៣:០០]

**សៈ** តើមូលហេតុអ្វីដែលលោកទៅជាមួយ សុន សេន មួយថ្ងៃមុនមេដឹកនាំផ្សេងៗទៀតនោះ ដែលមកភ្នំពេញមុនពេលមេដឹកនាំផ្សេងទៀតមកទាំងអស់គ្នានោះ?

**ផៈ** ខ្ញុំមិនដឹងថា ករណីយ៉ាងម៉េចទេ ប៉ុន្តែក្នុងមន្ទីរហ្នឹង គាត់ហ្នឹង គាត់ថាចាត់តាំងឲ្យខ្ញុំទៅមើលជាក់ស្តែងទៅ។ ទៅជាមួយបង សុន សេន ទៅៗ ទៅមើលទៅ ព្រោះស្អែកហ្នឹងយើងត្រូវទៅទាំងអស់គ្នាហើយ។ ខ្ញុំក៏ទៅ តាមការចាត់តាំងឲ្យទៅ ក៏ទៅទៅ ទៅជាមួយទៅ សុន សេន ហ្នឹង។

**សៈ** ថាតើមានមនុស្សផ្សេងទៀតទេ ដែលមកភ្នំពេញដែលលោកមកជាមួយ សុន សេន នោះ ឬក៏មានតែលោកពីរនាក់ហ្នឹងទេ?

**ផៈ** មិនមែនពីរនាក់ទេ គឺថានែ៎ ចូលទៅហ្នឹងនែ៎ ជិតៗហ្នឹងគឺថា តាម៉ុក ក៏ចូលទៅដែរ វន វេត ក៏ចូលទៅដែរ សុន សេន ក៏ចូលទៅដែរ កុយ ធួន ក៏ចូលទៅដែរ ទៅថ្ងៃហ្នឹង កាលហ្នឹងថ្ងៃហ្នឹង ហើយនិង ប៉ុល ពត គាត់ចូលទៅដែរថ្ងៃហ្នឹង។

**សៈ** តើលោកអាចប្រាប់តុលាការបានទេ ថាលោកបានឃើញអ្វីខ្លះនៅពេលដែលលោកមកភ្នំពេញ ហើយលោកបានឃើញមក កាលណាលោកមកដល់ទីក្រុងនៅថ្ងៃទី១៩ មេសា ឆ្នាំ១៩៧៩ នោះ លោកបានឃើញអ្វីខ្លះ?

[១៣:៥៥:១១]

**ផៈ** ថ្ងៃ១៩ ហ្នឹងគឺថា ខ្ញុំចូលតាមផ្លូវលេខ៤ គឺថាត្រង់ថ្នល់ទទឹងហ្នឹង តាមថ្នល់ទទឹងហ្នឹងចូលទៅផ្លូវលេខ៤ មកតាមផ្លូវហ្នឹង មកហ្នឹងនែ៎ឃើញពោធិ៍ចិនតុងហ្នឹងមុនគេហ្នឹង ឃើញកប៉ាល់ហោះខ្លះអីខ្លះ។ ហើយចូលទៅតាម ចូលទៅក្នុងភ្នំពេញហ្នឹង ចូលមកៗដល់ស្តាត មកដល់ស្តាតហ្នឹងហើយ ចេញពីស្តាតហ្នឹងគឺទៅៗវាំង ចេញពីវាំងហ្នឹង ទៅស្ពានមុនីវង្ស ហើយមកតាមផ្លូវមុនីវង្សហ្នឹង មកតាមផ្លូវនែ៎ហ្នឹងមកស្ពានជ្រោយចង្វារ។ ជ្រោយចង្វារហ្នឹង វាត្រង់ហ្នឹងវាមានស្ពានទូតបារាំងត្រង់នោះអ៊ីចឹង។ មកហ្នឹងឃើញៗប្រជាជន គឺចេញមកក្នុងទីក្រុងហ្នឹង គឺថាចេញអស់ជាមូលដ្ឋានហើយក្នុងក្រុងហ្នឹង ប៉ុន្តែនៅមានមួយៗដែរ នៅជាយៗនៅមានមួយៗ។ ប៉ុន្តែអស់ជាមូលដ្ឋាន ប៉ុន្តែឃើញពពាក់ពពូនគឺមកតាមផ្លូវលេខ៤ ដែលខ្ញុំនេះ ខ្ញុំឃើញហ្នឹងមក ប្រជាជនមកពពាក់ពពូនតាមហ្នឹងច្រើន។ ខ្ញុំឃើញអ៊ីចឹង។

ហើយឃើញតាមផ្លូវហ្នឹង ឃើញសពច្រើនដែរ សពតាមផ្លូវហ្នឹង សពមិនដឹងអ្នកណា មិនដឹងអ្នកណី ឃើញសពច្រើនតាមផ្លូវហ្នឹងតាមបន្ទាយៗហ្នឹង។ ហ្នឹងឃើញសពច្រើនដែរ ស្អុយដែរអីដែរហ្នឹងអ៊ីចឹង។ ហ្នឹងដល់មើលទីក្រុងសព្វគ្រប់ចំណុចតាមមាត់ទន្លេហើយអស់ហើយ ល្ងាចមកវិញមកៗកន្លែងវិញមក មករាយការណ៍។ សុន សេន គាត់រាយការណ៍ គាត់ថា ជាមូលដ្ឋានហ្នឹង គឺថាកម្លាំងយើងគ្រប់គ្រងអស់ហើយៗ គឺថា ដូចជា មិនមានបញ្ហាអីទេ អាចៗចូលទៅបានហើយ។ ដល់ហ្នឹង គាត់ថា អ៊ីចឹងយើងទៅថ្ងៃ២០ហ្នឹង បណ្តោយទៅអ៊ីចុះ រៀបចំៗទៅទាំងអស់គ្នា មួយមន្ទីរហ្នឹងទៅច្រើនគ្នាដែរ។ ហើយតាមមុខសញ្ញាគេចូលដល់នេះ ដល់ចូលភ្នំពេញនេះ ជុំគ្នានៅវ៉ារទេះភ្លើង នៅស្តុបនៅនឹងវ៉ារទេះភ្លើងហ្នឹងឯង។

[១៣:៥៨:០៩]

**ស៖** ពេលដែលលោកនិយាយថា នៅពេលឃើញលោក -- លោកថា ឃើញសពជាច្រើន ដែលនៅតាមផ្លូវ តើនៅតាមផ្លូវជាតិលេខ៤ ឬក៏នៅកន្លែងផ្សេងៗទៀត ដែលលោកបានឃើញសព សាកសពដែលមនុស្សស្លាប់នោះ?

**ឆ៖** ខ្ញុំឃើញ ចាប់ពីខ្ញុំចូលទៅផ្លូវលេខ៤ ហ្នឹង គឺថាត្រង់បែកចានហ្នឹងមានដែរ ត្រង់ផ្លូវបំបែកទៅផ្លូវលេខ៣ ហ្នឹងក៏មានដែរ។ ហើយនែ៎ តាមផ្លូវចូលទៅផ្លូវពោធិ៍ចិនតុងហ្នឹងក៏ឃើញដែរ ឃើញដែរត្រង់ហ្នឹងឃើញដែរ ហើយដល់នៅស្តាតហ្នឹងក៏ឃើញ តិចទេ នៅស្តាតតិចទេ ប៉ុន្តែឃើញដែរ។ ដល់សួរគាត់ទៅ គាត់នែ៎ សុន សេន គាត់ខទ្មេសនាមកន្លែងៗណា ដែលវារឹងៗហ្នឹង យើងត្រូវដាក់ខ្លះហ្នឹងឯង។ កន្លែងណាដែលរឹងៗ នៅតែតបតយើងចុងក្រោយ យើងមានបង្ហើយៗខ្លះ គាត់មានមតិអ៊ីចឹងអ្នានរណាតដៃ គឺត្រូវពន្លះវាខ្លះហ្នឹងឯង។ ហើយពេលហ្នឹង គឺថាកងទ័ពយើងពេញៗ ឡើងទីក្រុងភ្នំពេញគ្រប់មុខសញ្ញាទាំងអស់ គឺថា គឺកាន់កាប់ទាំងស្រុងតែម្តង។ ថ្ងៃ១៩ ថ្ងៃ២០ ហ្នឹង យើងទៅឃើញកងទ័ពយើងនៅគ្រប់ចំណុចៗដែលទីបញ្ជាការត្រូវទៅមើលហ្នឹង គឺនៅទាំងអស់ ឈរជើងបានទាំងអស់តែម្តង។

[១៣:៥៩:៥៧]

**ស៖** សាកសពដែលលោកបានឃើញនៅទីតាំង ទីកន្លែងទាំងអស់នោះ តើជាជនស៊ីវិល ឬក៏មានទាហាន ឬក៏មានទាំងទាហាន មានទាំងស៊ីវិល?

**ឆ៖** ខ្ញុំឃើញភាគច្រើនគឺថាឃើញម្លូកតែម្តង ម្លូកដែកណា។ ឃើញម្លូកដែកទាហានភាគច្រើនទាហាន។

**សះ** នៅថ្ងៃបន្ទាប់ តើមេដឹកនាំណាខ្លះដែលមកភ្នំពេញនៅថ្ងៃទី២០នោះ? ថាតើនៅវ៉ារទេះភ្លើងហ្នឹងលោកបានជួយមេដឹកនាំអ្នកណាខ្លះនៅថ្ងៃទី២០ ដែលលោកមកដល់ភ្នំពេញនោះ?

**ឆះ** ដូចខ្ញុំបានរៀបរាប់អម្បាញ់មិញហ្នឹងគឺថា មេបញ្ជាការសមរភូមិមួយៗហ្នឹង គ្រប់មុខសញ្ញាហ្នឹងជុំគ្នាហ្នឹងទាំងអស់។ ទាំងៗកងពល ទាំងវរសេនាធំ ទាំងវរសេនាតូច ច្រើនៗកន្លែងហ្នឹងមានច្រើនគ្នាណាស់។

[១៤:០១:៤៧]

**សះ** តើយុទ្ធជនដែលនៅក្នុងសមរភូមិដែរ តើពួកគាត់ដែលជាយុទ្ធជនហ្នឹងមកជាមួយ ប៉ុល ពត ដែរឬទេ?

**ឆះ** មកៗទាំងអស់ៗ។ អ្នកដែលពាក់ព័ន្ធនៅសមរភូមិហ្នឹងគឺមកទាំងអស់។

**សះ** អ្វីដែលខ្ញុំចង់សួរលោក ហើយខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ថាតើមេដឹកនាំដែលមកជួបលោកនៅវ៉ារទេះភ្លើងនៅថ្ងៃទី២០ ហ្នឹង គឺអ្នកណា? ហើយលោកនិយាយថាមានក្រុមមេដឹកនាំដែលមកជួបលោកនៅស្ថានីយរទេះភ្លើងនុ៎ង តើជាអ្នកណាដែរនៅថ្ងៃទី២០ ខែមេសា នោះ?

**ឆះ** កន្លែងមុខសញ្ញារទេះភ្លើងហ្នឹង គឺត្រូវមុខសញ្ញា សុន សេន របស់មជ្ឈិមទាំងអស់ហ្នឹង។ គាត់កាន់កងទ័ពមជ្ឈិមហ្នឹង គឺកងគាត់ហ្នឹងមកទាំងអស់ មកចន្លោះផ្លូវលេខ៥ ហើយផ្លូវលេខ៤ ហ្នឹងមកៗមុខសញ្ញាហ្នឹង។ អង្គាល់ហ្នឹងមានកម្មាភិបាល មានៗកម្មាភិបាលកងពលៗអីហ្នឹងមកៗដែរ។ ហើយក្នុងហ្នឹងគឺថា កុយ ធួន គាត់ទៅដល់ នៅនៅចាំនុ៎ងដែរ។ នួន ជា អត់ទាន់ឃើញទេ ពេលហ្នឹង។ ខ្ញុំអត់ទាន់ឃើញគាត់ទេ ប៉ុន្តែខ្ញុំឃើញគណៈសមរភូមិ តាមភូមិភាគហ្នឹងមកដល់មុនដូចជា កុយ ធួន ក៏មក, ង៉ែ សោ ភឹម ក៏មក, វន វ៉េត ក៏មក, ចេង អន ក៏មកដែរ ហើយ តាម៉ុក ក៏មកដែរ។ គឺថាគណៈសមរភូមិជុំវិញហ្នឹង គេមក ហើយនិងកម្មាភិបាលក្រោមៗហ្នឹងមកទាំងអស់ មក។

[១៤:០៤:២១]

**សះ** ថាតើនៅពេលណាដែល ប៉ុល ពត, នួន ជា, ខៀវ សំផន មកដល់ស្ថានីយរថភ្លើងហ្នឹង? ថាតើពួកគាត់មកដល់វ៉ារទេះភ្លើងហ្នឹងនៅថ្ងៃ២០ ខែមេសា ៧៥ហ្នឹង ឬក៏មកនៅពេលក្រោយទៀត?

**ឆះ** អ៊ំ លោកអ៊ំ នួន ជា គាត់ក្រោយបន្តិច មកថ្ងៃ២១ កាលហ្នឹង មិនចាំ។ ថ្ងៃ២០, ២១ ហ្នឹងឯង។ ហើយមកបន្តបន្ទាប់ គឺថាភាគច្រើនមកតាមផ្លូវលេខ៥ មកវិញ។ ពួកខ្ញុំចូលមកតាមផ្លូវលេខ៤។ គាត់មកតាមផ្លូវលេខ៥។ មកឆ្លងព្រែកក្តាមហ្នឹងហើយ មកតាមផ្លូវលេខ៥ មកបណ្តោយទន្លេហ្នឹង។

**សៈ** ថាតើលោកនៅចាំដែរឬទេថា តើពេលណាដែល ប៉ុល ពត និង ខៀវ សំផន មកដល់? ថាតើពួកគាត់មកជាមួយនឹងមេបញ្ជាការទាហានរួមជាមួយគ្នា ឬមួយក៏គាត់ធ្វើដំណើរផ្សេងពីមេបញ្ជាការទាហាននោះ?

**ឆះ** អង្កាល់ហ្នឹងអ៊ំ នួន ជា, អ៊ំ ខៀវ សំផន គឺថា -- បងប៉ង់ គាត់ជាអ្នកចាត់ចែង គាត់មកជាបន្តបន្ទាប់មក។

**សៈ** ថាតើៗមេដឹកនាំហ្នឹង គាត់ស្នាក់នៅកន្លែងស្ថានីយរថភ្លើងហ្នឹងអស់រយៈពេលប៉ុន្មានដែរ មុននឹងគាត់ប្តូរទៅកន្លែងផ្សេង?

[១៤:០៦:៣៥]

**ឆះ** នៅរ៉ាវទេះភ្លើងហ្នឹង នៅមិនបានមួយអាទិត្យល្អទេ តិចជាងគេនៅកន្លែងហ្នឹង បំបែកគ្នា។

**សៈ** ថាតើគេចាត់តាំងឲ្យលោកធ្វើអ្វីដែរ នៅក្នុងពេលប្រហែលជាជិតមួយអាទិត្យហ្នឹង? គឺរយៈពេលមួយអាទិត្យដែលមេដឹកនាំហ្នឹងគាត់ស្នាក់នៅរ៉ាវទេះភ្លើងហ្នឹង លោកមានតួនាទីអ្វី ឬក៏មានការងារអ្វីដែរ?

**ឆះ** នាទីរបស់ខ្ញុំពេលហ្នឹងគឺថា នៅជាមួយគាត់ហ្នឹងគឺថាយាមកាមទៅហើយ។ យាមកាម យាមកាមជុំវិញកន្លែងហ្នឹងទៅ ទាំងយប់ទាំងថ្ងៃ យាមៗ អត់ទាន់ទៅណាទេ។ យាម បញ្ហាធំគឺបញ្ហាសន្តិសុខហ្នឹង។ ផ្តោតតែរឿងសន្តិសុខជារឿងធំជាងគេ។

**សៈ** ថាតើ អៀង សារី គាត់មកដល់ទីក្រុងភ្នំពេញនៅពេលណាដែរ?

**ឆះ** អ៊ំ អៀង -- លោកអ៊ំ អៀង សារី គាត់មកដល់ទីក្រុងភ្នំពេញ គឺថាក្រោយរំដោះហ្នឹងជិតមួយអាទិត្យដែរ បានគាត់មកដល់។

**សៈ** ថាតើគាត់មកដល់ក្រោយគេ បានន័យថាមកដល់ក្រោយគេ បានន័យថាមកដល់ក្រោយពេលដែលមេដឹកនាំផ្សេងៗគេមកដល់រ៉ាទេះភ្លើង តើអ៊ីចឹងមែនទេ?

**ឆះ** បាទ គាត់មកដល់ក្រោយគេ ព្រោះគាត់មកពីបរទេស។ គាត់ជិះកប៉ាល់ហោះចុះនៅពោធិ៍ចិនតុងហ្នឹង។ ហើយមកតាមកប៉ាល់ហោះ។

[១៤:០៩:០៥]

**សៈ** តើនៅពេលដែល អៀង សារី មកដល់ទីក្រុងភ្នំពេញហ្នឹង តើលោក អៀង សារី ស្នាក់នៅរ៉ាវទេះភ្លើងជាមួយមេដឹកនាំដទៃទៀត ឬមួយក៏អត់ទេ?

**ឆ៖** កាលអង្កាល់ហ្នឹង យើងបានថយពីវ៉ារទេះភ្លើងហ្នឹង យើងមកនៅខាងលិចក្រសួងការពារ កាលហ្នឹងគេហៅថា ក្រសួងពាណិជ្ជកម្មមិនដឹង កាលជំនាន់ហ្នឹង ក្រសួងពាណិជ្ជកម្ម ដល់ក្រោយមក គេដាក់អគ្គសេនាធិការរាល់ថ្ងៃនេះៗ មកនៅកន្លែងហ្នឹងៗ។

**ស៖** តើលោកចាំដែរឬទេថា នៅពេលដែលអៀង សារី មកដល់ហ្នឹង គឺៗមកដល់នៅពេលដែល លោកនៅស្ថានីយរទេះភ្លើងហ្នឹង ឬមួយក៏នៅពេលដែលលោករើមកនៅខាងក្រសួងពាណិជ្ជកម្មហើយ តើលោកចាំដែរឬទេ?

**ឆ៖** ចន្លោះហ្នឹងខ្ញុំអត់សូវចាំទេ។ ខ្ញុំអត់ចាំទេចន្លោះហ្នឹង។ ប៉ុន្តែឃើញៗ ខ្ញុំចាំ នៅកន្លែងក្រសួង ពាណិជ្ជកម្មចាស់ហ្នឹង អាហ្នឹងទៅនឹងឃើញគាត់ ឃើញគាត់នៅជុំគ្នានៅហ្នឹង។

**ស៖** តើមេដឹកនាំហ្នឹង -- មេដឹកនាំប្រទេសហ្នឹង គាត់នៅអតីតក្រសួងពាណិជ្ជកម្មហ្នឹងអស់ រយៈពេលប្រហែលប៉ុន្មានដែរ លោកចាំទេ?

**ឆ៖** ទៅនៅកន្លែងហ្នឹងជិតកន្លះខែដែរ ពេលទៅនៅកន្លែងហ្នឹង។

**ស៖** ថាលោកអាចរៀបរាប់បានដែរឬទេ តើប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី និង មេដឹកនាំដទៃទៀតគាត់ធ្វើអ្វីដែរនៅក្នុងពេលដែលគាត់នៅវ៉ារទេះភ្លើង និងនៅពេលដែលគាត់ប្តូរទៅ ក្រសួងពាណិជ្ជកម្ម? តើលោកអាចរៀបរាប់បានទេ ថាពួកគាត់ធ្វើអ្វីដែរនៅពេលទាំងអស់នោះ?

[១៤:១២:១៣]

**ឆ៖** ខ្ញុំឃើញគាត់ធ្វើការ នៅរទេះភ្លើងក៏ដោយ នៅកន្លែងក្រសួងពាណិជ្ជកម្មចាស់ហ្នឹងក៏ដោយ ឃើញនៅពួកគាត់ធ្វើការ គាត់ជុំគ្នាគាត់ គាត់ប្រជុំគ្នាគាត់ ប្រជុំរហូត។ ថ្ងៃប្រជុំ ថ្ងៃក៏ប្រជុំ។ ហើយតាម សមរភូមិជួបជាបន្តបន្ទាប់។

**ស៖** បើតាមការបកប្រែជាភាសាអង់គ្លេស គឺគេនិយាយថា ជួបប្រជុំនៅសមរភូមិ។ តើលោក ចង់និយាយថា គេជួបប្រជុំជាមួយនឹងមេទ័ពមកពីសមរភូមិ ឬមួយក៏គឺមានមូលដ្ឋានទ័ពនៅវ៉ារទេះភ្លើង និងនៅក្រសួងពាណិជ្ជកម្មចាស់ហ្នឹង តើលោកចង់មានន័យមួយណាដែរ?

**ឆ៖** ទេ ខ្ញុំបញ្ជាក់អំមិញគឺថា ឧទាហរណ៍ថាគាត់នៅរទេះភ្លើង គឺថាមេបញ្ជាការសមរភូមិដែល ៗបានចូលភ្នំពេញហើយ ប៉ុន្តែ គេនៅតាមទិសរបស់គេ ហ្នឹងមុខងារមួយៗនេះគេមកជួបគាត់។ នៅរទេះ ភ្លើងក៏អ៊ីចឹង នៅក្រសួងពាណិជ្ជកម្មហ្នឹងក៏អ៊ីចឹង គេមកជួបដែរ។ គឺមានការទាក់ទងគ្នាឃើញទៅមកៗ បើមួយមកហើយ អាមួយទៅ មួយមក មួយទៅ។ ពេលខ្លះក៏ជុំគ្នា ពេលខ្លះពីរនាក់ក៏ធ្វើ បីនាក់ក៏ធ្វើ។

ឃើញថាការងារពេលហ្នឹងវាមមាញឹកណាស់។ រៀបរយទីក្រុងភ្នំពេញហ្នឹង ឃើញថាវាមមាញឹកមែនទែនការងារ។

**ស៖** --

[១៤:១៤:២០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ ផ្អាកបន្តិចសិន! សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវ៉ាស!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នាទាំងនៅក្នុង និងនៅសាលសវនាការ។ ខ្ញុំសូមជំទាស់ជាមួយសំណួរដែលនិយាយអំពីទីតាំង ព្រោះថាវាហាក់ដូចជាមិនត្រឹមត្រូវដែលគាត់និយាយ -- លោកសាក្សីបាននិយាយថា លោកអៀង សារី មិនមែន -- អត់មាននៅខាងវ៉ារទេះភ្លើងទេ។ ប៉ុន្តែសំណួរត្រូវបានលើកឡើងថា លោក អៀង សារី និងអ្នកដទៃទៀត នៅស្នាក់នៅទាំងស្ថានីយរថភ្លើង និងនៅកន្លែងផ្សេងទៀត។ ដូច្នេះ ចំពោះខ្ញុំ ខ្ញុំគិតថា បញ្ហាគឺថាសំណួរ គឺហាក់ដូចជាតម្រូវ ឬក៏ធ្វើឲ្យសាក្សី គាត់ឆ្លើយទាំងអស់នេះ។ ដូច្នេះ គឺថាយើងគួរតែនិយាយអំពីដែលកើតឡើងនៅស្ថានីយរថភ្លើង អ្នកណានៅកន្លែងណា? ធ្វើអីខ្លះ? ជួបអ្នកណាខ្លះ? បន្ទាប់មក ទៅសួរនៅក្រសួងពាណិជ្ជកម្ម ថាតើអ្នកណាជួបអ្នកណា? ធ្វើអ្វី? នៅឯណា? ដូច្នេះ ខ្ញុំមើលទៅឃើញថា ហាក់ដូចជាសហព្រះរាជអាជ្ញាកំពុងតែដាក់បញ្ចូល ចាប់បញ្ចូលទាំងអស់គ្នា ដើម្បីឲ្យឃើញឲ្យនៅជាមួយគ្នា។ ដូច្នេះ យើងគួរតែមានការរៀបចំពាក្យ ឬក៏ការបែងចែកពាក្យឲ្យត្រឹមត្រូវ។ ខ្ញុំគិតថា ខាងព្រះរាជអាជ្ញាគាត់ដូចជាមានជំនាញនៅក្នុងការទាញបញ្ចូលបែបនេះខ្លាំងណាស់។ សូមអរគុណ។

[១៤:១៥:៥៩]

**លោក ផេល លីសាក់៖**

ខ្ញុំមិនយល់ច្បាស់ ថាតើមេធាវីគាត់ចង់ជំទាស់ទៅលើអ្វី ឬក៏អស់នោះទេ? ពីព្រោះថា សាក្សីគាត់បាននិយាយថា គាត់បញ្ជាក់ថា អៀង សារី គាត់មកដល់នៅពេលណា។ មិនច្បាស់ថា គាត់មកដល់នៅពេលដែលនៅស្ថានីយរថភ្លើង ឬក៏នៅក្រសួងពាណិជ្ជកម្ម ពីព្រោះវាមានរយៈពេលខ្លី។ ហេតុដូច្នេះហើយ ដោយសារហេតុផលទាំងអស់នេះហើយ ទើបខ្ញុំមិនបំបែក ឬក៏ខ្ញុំមិននិយាយបំបែកគ្នានៅលើការដេញសួរសាក្សីបែបនេះ។

[១៤:១៦:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៦:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា បន្តការតាំងសំណួរ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ទាក់ទងទៅនឹងអ្វីដែលមេធាវីលោក អៀង សារី បានលើកឡើង លោកបាននិយាយថា លោកបានឃើញមេដឹកនាំធ្វើការប្រជុំជាមួយនឹងមេបញ្ជាការទាហាន។ ថាតើមេបញ្ជាការមកពីគណៈមជ្ឈិមណាខ្លះ ដែលធ្វើការប្រជុំជាមួយមេបញ្ជាការយោធា។ តើលោកឃើញមេទ័ព -- អ៊ំ សូមទោស តើលោកឃើញមេដឹកនាំណាខ្លះ ដែលជួបប្រជុំជាមួយមេទ័ពទាំងអស់នោះ?

[១៤:១៧:៣៦]

**លោក ម៉ៃខល កាណាវាស៖**

សូមឲ្យសួរផង ថានៅពេលណា? នៅកន្លែងណា? នេះជាការសំខាន់។ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅពេលដែលខ្ញុំទទួលបានចម្លើយពីសំណួររបស់ខ្ញុំហ្នឹង ខ្ញុំនឹងសួរបន្តទៀតថានៅពេលណា? នៅកន្លែងណា? ឬក៏អ្វី? ដូច្នេះ ការដែលមេធាវីគាត់មកនិយាយកាត់ខ្ញុំនេះ គឺវាអត់មានបានទទួលផលចំណេញអីនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញតំណាងសហព្រះរាជអាជ្ញា តាំងសំណួរតាមបច្ចេកទេសរបស់លោកចុះ! ចំណែកឯលោកមេធាវី ម៉ៃខល កាណាវាស ប្រសិនបើមានបញ្ហាអ្វីដែលមិនត្រឹមត្រូវនោះ គឺចាំដល់វេនលោកសឹមលោកសួរបញ្ជាក់។ ពីព្រោះលោកពូកែខាងសួរបញ្ជាក់ឡើងវិញ អំពីចំណុចខ្វះចន្លោះ ខ្វះខាតនៃចម្លើយដែលបានផ្តល់នូវសក្ខីកម្មនៅទីនេះ ដូចជាការសួរអំពីម្សិលមិញ ចំពោះអ្នកជំនាញ ដេវីដ ឆេនដ័ល័រ ដែរ។ នេះជាបច្ចេកទេសខុសគ្នា។

[១៤:១៨:៥២]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះ ខ្ញុំសូមសួរសំណួរខ្ញុំឡើងជាថ្មីម្តងទៀត ថាតើលោកឃើញអ្នកណាខ្លះ? ថាតើមេដឹកនាំណាខ្លះ ដែលជួបប្រជុំជាមួយនឹងមេបញ្ជាការកងទ័ព ទាំងនៅវ៉ារទេះភ្លើងហ្នឹង ទាំងនៅក្រសួងពាណិជ្ជកម្មចាស់ហ្នឹង តើលោកអាចប្រាប់បានទេ?

**លោក វ៉ាចាម តុន៖**

**ឆ៖** អម្បាញ់មិញ ខ្ញុំបានបញ្ជាក់ថា នៅវ៉ារទេះភ្លើងហ្នឹង គឺថាមេបញ្ជាការសមរភូមិមុខសញ្ញាមួយៗ ដូចជា មុខសញ្ញា តាម៉ុក, ដូចជាមុខសញ្ញា វន វេត, ដូចជាមុខសញ្ញា កុយ ធួន, ដូចជាមុខសញ្ញា សោ ភឹម គេមកធ្វើការជាមួយគាត់ជាបន្តបន្ទាប់ នៅវ៉ារទេះភ្លើងហ្នឹងអ៊ីចឹង។ ហើយក្នុងហ្នឹង ក៏មានមេទ័ព ដូចថាថ្នាក់កងពល អាហ្នឹង ក៏មកជួបគាត់ដែរ។ ថ្នាក់កងពលហ្នឹង។ ដល់នៅរើពីកន្លែងហ្នឹងមកនៅកន្លែងពាណិជ្ជកម្មហ្នឹង មកធ្វើការហ្នឹង ក៏កម្មាភិបាលដែលៗប្រចាំសមរភូមិនីមួយៗហ្នឹង គឺថាគេទៅហើយ គេមក ថ្ងៃខ្លះគេទៅវិញគេមួយអីហ្នឹងគេមកវិញ ក៏មកជួបគាត់ដែរ។ ហ្នឹងឃើញគាត់ធ្វើការជាប់ ដូចខ្ញុំបញ្ជាក់អ៊ីចឹងធ្វើការជាប់ កន្លែងវ៉ារទេះភ្លើងក៏ធ្វើ កន្លែងក្រសួងពាណិជ្ជកម្មគាត់ធ្វើការជាប់ ហើយពេលខ្លះហ្នឹងចាំបាច់ធ្វើយប់ក៏គាត់ធ្វើដែរ។ ធ្វើការយប់ដែរ។ ខ្ញុំឃើញអ៊ីចឹង។

**ស៖** តើ នួន ជា ចូលរួមគ្រប់ពេលឬនៅក្នុងការប្រជុំ ការពិភាក្សាគ្នានេះ?

**ឆ៖** ខ្ញុំឃើញដល់គាត់មកជុំគ្នា គឺធ្វើការជុំគ្នាទាំងអស់។ ធ្វើការជុំគ្នា។

**ស៖** តើ ខៀវ សំផន គាត់ចូលរួមប្រជុំជាទៀងទាត់ដែរឬទេ នៅក្នុងកិច្ចប្រជុំទាំងអស់នេះ?

[១៤:២១:១៥]

**ឆ៖** អ៊ំ ខៀវ សំផន ក៏នៅ និយាយរួមនៅវ៉ារទេះភ្លើងដែលមកជុំគ្នាហើយ និងកន្លែងពាណិជ្ជ-កម្មចាស់ហ្នឹងគឺថា គាត់ជុំគ្នាជាអចិន្ត្រៃយ៍ហ្នឹង គឺថា អ៊ំ ប៉ុល ពត, អ៊ំ នួន ជា, អ៊ំ ខៀវ សំផន, អ៊ំ អៀង សារី, ង៉ែ សុន សេន ដែលអចិន្ត្រៃយ៍នៅក្នុង ង៉ែ ជាអចិន្ត្រៃយ៍រាល់ថ្ងៃហ្នឹងគាត់ធ្វើ គាត់នៅជុំគ្នាតើ។ គាត់ធ្វើការជាមួយគ្នារហូត។

**ស៖** សូមអរគុណដែលលោកបានបំភ្លឺបញ្ជាក់។ ឥឡូវនេះ ខ្ញុំសូមសួរលម្អិតអំពីលោក អៀង សារី នៅដែល អៀង សារី មកដល់ភ្នំពេញ ថាតើគាត់ចូលរួមជាទៀងទាត់ដែរឬទេ នៅក្នុងកិច្ចប្រជុំទាំងអស់នោះ?

[១៤:២២:១៩]

**ឆ៖** អ៊ំ អៀង សារី ចាប់ពីគាត់មកដល់ពីក្រៅហ្នឹង គាត់នៅធ្វើការនៅហ្នឹងជាប់។ ប៉ុន្តែ ន៉ែ ដល់ អ៊ំ អៀង សារី មកដល់គឺថា បន្ទាន់មែនទែនគឺរៀបចំកន្លែងខាងក្រោយវាំងហ្នឹងទទួលភ្ញៀវ។ ហ្នឹងគឺរៀបចំទទួលភ្ញៀវនៅកន្លែងហ្នឹង ការងារបម្រើ ការងារទទួលភ្ញៀវហ្នឹងដែលវាត្រូវគិតគូរបញ្ហាសន្តិសុខ វាត្រូវគិតគូររៀបចំផ្ទះសម្បែង វាគិតគូរអ្នកផ្ទះបាយអីហ្នឹងសព្វគ្រប់ទាំងអស់។ ឃើញគាត់រៀបចំការងារមមាញឹកដែរ។

**ស៖** ក្នុងអំឡុងពេលទាំងអស់នេះ គឺអំឡុងពេលដែលមេដឹកនាំជួបគ្នានៅវ៉ារទេះភ្លើង និងនៅក្រសួងពាណិជ្ជកម្មចាស់ហ្នឹង តើពួកគាត់នៅជាមួយគ្នាធ្វើការជាមួយគ្នាទាំងយប់ ទាំងថ្ងៃ ឬមួយក៏គាត់មានកន្លែងស្នាក់នៅផ្សេងៗដែលគាត់ត្រូវទៅស្នាក់នៅ ឬក៏ទៅសម្រាកពេលយប់ដែរឬទេ?

[១៤:២៣:៣៧]

**ឆ៖** ខ្ញុំឃើញគឺថា អ៊ំ ប៉ុល ពត, អ៊ំ នួន ជា, អ៊ំ ខៀវ សំផន, អ៊ំ អៀង សារី គាត់នៅជុំគ្នាទេនៅហ្នឹង នៅជិតគ្នាទេ។ ហើយដោយឡែក មានកន្លែងដោយឡែកមានតែ សុន សេន ទេ មានកន្លែងដោយឡែក។ តាម៉ុក មានកន្លែងដោយឡែក។ វន វ៉េត មានកន្លែងដោយឡែក។ កុយ ធួន ក៏មានកន្លែងដោយឡែកទាំងអស់ គេមានកន្លែងរបស់គេ ហើយ សោ ភឹម គេមានរបស់គេ។ ហើយខាងក្នុងកន្លែងមុខសញ្ញាមួយៗហ្នឹងគេមានកម្លាំងរបស់គេ កម្លាំងកងទ័ពរបស់គេមួយៗមានទាំងអស់នៅនុ៎ង។ គេធ្វើការបន្តរបស់គេទៀត។

**ស៖** សូមអរគុណលោក។ តើបន្ទាប់ពីនៅក្រសួងពាណិជ្ជកម្មចាស់ហើយហ្នឹង តើមេដឹកនាំទាំងអស់ហ្នឹងគាត់ផ្លាស់ប្តូរកន្លែងទៅកន្លែងណាផ្សេងទៀតដែរឬទេ?

[១៤:២៤:៥២]

**ឆ៖** ដល់ចេញពីកន្លែងហ្នឹង គឺថាមានកន្លែងដោយឡែកៗ គឺកន្លែងហ្នឹងយើងហៅ ក-៣ ទៅរៀបចំនៅកន្លែង ក-៣ ហ្នឹង ដល់ទៅរៀបចំនៅកន្លែង ក-៣ ហ្នឹង ខ្ញុំអត់បានទៅទេ ខ្ញុំជាប់រៀបចំផ្ទះភ្ញៀវ។ ប៉ុន្តែពួកក្រុមដឹកនាំរបស់គាត់ គាត់នៅ ក-៣ហ្នឹង។

**ស៖** តើក្នុងពេលណាមួយ តើនៅពេលណាដែលមេដឹកនាំហ្នឹង គាត់ស្នាក់នៅ ឬក៏ជួបគ្នានៅវត្តវិហារព្រះកែវមរកតនុ៎ង តើនៅពេលណាដែរ?

**ឆ៖** អាហ្នឹងគាត់ជួបគ្នាក្នុងខែ៥។

**ស៖** តើពួកគាត់ស្នាក់នៅវិហារព្រះកែវមរកតហ្នឹងពេញ១ខែឧសភាហ្នឹង ឬមួយក៏យ៉ាងម៉េច

ដែរ?

**ឆ៖** កាលហ្នឹងទៅជួបជុំគ្នានៅវិហារព្រះកែវហ្នឹង គឺជុំគ្នាដែរ គឺថាថ្នាក់ដឹកនាំភូមិភាគមួយចំនួនមកធ្វើការនៅនុំងដែរ។ គេរៀនសូត្រនៅហ្នឹងដែរ រៀននៅហ្នឹងជិត១០ថ្ងៃដែរ។

[១៤:២៦:៤៧]

**ស៖** នៅពេលដែលមេដឹកនាំ គាត់ស្នាក់នៅវិហារព្រះកែវមរកតហ្នឹង តើលោកស្នាក់នៅទីនោះក្នុងនាមជាអ្នកការពារដែរ ឬមួយក៏យ៉ាងម៉េច?

**ឆ៖** គាត់ស្នាក់នៅនៅកន្លែងវិហារព្រះកែវហ្នឹង ខ្ញុំនៅ នៅយាមផ្ទះភ្ញៀវនៅខាងលិចហ្នឹងទេ នៅរបងជាប់គ្នាហ្នឹង កន្លែងសម្រាប់ទទួលភ្ញៀវខាងលិចហ្នឹង នៅបរិវេណវាំងហ្នឹង។

**ស៖** តើលោកធ្វើការនៅពេលថ្ងៃទេ នៅពេលដែលមេដឹកនាំហ្នឹងគាត់ស្នាក់នៅវិហារព្រះកែវមរកតហ្នឹង តើលោកធ្វើការនៅនុំងដែរទេ?

**ឆ៖** ខ្ញុំចេញចូលៗដែរ ពេលថ្ងៃខ្ញុំចេញចូលទៅដែរ ហើយហ្នឹង ខ្ញុំចូលទៅមួយភ្លែតៗ។ ជាមូលដ្ឋាន ខ្ញុំនៅខាងលិច នៅវិហារព្រះកែវហ្នឹង បរិវេណខាងលិចវាំងហ្នឹង បរិវេណសម្រាប់ទទួលភ្ញៀវហ្នឹង រៀបចំផ្ទះនៅហ្នឹង។

**ស៖** លោកបានបង្ហាញថា នៅខែឧសភា ឆ្នាំ៧៥ គឺនៅពេលដែលមេដឹកនាំនៅវិហារព្រះកែវហ្នឹង គឺជារយៈ -- គឺមានរយៈពេលមួយ គឺមានរយៈពេល១០ថ្ងៃដែលមានការប្រជុំជាមួយខាងភូមិភាគ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីការប្រជុំទាំងអស់ -- នៅវិហារព្រះកែវហ្នឹង។ ដូច្នេះ ខ្ញុំសូមសួរសំណួរលោកទាក់ទងទៅនឹងការប្រជុំនោះ។ ទីមួយ ថាតើលោកអាចជម្រាបយើងបានដែរឬទេ ថាតើមានមនុស្សប្រហែលប៉ុន្មាននាក់ជារួម ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ ដែលមានរយៈពេល១០ថ្ងៃនៅវិហារព្រះកែវនោះ គឺការប្រជុំនៅវិហារព្រះកែវ នៅខែឧសភា ឆ្នាំ៧៥នោះ?

[១៤:២៩:០៧]

**ឆ៖** ខ្ញុំមិនបានរាប់ឲ្យច្បាស់ទេ ប៉ុន្តែខ្ញុំឃើញ ហើយខ្ញុំបានជួបហ្នឹង គឺថាគ្រប់ភូមិភាគហ្នឹង គ្រប់ភូមិភាគដែលទៅជុំគ្នានៅហ្នឹងទាំងអស់។

**ស៖** តើលោកមានវត្តមាននៅក្នុងបន្ទប់ប្រជុំដែរឬទេនៅពេលនោះ?

**ឆ៖** ថ្ងៃខ្លះខ្ញុំនៅ ប៉ុន្តែថ្ងៃខ្លះអត់នៅទេ ខ្ញុំទៅកន្លែងផ្ទះទទួលភ្ញៀវហ្នឹងជាមូលដ្ឋាន។

**ស៖** តើអ្នកណាជាអ្នកដឹកនាំការប្រជុំនៅពេលដែលលោកមានវត្តមាននៅទីនោះដែរ? តើអ្នក

ណាជាអ្នកដឹកនាំការប្រជុំនោះ?

**ឆ៖** ការដឹកនាំប្រជុំនៅនុ៎ង មានតែអ៊ំ ប៉ុល ពត ហើយអ៊ំ នួន ជា នេះជាអ្នកដឹកនាំប្រជុំកន្លែងហ្នឹង។

**ស៖** ផ្អែកតាមការសង្កេតរបស់លោក ថាតើគោលបំណងនៃការប្រជុំនោះ គឺប្រជុំដើម្បីធ្វើអ្វី? ហើយមេដឹកនាំនោះគេនិយាយពីអ្វី គោលបំណងអ្វីក្នុង១០ថ្ងៃនោះ?

**ឆ៖** ខ្ញុំសង្កេតឃើញការដែលប្រជុំហ្នឹង ការប្រជុំនៅក្នុងព្រៃ ការបើកវគ្គរៀនសូត្រហ្នឹង ហើយការប្រជុំនៅកន្លែងហ្នឹង គឺថាឃើញដូចថា គឺសរុបសភាពការណ៍ គឺថាយើងបានវាយរំដោះទីក្រុងភ្នំពេញរួចរាល់អស់ហើយ។ ដូច្នេះយើងត្រូវរៀបចំទិសរបស់យើង គឺថាពេលហ្នឹង ដូចមានថា យើងធ្វើបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ គឺចប់សព្វគ្រប់អស់ហើយ។ ដូច្នេះពេលហ្នឹង គឺក្រោយពីប្រជុំហ្នឹងឃើញឯកសារ គេថាយើងទៅធ្វើបដិវត្តន៍សង្គមនិយម ហើយដើម្បីឈានទៅកុម្មុយនីស្តនិយម។ អាហ្នឹងគេចាត់ទុកជាបើកទំព័រប្រវត្តិសាស្ត្រមួយ គឺចាប់ពីពេលហ្នឹងឃើញ នែ៎ហូរហែមកប្រជុំ គឺថានិយាយពីរឿងធ្វើបដិវត្តន៍សង្គមនិយម ហើយឈានទៅកុម្មុយនីស្តនិយម។ ហើយរបៀបរបបធ្វើការងារអត់ខុសទេ គឺថាខទ្ទេសនាមសភាពការណ៍ក្នុងប្រទេស និងក្រៅប្រទេស ហើយធ្វើជីវទស្សនៈបដិវត្តន៍ ហើយនិងលើកទិសវិធានការអនុវត្តតទៅទៀត លើមាគ៌ាសំខាន់ៗដែលៗត្រូវតែអនុវត្តតទៅទៀត។

[១៤:៣២:៤៣]

**ស៖** នៅពេលដែលលោកនិយាយថា ការប្រជុំនោះពិភាក្សាអំពីបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យបានសម្រេចហើយ ហើយគេតទៅបដិវត្តន៍សង្គមនិយម។ តើលោកនៅចាំទេ តើគេលើកពិភាក្សាពីបញ្ហាអ្វីខ្លះ? ថាតើគេត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យឈានទៅដល់បដិវត្តន៍សង្គមនិយមនោះ?

**ឆ៖** ខ្ញុំមិនចាំឯកសារអស់ទេ។ ប៉ុន្តែទិសដៅដូចខ្ញុំបានលើកឡើងអ៊ីចឹង ឃើញឯកសារជាច្រើនណាស់សម្រាប់កសាងសង្គមនិយមហ្នឹង គឺថាការពារប្រទេសក៏នៅក្នុងនុ៎ងដែរ កសាងសង្គមនិយមក៏នៅក្នុងនុ៎ងដែរ កសាងសហករណ៍ជឿនលឿនអីហ្នឹង នៅក្នុងនុ៎ងទាំងអស់។ សហករណ៍ជឿនលឿនអីហ្នឹង។ ខ្ញុំមិនចាំគោលឯកសារល្អិតទេ ប៉ុន្តែខ្ញុំបានមើល ហើយខ្ញុំបានឃើញឯកសារហ្នឹង វាៗមានលំនាំអ៊ីចឹង។

**ស៖** លោកបានឆ្លើយថា ប៉ុល ពត, នួន ជា ជាអ្នកដឹកនាំការប្រជុំទាំងនោះ។ តើលោកអាចជម្រាបតុលាការបានទេ ថាតើ អៀង សារី និង ខៀវ សំផន បានវត្តមាននៅក្នុងការប្រជុំទាំងនេះទេ?

[១៤:៣៤:២៩]

**ធ៖** គាត់មានវត្តមានប្រជុំនៅនុ៎ងដែរ មាន ទាំងពីរនាក់ហ្នឹងមាននៅ។

**ស៖** ខ្ញុំចង់សួរលោកថាតើអំពីប្រធានបទមួយចំនួន ឬកម្មវត្ថុមួយចំនួន តើលោកបានឮការពិភាក្សាដែលគេលើកឡើងនៅក្នុងអង្គប្រជុំដែរឬទេ? លោកបានឆ្លើយថា នៅព្រឹកថ្ងៃនេះថា "ការប្រជុំដែលលោកបានវត្តមាននៅប-៥ គឺការធ្វើសេចក្ដីសម្រេចដើម្បីជម្លៀសទីក្រុងភ្នំពេញ ជាបណ្ដោះអាសន្ន គឺដើម្បីជម្លៀសមួយអាទិត្យ"។ ថាតើមានការពិភាក្សាអ្វីទេនៅក្នុងខែឧសភា ឆ្នាំ១៩៧៥ ថាតើការជម្លៀសប្រជាជនចេញពីភ្នំពេញនោះ គឺត្រូវតែជម្លៀសជាអចិន្ត្រៃយ៍ ឬយ៉ាងណានោះ តើគេបានពិភាក្សាដែរឬទេ?

**ធ៖** ពេលដែលខ្ញុំថា ពេលដែលខ្ញុំនៅៗឃាមហ្នឹងដូចអត់ឮដែរ អត់ឮទេ រឿងបញ្ហាជម្លៀសប្រជាជន ដូចអត់ឮពិភាក្សារឿងហ្នឹងទេ។ អត់មានទេ។

**ស៖** នៅពេលណាមួយ តើលោកបានដឹងថា តើសេចក្ដីសម្រេចដែលគេបានធ្វើការជម្លៀសភ្នំពេញ -- ប្រជាជនចេញពីភ្នំពេញនោះ គេត្រូវជម្លៀសរហូត ហើយមិនមែនថាជាការជម្លៀសបណ្ដោះអាសន្នទេ? តើលោកធ្លាប់បានដឹង ឬក៏ឮការសម្រេចបែបនេះដែរឬទេ?

[១៤:៣៦:៤០]

**ធ៖** វគ្គ ឃ្លាហ្នឹង ខ្ញុំអត់ដឹងដែរ អត់បានដឹងទេ អត់បានដឹង។

**ស៖** តើលោកនៅចាំដែរឬទេ នៅក្នុងការប្រជុំខែឧសភា ឆ្នាំ១៩៧៥ ថាតើមានការពិភាក្សាថា តើក្នុងការសម្រេចក្នុងការចាយលុយ ឬមិនចាយលុយ តើគេបាននិយាយទេ ពីបញ្ហានេះ?

**ធ៖** ខ្ញុំអត់បានដឹងទេ អត់ឮពិភាក្សាពីរឿងហ្នឹងទេ។

**ស៖** តើលោកបានឮការពិភាក្សាណាមួយអំពីថា តើត្រូវធ្វើអ្វីទាក់ទងទៅនឹងវត្តអារាម ហើយនិងព្រះសង្ឃនៅប្រទេសទាំងមូលទេ? តើជាប្រធានបទដែលគេពិភាក្សានៅក្នុងការប្រជុំខែឧសភា ឆ្នាំ១៩៧៥ ដែរឬទេ?

**ធ៖** ខ្ញុំដូចអត់ៗឮទេ និយាយពីរឿងៗហ្នឹង អត់មានតែម្ដង អត់មានឮទេ។ អត់មានអត្ថាធិប្បាយរឿងហ្នឹងទេ អត់ទេ។ ស្ងាត់ស្ងៀមតែម្ដង ដូចអត់មានអីទាំងអស់។

**ស៖** តើលោកចាំដែរឬទេ បន្ទាប់ពីការប្រជុំ១០ថ្ងៃរបស់មេដឹកនាំនៅព្រះកែវនោះ? តើមានការប្រជុំធំដែលគេធ្វើឡើងក្រោយពីការប្រជុំនោះទេ ដែលមានអ្នកចូលរួមមកពីកម្មាភិបាលទូទាំងប្រទេស

ទោះជាមកពី -- នៅជាវិទ្យាស្ថានខ្មែរៗសូវៀត ឬក៏នៅអូឡាំពិកចាស់នោះ តើលោកនៅចាំទេ?

[១៤:៣៩:០៥]

**ឆ៖** ចំណុចនេះ ខ្ញុំអត់ចាំទេ។ អត់ឃើញ ខ្ញុំអត់ចាំ។

**ស៖** តើលោកបន្តធ្វើការជាអ្នកយាមហ្នឹងអស់រយៈពេលប៉ុន្មាន សម្រាប់មេដឹកនាំទាំងនោះ បន្ទាប់ពីមានការប្រជុំនៅព្រះកែវមរកតនៅក្នុងខែឧសភា ឆ្នាំ១៩៧៥ មក លោកបន្តធ្វើការងារជាអ្នកយាមរបស់មេដឹកនាំទាំងនោះយូរតទៅទៀតទេ?

**ឆ៖** ចំពោះរូបខ្ញុំ គឺថាចាប់ពីអ៊ំ អៀង សារី គាត់មកពីក្រៅមក ហ្នឹងហើយចាប់ -- ចាប់ទទួលភ្ញៀវពីខែ៥ហ្នឹង ពីខែ៥ចាប់ពីហ្នឹង ខ្ញុំអត់បានយាមទៀតទេ។ ខ្ញុំមានតួនាទីរៀបចំតែផ្ទះសម្រាប់ទទួលភ្ញៀវទេ។ នៅខាងក្រៅ ខ្ញុំអត់បានយាមទៀតទេខ្ញុំ។

**ស៖** តើពេលណាដែលគេផ្ទេរលោកពីអ្នកយាមទៅជាបុគ្គលិកធ្វើការជាមួយលោក អៀង សារី ក្នុងការរៀបចំផ្ទះភ្ញៀវដែលនៅក្នុងក្រសួងការបរទេស? តើលោកនៅចាំទេ តើគេផ្ទេរមុខងារលោកជាអ្នកយាមទៅធ្វើការហ្នឹងនៅក្នុងឆ្នាំ៧៥ ក្នុងខែណាលោកចាំទេ?

[១៤:៤១:00]

**ឆ៖** ខ្ញុំចាំគឺចាប់ពីខែ៥ឡើងទៅ។ ខែ៥ មក។

**ស៖** តើលោកនៅចាំទេថា ពេលណាដែលមេដឹកនាំទាំងនោះបានប្តូរទីតាំងទៅមន្ទីរក-១ នោះ?

**ឆ៖** តាមខ្ញុំចាំ ដូចខ្ញុំបញ្ជាក់អំមិញហ្នឹងគឺថា កន្លែងៗវាច្រើនចល័ត នៅក-៣នេះហើយៗ បានក្រោយមកទៀតបានមកនៅក-១ ទន្លេបាសាក់ហ្នឹង។ អាហ្នឹងចុងឆ្នាំ១៧៥ ហើយបានទៅនៅនុ៎ងនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាក អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់សាក្សីនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ និងហើយអញ្ជើញគាត់ និងមេធាវីរបស់គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ដោយខ្លីលោក ខៀវ សំផន នឹងបានជម្រាប -- គឺថាគាត់ លោក ខៀវ សំផន គាត់ប្រាប់ខ្ញុំអម្បាញ់មិញថា គាត់ក្អកខ្លាំងមែនទែន ហើយគាត់មិនប៊ានក្អកនៅទីនេះ ព្រោះគាត់ខ្លាចរំខានតុលាការ។ អ៊ីចឹងប្រហែលជាចេញទៅ -- បន្ទាប់ពីពេលនេះទៅរហូតដល់ពេលចូលមកវិញ គាត់អត់បានចូលទេ គាត់ប្រហែលជា -- គាត់នៅបន្ទប់នៅខាងក្រោមដើម្បីបន្តស្តាប់សវនាការ។ គាត់មិនប៊ាននៅទីនេះ ដោយសារខ្លាចក្អកទៅរំខានដល់តុលាការ។

[១៤:៤៣:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត តាមការស្នើសុំនេះ ហើយអនុរក្សមន្ទីរឃុំឃាំងនាំលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំ ដែលមានឧបករណ៍សោតទស្សន៍រៀបចំទុកសម្រាប់គាត់ ដើម្បីគាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិការទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបទៅមេធាវីការពារក្តីលោក ខៀវ សំផន ថាសុំឲ្យលោកផ្តល់នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក ខៀវ សំផន មកក្រឡាបញ្ជីសវនាការ។ ហើយទីពីរ គឺបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក ខៀវ សំផន អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ដែលរៀបចំនូវឧបករណ៍សោត-ទស្សន៍សម្រាប់គាត់នៅក្រោមសាលសវនាការនេះផងដែរ។

បាទ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិការជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំចង់ជម្រាបលោកថា ខ្ញុំសូមបញ្ចប់សំណួរទាក់ទងទៅនឹងការស្នាក់នៅ ឬក៏ទីតាំងរបស់មេដឹកនាំទាំងអស់នេះហើយ ហើយក៏ខ្ញុំបានបញ្ចប់ការសួរលោកអំពីព័ត៌មានលម្អិតនៃការស្នាក់នៅនេះ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីរយៈពេលដែលលោកនៅក្រសួងការបរទេសវិញម្តង។ ជាដំបូងនេះ ខ្ញុំចង់សួរលោក ព្រោះលោកបានបញ្ជាក់ថា លោកបានធ្វើការរៀបចំនៅ ខែឧសភា ឆ្នាំ៧៥។ ដូច្នេះ ខ្ញុំចង់សួរលោកថាតើក្រសួងការបរទេសហ្នឹងចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ នៅក្នុងខែឆ្នាំណាដែរ?

**លោក រ៉ចាម តុន៖**

**ឆ៖** ក្រសួងការបរទេសហ្នឹង ដូចខ្ញុំបានបញ្ជាប់អម្បាញ់មិញបណ្តើរៗគឺថា ចាប់ពីខែ៥ ចាប់ពីលោកអ៊ំ អៀង សារី គាត់មកពីបរទេសមក គឺថា ភារកិច្ចទទួលភ្ញៀវហ្នឹង គឺមានជាអចិន្ត្រៃយ៍អ៊ីចឹង។ ចាប់ពីខែ៥ហ្នឹងរហូត ធ្វើទទួលភ្ញៀវរហូត ស្ទើរតែថារាល់អាទិត្យ ទទួលភ្ញៀវ។ ដល់អ៊ីចឹង កាលហ្នឹងមិនទាន់ប្រកាសទេ ប៉ុន្តែខ្ញុំ ដូចខ្ញុំបានបញ្ជាក់អំមិញ គឺខ្ញុំមានភារកិច្ចទទួលខុសត្រូវ គឺកន្លែងទទួលភ្ញៀវដូចជារៀបចំផ្ទះសម្រាប់ភ្ញៀវ រៀបចំផ្ទះបាយសម្រាប់ភ្ញៀវអ៊ីចឹង។ គឺគេមានភារកិច្ច ខ្ញុំជម្រៅការងាររបស់ខ្ញុំគឺ តាំងពីខែ៥ ហ្នឹងមក។

ដល់ចុងខែ ចុង៧៥ ដើម៧៦ ហ្នឹងបានរៀបចំជាមន្ទីរ១ប-១ ហ្នឹង។

[១៥:០៤:៣៨]

**ស៖** លោកបាននិយាយយោងទៅដល់ប-១ អ៊ីចឹងតើ ប-១ ហ្នឹងគឺជាឈ្មោះ ជាលេខកូដ ឬក៏ឈ្មោះកូដហ្នឹង សម្រាប់ក្រសួងការបរទេសនោះ តើមែនទេ?

**ឆ៖** បាទ គឺថាគេតាំងឈ្មោះថា ប-១ អ៊ីចឹង គឺសម្រាប់មន្ទីរ សម្រាប់ទទួលភ្ញៀវ ខាងកិច្ចការងារបរទេសហ្នឹង។

**ស៖** តើលោកអាចជម្រាបបានដែរឬទេ ថាលោកមានតួនាទីអ្វីដែរ នៅក្នុងក្រសួងការបរទេសនុ៎ង?

**ឆ៖** ខ្ញុំជាប្រធានមន្ទីរប-១ ហ្នឹង គឺទទួលខាងរដ្ឋបាល។ រដ្ឋបាលចាត់ចែងការងារជាអចិន្ត្រៃយ៍ ហ្នឹង គឺគេមានភារកិច្ចអ៊ីចឹង។

**ស៖** តើលោកអាចជម្រាបឲ្យលម្អិតបានបន្តិចដែរឬទេ? អំពីផ្នែកនៃការទទួលខុសត្រូវ បានន័យថា តើលោកទទួលខុសត្រូវផ្នែកអីខ្លះដែរ នៅក្នុងក្រសួងការបរទេសនោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបហើយ គឺនៅនឹងក្រសួងការបរទេសហ្នឹង ខ្ញុំជាប្រធានមន្ទីរប-១ ហ្នឹង។ ប-១ នោះ គឺខ្ញុំគ្រប់គ្រងកម្លាំងនៅទីក្រុងភ្នំពេញ។ កម្លាំងដែលសម្រាប់ទទួលភ្ញៀវនោះ គឺខ្ញុំគ្រប់គ្រងទាំងនយោបាយ ទាំងសតិអារម្មណ៍ ទាំងចាត់តាំងហ្នឹង គឺខ្ញុំគ្រប់គ្រងកម្លាំងហ្នឹង។ ហើយតាមខេត្ត ក៏ខ្ញុំគ្រប់គ្រងដែរ ទៅខេត្ត ដូចជានៅខេត្តព្រះសីហនុ ដូចជានៅសៀមរាប ដូចជានៅសិរីសោភ័ណ ហើយនៅខេត្តបាត់ដំបងហ្នឹង ហើយនៅខេត្តពោធិ៍សាត់ ហើយនៅខេត្តកំពង់ឆ្នាំង នៅខេត្តកំពង់ចាម គឺថាមានសាខា តាមខេត្តទៀត សម្រាប់មន្ទីរទទួលភ្ញៀវហ្នឹង គឺកន្លែងទទួលភ្ញៀវ។ និយាយរួម កន្លែងដែលផ្ទះទទួលភ្ញៀវ។ គេមានពួកខ្ញុំគ្រប់គ្រងទាំងអស់។

[១៥:០៧:២០]

**ស៖** ក្នុងពេលដែលលោកបំពេញការងារជាប្រធានរដ្ឋបាលនុ៎ង តើអ្នកណាជាមេដឹកនាំរបស់លោក? បានន័យថា តើអ្នកណាជាអ្នកដែលលោកត្រូវរាយការណ៍ជូនទៅគេ?

**ឆ៖** មេដឹកនាំ គឺថា អ៊ំ អៀង សារី គាត់ទទួលខុសត្រូវរួមទាំងអស់។

**ស៖** តើគាត់ជាមន្ត្រីដែលមានតួនាទីខ្ពស់ជាងគេបំផុតនៅក្រសួងការបរទេស តើមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ អំពីកម្មាភិបាលដទៃទៀត ដែលមានការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ឬក៏ជាប្រធានដែលត្រូវរាយការណ៍ទៅលោក អៀង សារី បានដែរឬទេ? ថាតើមានប្រធាន ឬក៏មានអ្នកដែលទទួលខុសត្រូវចាត់ចែងណាខ្លះ ដែលធ្វើការនៅក្រសួងការបរទេស ហើយត្រូវរាយការណ៍ទៅលោក អៀង សារី តើលោកអាចជម្រាបបានដែរឬទេ?

**ឆ៖** ទទួលខុសត្រូវ គឺថាមានវាផ្នែកៗដែរ។ ឧបមាថា ខាងស្ថានទូតដែលប្រចាំនៅកម្ពុជានេះ មានលោក ទូន គាត់ទទួលខុសត្រូវ។ ហើយខាងផ្ទះបាយនេះ មីងស៊ីន គាត់អ្នកទទួលខុសត្រូវខាងផ្នែកផ្ទះបាយ។ ហើយខាងកិច្ចការនយោបាយនេះ គឺ បង ស្វរ ហុង គាត់ទទួលខុសត្រូវ។

[១៥:០៩:៥៣]

**ស៖** តើមានបុគ្គលិកប្រហែលជាប៉ុន្មាននាក់ដែរជារួម ដែលធ្វើការនៅក្រសួងការបរទេសនោះ?

**ឆ៖** នៅក្នុងក្រសួងការបរទេសបុគ្គលិក ចុង៧៨ ហ្នឹងគឺថាបានជាង ១.០០០នាក់ទេ។ ជាង ១០០០។

**ស៖** ឥឡូវនេះយើងត្រឡប់ទៅពេលដែលទើបតែបង្កើតក្រសួងការបរទេស តើលោកអាចប្រាប់បានដែរឬទេ? តើគេជ្រើសរើសបុគ្គលិកឲ្យចូលធ្វើការក្នុងក្រសួងហ្នឹង គឺជ្រើសរើសតាមរបៀបណាដែរ?

**ឆ៖** បើថ្នាក់កម្មាភិបាលគឺមានមន្ទីរ៨៧០ ជាអ្នកជ្រើសរើសបញ្ជូនមកប-១។ ឯបុគ្គលិកដែលនៅក្នុងក្រសួង ធ្វើការងារនៅក្នុងក្រសួងហ្នឹងគឺថា អ៊ំ អៀង សារី គាត់អ្នកៗណែនាំ គាត់អ្នករើស។ ឯខ្ញុំ ខ្ញុំគ្រាន់តែទៅអនុវត្តដាក់ស្តែង ខ្ញុំទៅមើល ខ្ញុំទៅនាំមកហ្នឹង ហើយដើម្បីណែនាំជាក្រុម ណែនាំជាកង ណែនាំជាអ្នកណានៅខាងផ្នែកបម្រើ អ្នកណាត្រូវនៅខាងផ្នែកផ្ទះបាយអីអ៊ីចឹង។ ខ្ញុំចាត់ចែងដាក់ស្តែងអ៊ីចឹង។

[១៥:១២:១១]

**លោក ខេល លីសាក់៖**

លោកប្រធាន ក្នុងពេលនេះ ខ្ញុំសូមផ្តល់ឯកសារដល់សាក្សីគឺ កិច្ចសម្ភាសន៍ទីមួយ របស់គាត់ជាមួយសហចៅក្រមស៊ើបអង្កេតដែលមានលេខ E3/24 ដែលនៅក្នុងសំណុំរឿងគេហៅថា D91/10។ ហើយខ្ញុំចង់សួរគាត់មួយចំនួនទាក់ទងទៅនឹងការសម្ភាសមួយនេះ។ ហើយខ្ញុំមានផ្នែកមួយចំនួន គឺថាអង់គ្លេសគឺមាន 00223582, ភាសាខ្មែរគឺ 00204070 និងភាសាបារាំងគឺមានលេខ 00503923។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារជូនទៅសាក្សី ហើយសូមបង្ហាញនៅលើអេក្រង់ផងដែរ។

សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ។

[១៥:១៣:៣៦]

**លោក អាកឡូរ វ៉ែកគែន៖**

បាទ លោកប្រធាន សូមឲ្យសហព្រះរាជអាជ្ញាអានលេខ ERN ឡើងវិញព្រោះថា ខ្ញុំ-- អ្វីដែល

ខ្ញុំមានគឺថា វាអត់ដូចគ្នាទេ លោកប្រធាន។ ERN ជាភាសាបារាំងលោកប្រធានអំមិញ។

**លោក ខេល លីសាក់៖**

បាទ ខ្ញុំសូមជម្រាបឡើងវិញ ភាសាបារាំងគឺ 00503923។

**លោក អាកទួរ វែកគែន៖**

បាទ ខ្ញុំសូមទោស វាអត់ដូចគ្នានឹងកិច្ចស្តាប់ចម្លើយរបស់សាក្សីនេះទាល់តែសោះ តើលោកសហព្រះរាជអាជ្ញាអាចឲ្យលេខ ERN ខុសពីហ្នឹងទេ ដើម្បីឲ្យខ្ញុំអាចរកឯកសារនេះ ឃើញ?

[១៥:១៤:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី -- លោកស្រីមេធាវី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ចំពោះខ្ញុំ លោកប្រធាន គឺលេខដែលឲ្យជាភាសាបារាំងហ្នឹងលេខត្រូវហើយ គឺនៅទំព័រទី៧ បើសិនជាខ្ញុំឲ្យព័ត៌មាននេះទៅគឺអាចជួយដល់មេធាវីការពារក្តីបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:១៥:១៦]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ផ្នែកដែលខ្ញុំចង់ឲ្យលោកធ្វើការពិនិត្យមើល គឺនៅក្នុងការសម្ភាសរបស់លោក ហើយខ្ញុំសូមអានដូចតទៅនេះ៖ "នៅបុរីកីឡា គឺមនុស្សមកពីគ្រប់ភូមិភាគ។ ខាងក្រសួងការបរទេសមានសិទ្ធិរើសបុគ្គលិកផ្ទាល់។ ក្រសួងផ្សេងៗទៀតក៏ទៅរើសនៅបុរីកីឡាដែរ។ មន្ទីរ៨៧០ ជាអ្នករើសមកពីភូមិភាគ។ ហើយក្រសួងការបរទេស អៀង សារី ជាអ្នកកំណត់រើសយក។ ទីមួយ វណ្ណភាព, ទីពីរ រូបសម្បត្តិ និងទីបី គឺអ្នកមកពីមូលដ្ឋានបដិវត្តន៍ចាស់"។ ហើយសំណួរបន្ទាប់ដែលខ្ញុំចង់សួរគឺថា លោកបានបញ្ជាក់ថា មន្ទីរ៨៧០ ជាអ្នករើសមកពីភូមិភាគ ហើយយកអ្នកទាំងអស់នោះមកបុរីកីឡា ហើយបន្ទាប់មកក្រសួង គឺជាអ្នកជ្រើសរើសពីក្រុមទាំងអស់នោះ។ តើលោកអាចជម្រាបបានដែរឬទេ ថាតើ

មន្ទីរ៨៧០ហ្នឹង គឺជាមន្ទីរអ្វីដែរ? តើលោកអាចជម្រាបបានទេ?

**លោក វ៉ាចាម គុន៖**

**ឆ៖** មន្ទីរ៨៧០ហ្នឹង គឺមន្ទីរតាំងលេខ ៨៧០ហ្នឹង គឺថាមាន ប៉ង់ ហ្នឹងគាត់ទទួលខុសត្រូវគឺសម្រាប់ណែនាំពីខាងលើមក ខាងលោកអ៊ំ ប៉ុល ពត មក។ គឺគាត់ មន្ទីរហ្នឹង គាត់ទាក់ទងទៅគ្រប់ភូមិភាគ ហើយដល់មកភូមិភាគត្រូវយកប៉ុន្មានៗ គឺខាងមន្ទីរ៨៧០ហ្នឹង។ ប៉ង់ ហ្នឹងជាប្រធានហ្នឹងគាត់អ្នកជ្រើសរើសមក។

[១៥:១៧:២៧]

**ស៖** តើលោកបានចូលរួមនៅក្នុងការជ្រើសរើសបុគ្គលិកមកពីបុរីកីឡាដែរឬទេ? គឺថាតើលោកបានចូលរួមក្នុងការរើសមនុស្ស ដែលត្រូវមកធ្វើការនៅក្រសួងការបរទេសដែលយកពីបុរីកីឡាហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំផ្ទាល់បានទៅចូលរួមរើសដែរ។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ ថានៅពេលណា ប្រហែលជានៅពេលណា ដែលលោកទៅបុរីកីឡា ដើម្បីរើសមនុស្សមកធ្វើការនៅក្រសួងនោះ?

**ឆ៖** អង្កាល់ណោះតាំងពីឆ្នាំ៧៧មក។ មុននៅឆ្នាំ៧៧ហ្នឹង គឺថាខាង៨៧០ អ្នករើសមក គឺប្រគល់មកឲ្យខាងខ្ញុំហ្នឹងទទួលយក ចាត់ចែងទទួលយក គ្រប់គ្រងទៅ។

**ស៖** ខ្ញុំសូមបញ្ជាក់ គឺលោកនិយាយថា លោកចាប់ផ្តើមធ្វើការងារហ្នឹងនៅឆ្នាំ៧៧ គឺនៅឆ្នាំ៧៧ហ្នឹងទេ ដែលលោកទៅរើសបុគ្គលិកដោយផ្ទាល់ពីបុរីកីឡា។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

[១៥:១៩:២៨]

**ស៖** នៅក្នុងផ្នែកដែលខ្ញុំអាននៅក្នុងកិច្ចសម្ភាសន៍របស់លោកនោះ គឺលោកបានបញ្ជាក់ថា “អៀង សារី ជាអ្នកកំណត់រើសនូវលក្ខណៈសម្បត្តិក្នុងការជ្រើសរើសបុគ្គលិក”។ តើគាត់ប្រាប់មកលោកអំពីលក្ខណៈសម្បត្តិហ្នឹង គឺប្រាប់តាមរបៀបណាដែរ?

**ឆ៖** គាត់ណែនាំមក គឺថាអាហ្នឹងជាបន្តបន្ទាប់វាមានក្នុងឯកសារ។ ក្នុងឯកសារគឺមាន មានសរសេរលាយលក្ខណ៍ជាអក្សរ ហើយគាត់ឈរមូលដ្ឋានឯកសារហ្នឹង ហើយគាត់ប្រាប់ខ្ញុំថា ឥឡូវហ្នឹងអនុវត្តតាមឯកសារនេះ ក្នុងការជ្រើសរើស។ ខ្ញុំក៏ធ្វើតាមមតិរបស់គាត់ណែនាំហ្នឹង។

**ស៖** តើលិខិតជាលាយលក្ខណ៍អក្សរហ្នឹង គឺជាលិខិតរបស់ក្រសួងការបរទេស ឬមួយក៏ជាលិខិតមកពីក្រសួង ឬក៏មកពីផ្នែកណាផ្សេង?

**ឆ៖** ឯកសារហ្នឹង គឺកំណត់ពីមន្ទីរ៨៧០មក។

**ស៖** លោកបានបញ្ជាក់នៅក្នុងសក្ខីកម្មរបស់លោក ដែលលោកផ្តល់ទៅដល់សហចៅក្រមស៊ើបអង្កេតថា លក្ខណៈសម្បត្តិទីមួយ ដែលគេតម្រូវឲ្យលោកមើលនៅពេលដែលលោកជ្រើសរើសហ្នឹង គឺទីមួយហ្នឹង គឺវណ្ណភាព បានន័យថាប្រវត្តិវណ្ណភាព។ តើគេប្រាប់លោកយ៉ាងម៉េចដែរអំពីវណ្ណភាពហ្នឹង? តើវណ្ណភាពបែបណាដែលតម្រូវក្នុងការជ្រើសរើសបុគ្គលយកមកធ្វើការនោះ?

[១៥:២១:៤៦]

**ឆ៖** វណ្ណភាពនេះ គឺបញ្ជាក់ថា វណ្ណភាពដែលចេញពីកសិករក្រីក្រ។ ក្រីក្រហ្នឹង គឺថាដែលគ្មានជំពាក់ជំពិនអ្វីទាំងអស់ អត់មាននិន្នាការអ្វីៗទាំងអស់ គឺថាគាត់នៅក្នុងស្រែហ្នឹង គាត់ប្រកបតែធ្វើស្រែធ្វើចម្ការ ដោយលំបាកលំបិន យកពួកហ្នឹង។ យកពួកហ្នឹងជាមូលដ្ឋាន។

**ស៖** តើគេមានប្រាប់បានដែរឬទេ ថាហេតុអ្វីក៏អ្នកដែលត្រូវជ្រើសរើសហ្នឹងត្រូវតែមានប្រវត្តិវណ្ណភាពជាអ្នកក្រីក្រ គឺកសិករក្រីក្រហ្នឹង តើគេមានប្រាប់លោកថាហេតុអ្វីទេ?

**ឆ៖** តាមរៀនជាបន្តបន្ទាប់មក គឺយកវណ្ណៈកសិករក្រីក្រហ្នឹង ហើយវណ្ណៈកម្មករហ្នឹង អាហ្នឹងជាស្នូលតែម្តង ជាស្នូលនៃកងកម្លាំងបដិវត្តន៍។ គេរៀនបន្តបន្ទាប់ហ្នឹង គេបញ្ជាក់អ៊ីចឹងតែម្តង មានឯកសារអ៊ីចឹងតែម្តង។

**ស៖** នៅពេលដែលលោកទៅបុរីកីឡា ដើម្បីជ្រើសរើសមនុស្សមកធ្វើការនៅក្រសួង។ តើលោកធ្វើយ៉ាងណាទើបដឹងអំពីវណ្ណភាពរបស់មនុស្សទាំងអស់នោះ? តើមនុស្សទាំងអស់នោះតម្រូវ -- គេតម្រូវឲ្យរៀបចំជាប្រវត្តិរូប ឬមួយក៏លោកធ្វើការសួរទៅលើមនុស្សទាំងអស់នោះដោយផ្ទាល់តែម្តង?

[១៥:២៣:៤៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្តាប់ការជំទាស់របស់មេធាវីការពារក្តីសិន។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំគិតថា នេះគឺជាការសន្មត ប៉ុន្តែវា -- ប៉ុន្តែហេតុអ្វីក៏គាត់មិនព្រមសួរសំណួរសាមញ្ញថា ទៅជួប

ហើយបន្ទាប់មកផ្ដល់ឱកាសតែម្ដង តើសម្រេចយ៉ាងដូចម្ដេច? ហេតុអីក៏គាត់មិនសួរសំណួរបែបនេះទៅសាក្សី? ខ្ញុំគិតថា ការសួររបស់ព្រះរាជអាជ្ញានោះដូចជាសំណួរនាំមុខ។ ប្រសិនបើគាត់ចង់នាំមុខក៏នាំមុខទៅ វាជាសំណួរនាំមុខទៅហើយ។ ប៉ុន្តែខ្ញុំគិតថា វាធ្វើអីចឹង វាធ្វើឲ្យយើងច្របល់ច្រឡូកច្រឡំទាំងអស់គ្នា។ ខ្ញុំគិតថា ការសួរហ្នឹងវាមិនដូចអ្វីជារឿងល្អ ជាអ្វីនោះទេ។ វាជាវិធីសាស្ត្រមួយក្នុងការសួរដែលមិនត្រឹមត្រូវ។

[១៥:២៤:៤៦]

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជម្រាបថាអត់មានការនាំមុខ អត់មានសំណួរនាំមុខអ្វីនោះទេ គឺសាក្សីអាចប្រាប់មកយើងបាន។ ហើយខ្ញុំគិតថា គ្មានអ្វីដែលខុសនោះទេ ដែលខ្ញុំសួរសាក្សីថា តើគាត់ឲ្យគេធ្វើប្រវត្តិរូប ឬក៏សួរដោយផ្ទាល់។ ដូច្នេះ ខ្ញុំគិតថា ការជំទាស់នេះដូចជាគ្មានមូលដ្ឋានអីសោះ។ ហើយខ្ញុំគិតថាឲ្យសាក្សីគាត់ឆ្លើយសំណួរទៅ ហើយគឺថាគ្មានការណ៍ណាមួយដែលបង្ហាញថា សំណួរហ្នឹង ឬក៏ខ្ញុំនឹងនាំមុខសាក្សីឲ្យឆ្លើយនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនមានមូលដ្ឋានសមស្រប។ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព អង្គជំនុំជម្រះត្រូវការស្ដាប់នូវចម្លើយសាក្សីតបទៅនឹងសំណួរនេះ។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកនៅចងចាំ។ ហើយបើមិនចាំទេ គឺឲ្យតំណាងសហព្រះរាជអាជ្ញាអាចរៀបចំសំណួរនេះសាជាថ្មីឡើងវិញដើម្បីឲ្យសាក្សីស្ដាប់បានជាក់ច្បាស់ ទំនងជាអាចភ្លេចហើយ។

[១៥:២៦:១៩]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី តើលោកចង់ឲ្យខ្ញុំសួរសាជាថ្មីម្ដងទៀត ឬមួយក៏លោកចង់ឆ្លើយតែម្ដង?

**លោក វ៉ាចាម តុន៖**

**ឆ៖** បានគាត់បញ្ជាក់សាជាថ្មីទៀតទៅ។

**ស៖** អ្វីដែលខ្ញុំចង់សួរគឺថានៅពេលដែលលោកទៅដល់បុរីកីឡាហ្នឹង តើលោកធ្វើយ៉ាងណាទើបដឹងអំពីវណ្ណភាពរបស់មនុស្សដែលនៅបុរីកីឡា គឺមនុស្សដែលលោកត្រូវជ្រើសរើសយកមកធ្វើការនៅ

ក្រសួងការបរទេសនោះ?

**ឆ៖** ខ្ញុំទៅកន្លែងបុរីកីឡាហ្នឹង គេមានអ្នកដែលគេកំណត់ គេហៅថាជីវប្រវត្តិសង្ខេបក្នុងបុគ្គលមួយៗ មាន។ យើងទៅទាក់ទងគេហ្នឹង។ ទៅទាក់ទងគេហ្នឹងបានឯកសារហ្នឹងហើយ បានយើងដើម្បីស្គាល់គេ យើងហៅឈ្មោះគេឲ្យគេតម្រង់ជួរមក តម្រង់ជួរ ហើយយើងមើលទៅ។ អាហ្នឹងខ្ញុំមើលៗជាក់ស្តែង ខ្ញុំមើលតាមៗគោលការណ៍ដែលបានកំណត់ហ្នឹងអត់។ មើលរូបភាព រូបសម្បត្តិគេ ហើយមើល មើលទៅអាចគេនៅក្នុងមន្ទីរប-១ ពីព្រោះក្នុងមន្ទីរប-១ គឺថាជ្រើសរើសកម្លាំងហ្នឹងដើម្បីកសាងកម្លាំងហ្នឹង គឺត្រៀមទៅក្រៅដែរ ទៅធ្វើជាបុគ្គលិកទៅខាងក្រៅប្រទេសនេះប្រទេសនោះ។ ដូច្នេះត្រូវជ្រើសរើសហ្មត់ចត់ដែរ។ ត្រូវរើសរូបសម្បត្តិខ្លះៗដែរ អីចឹងដែរ។ រើសកម្ពស់ដែរ មើលរើសតែមនុស្សហ្នឹងសមរម្យ អាចដំណើរការហ្នឹងកើត អាហ្នឹងយើងមើលអីចឹង។

[១៥:២៨:៣៨]

**សៈ** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមពិភាក្សាអំពីប្រធានបទថ្មីមួយទៀត។ ក្នុងពេលដែលលោកបំពេញការងារនៅក្រសួងការបរទេស តើតួនាទីមួយដែលលោកទទួលខុសត្រូវហ្នឹងគឺបញ្ជូនឯកសារ ឬក៏លិខិតពីក្រសួងការបទេសទៅបុគ្គលផ្សេងៗទៀតនៅក្នុងអង្គការ។ តើលោកបានការងារមួយគឺទទួលខុសត្រូវខាងបញ្ជូនសារ បញ្ជូនលិខិតហ្នឹង តើមែនទេ?

**ឆ៖** សំណួរនេះ ខ្ញុំដូចជាស្តាប់មិនទាន់បានច្បាស់។ សូមបញ្ជាក់ម្តងទៀត។

**សៈ** ក្នុងពេលដែលធ្វើការនៅក្រសួងការបរទេសហ្នឹង តើលោកមានតួនាទីខុសត្រូវក្នុងការបញ្ជូនឯកសារពី អៀង សារី ឬក៏បញ្ជូនទៅ អៀង សារី តើមែនដែរឬទេ?

**ឆ៖** អំមិញគាត់សួរថា ឯកសារបញ្ជូនមកលោកអ៊ំ អៀង សារី អត់។ បើមានឯកសារពីមន្ទីរផ្សេងៗ ខ្ញុំបញ្ជូនទៅឲ្យគាត់ហើយ។ ហើយក្នុងនុំងខ្ញុំទៅជួបគាត់ផ្ទាល់ ពិគ្រោះពិភាក្សាគាត់។ ឧបមាថាក្នុងការជ្រើសរើសកម្លាំងហ្នឹង វាបានចំនួនប៉ុណ្ណេះ ហើយភូមិភាគនេះបានប៉ុណ្ណេះ ហើយភូមិភាគនោះបានប៉ុណ្ណោះ រាយការណ៍ឲ្យគាត់ទៅ។ បើគាត់*អូខេ*ហើយ ក៏ដំណើរការតាមហ្នឹងអីចឹងទៅ។

**សៈ** ប្រហែលជាបញ្ហាដោយសារខ្ញុំសួរទៅលោកស្តាប់មិនយល់ ឬក៏ប្រហែលជាបកប្រែមិនច្បាស់ឲ្យលោក។ ខ្ញុំសួរលោកគឺថា សួរថា តើលោកទទួលខុសត្រូវក្នុងការប្រគល់សំបុត្រ ឬក៏ឯកសារផ្សេងទៀត ដែលលោក អៀង សារី រៀបចំ ហើយយកទៅឲ្យអ្នកផ្សេងទៀតដែរឬទេ? ចង់សួរបែបនេះ។

**ឆ៖** ចំណុចៗនេះគឺថា ឯកសារណាដែលគាត់ឲ្យខ្ញុំបញ្ជូនទៅខាងមន្ទីរ៨៧០ ខ្ញុំបញ្ជូនតាមហ្នឹង

ទៅ ឬយកទៅប្រធានមន្ទីរ៨៧០ ក៏យកឲ្យទៅ ឈ្មោះ បងប៉ង់ ហ្នឹង អ៊ីចឹងទៅ ឲ្យគាត់ហ្នឹងទៅ។

[១៥:៣១:៣៣]

**ស៖** តើមានអ្នកណាផ្សេងទៀត ឬក៏មន្ទីរណាទៀតដែលៗលោកយកឯកសារ ឬក៏សំបុត្រពីលោក អៀង សារី ក្រៅពីមន្ទីរ៨៧០ លោកធ្លាប់យកទៅឲ្យមន្ទីរ ឬក៏បុគ្គលណាផ្សេងទៀតទេ?

**ឆ៖** យកសារពីអ៊ំ អៀង សារី ទៅអ្នកដទៃទៀតក្រៅពី ប៉ុល ពត ខ្ញុំឃើញថាមានដែរ តែវារង្វើលទេ រង្វើល ដូចថា -- បើថាទៅតាមៗមូលដ្ឋានមែនទែនទៅត្រូវឆ្លង៨៧០ ទាំងអស់ ហ្នឹងបើថាស្អីដែលថាស្អីដែលពាក់ព័ន្ធទៅខាងមូលដ្ឋាន ឆ្លងតាម៨៧០ បាន៨៧០ជម្រាបទៅតាមភូមិភាគ អាហ្នឹងអ៊ីចឹងបាទ។ យើងអត់មានទៅផ្ទាល់ទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ទាក់ទងទៅនឹងក្រុមមនុស្សផ្សេងៗ តើលោកបានបញ្ជូនឯកសារពី អៀង សារី ទៅ ប៉ុល ពត ដែរឬទេ?

**ឆ៖** ចំណុចនេះ បើថាបើទៅជា -- បើគាត់ចាត់ចែងថា ខ្ញុំឲ្យយកឯកសារនេះទៅឲ្យ ប៉ុល ពត ខ្ញុំយកឲ្យបានដែរ។ ប៉ុន្តែគាត់នៅជាមួយគ្នាហ្នឹង គឺមកនៅទីក្រុងភ្នំពេញមិនសូវនេះទេ គឺថា ជាមូលដ្ឋានគឺខ្លួនគាត់ គាត់នៅជុំគ្នា។ តែល្ងាចជុំគ្នាៗហើយ។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតចង់ឲ្យសាក្សីពិនិត្យមើលផ្នែកមួយនៃការសម្ភាស ហើយជាមួយសហចៅក្រមស៊ើបអង្កេត ហើយនិងសួរសំណួរមួយចំនួនទៅលោកសាក្សីនេះជាឯកសារ E3/24 នៅក្នុងបទសម្ភាសន៍ដដែលដែលខ្ញុំបានជូនទៅលោកសាក្សីរួចហើយ។ ផ្នែកដែលខ្ញុំចង់យោងទៅរកនោះគឺនៅខ្មែរ ERN 00204071, អង់គ្លេស ERN 00223583, បារាំង ERN 00503923 រហូតទៅដល់ 503924។ ហើយខ្ញុំសូមអនុញ្ញាតតុលាការ ដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ផងដែរបាទ។

[១៥:៣៤:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅក្នុងផ្នែកមួយនៃបទសម្ភាសន៍របស់លោកដែលខ្ញុំចង់សួរលោកនោះ លោកសាក្សីដែលមានខ្លឹមសារដូចខាងក្រោមនេះ៖ “ពាក្យនីរសារនៅក្នុងក្រសួងការបរទេស គឺការងារដែលចង់

បញ្ជូនឯកសារទៅឲ្យ ប៉ុល ពត និងក្រសួងផ្សេងៗ គឺខ្ញុំជាអ្នកទទួលខុសត្រូវយកទៅមេក្រសួងធំៗ មាន ទាំង ប៉ុល ពត និង សុន សេន។ ពេលខ្លះខ្ញុំចាំទទួលចម្លើយមកវិញ ជាសំបុត្រ ឬផ្ទាល់មាត់"។ ចប់សេចក្ដីដកស្រង់។ ខ្ញុំយល់ថាអ្វីដែលលោកទើបតែបានជម្រាបខ្ញុំហ្នឹង គឺថា ប៉ុល ពត និង អៀង សារី ធ្វើការជាមួយគ្នា ប៉ុន្តែនៅពេលដែលគេសុំឲ្យលោកបញ្ជូនឯកសារ ឬក៏សំបុត្រពី អៀង សារី ទៅ ប៉ុល ពត តើលោកត្រូវទៅកន្លែងណា ដើម្បីយកសំបុត្រទៅឲ្យ ប៉ុល ពត នោះ?

[១៥:៣៦:១៤]

**លោក វ៉ាចាម តុន៖**

**ឆ៖** ចំណុចនេះដូចខ្ញុំបានបញ្ជាក់អំមិញដែរ យើងថា បើមានសារ ឬមួយមានឯកសារអីពីក្រសួង បើថាលោកអ៊ំ អៀង សារី គាត់ឲ្យខ្ញុំយកទៅឲ្យអ៊ំ ប៉ុល ពត ខ្ញុំយកទៅឲ្យគាត់។ បើគាត់ឲ្យយកទៅឲ្យអ៊ំ សុន សេន ក៏ខ្ញុំយកទៅដែរ។ បើយកទៅឲ្យ វន វ៉េត គឺខ្ញុំយកទៅដែរ។ ហើយយកមកឲ្យអ៊ំ ខៀវ សំផន ក៏ខ្ញុំក៏យកទៅដែរ។ ក្នុងភ្នំពេញ ច្រើនមានអ៊ីចឹងដែរ។

**ស៖** តើរូបលោកផ្ទាល់ធ្លាប់បានយកសំបុត្រទៅឲ្យ ប៉ុល ពត ដែរឬទេ? ទៅឲ្យលោក សុន សេន ទេ? ឬក៏យកសំបុត្រ ឬក៏ឯកសារទៅឲ្យអ្នកជំនួយការ ឬក៏អ្នកធ្វើការឲ្យពួកគាត់ទេ?

**ឆ៖** ចំណុចហ្នឹង តាមការណែនាំរបស់អ៊ំ អៀង សារី បើថាឲ្យជំនួយការគាត់ សឹមឲ្យជំនួយការ បើគាត់ប្រាប់ថា សំបុត្រហ្នឹងយកទៅឲ្យគាត់ផ្ទាល់ យកទៅឲ្យគាត់ផ្ទាល់ អ៊ីចឹង។

**ស៖** តើ សុន សេន នៅកន្លែងណា ដែលលោកតែងតែយកសំបុត្រទៅឲ្យ សុន សេន នោះ? បើត្រូវយកសំបុត្រទៅឲ្យ តើយកទៅឲ្យគាត់នៅកន្លែងណា? តើលោកអាចជម្រាបតុលាការបានទេ?

**ឆ៖** សុន សេន គាត់អចិន្ត្រៃយ៍គាត់នៅនឹងក្រសួងការពារជាតិរបស់គាត់។ ក្រសួងការបរទេស ហើយក្រសួងការពារជាតិជាប់គ្នាទេ ជិតគ្នា យកទៅឲ្យគាត់មួយភ្លែតៗហ្នឹង។

[១៥:៣៨:២៩]

**ស៖** ចំពោះ ប៉ុល ពត បើសិនជាលោកត្រូវយកសំបុត្រពីលោក អៀង សារី ទៅឲ្យ ប៉ុល ពត ផ្ទាល់ តើលោកទៅកន្លែងណា ដើម្បី -- ទៅមន្ទីររបស់គាត់ ឬក៏ -- ទៅមន្ទីរនោះនៅកន្លែងណា?

**ឆ៖** មន្ទីរហ្នឹងគឺថា បើអ៊ំ អៀង សារី ប្រាប់ថា ឥឡូវគាត់នៅនឹង ក-៣ ខ្ញុំទៅមន្ទីរ ក-៣ ហ្នឹង។ បើគាត់បញ្ជាក់ថា ឥឡូវគាត់ទៅ ក-១ ក៏ទៅកន្លែង ក-១។ បើគាត់បញ្ជាក់ថា ទៅកន្លែងព្រះវិហារព្រះកែវ ក៏ទៅវិហារព្រះកែវ។ តាមកន្លែងដែលគាត់ទៅហ្នឹង គឺៗគាត់តម្រង់កន្លែងណា ទៅកន្លែងហ្នឹង។

**ស៖** សូមអរគុណ។ នៅទំព័រដដែលនេះដែរ នៅក្នុងបទសម្ភាសន៍របស់សហថៅក្រមស៊ើបអង្កេតនោះ លោកបានផ្តល់ចម្លើយដូចខាងក្រោមនេះ៖ "សំណួរសួរថា តើលោកនៅចាំថាយកសំបុត្រពី អៀង សារី, ខៀវ សំផន ទេ? លោកឆ្លើយថា មានច្រើនដែលរៀបចំសម្រាប់រៀបចំភ្ញៀវមុនចុះទៅទស្សនកិច្ចភូមិភាគ"។ ខ្ញុំចង់សំណួរដដែលចំពោះ ខៀវ សំផន ថាតើលោកធ្លាប់យកទៅសំបុត្រពីលោក អៀង សារី ទៅឲ្យលោក ខៀវ សំផន ទេ? បើលោកត្រូវយកទៅឲ្យ ត្រូវយកទៅឲ្យកន្លែងគាត់នៅកន្លែងណា? តើមន្ទីររបស់គាត់នៅកន្លែណា?

**ឆ៖** ខ្ញុំធ្លាប់យកសំបុត្រទៅឲ្យអ៊ំ ខៀវ សំផន មន្ទីររបស់គាត់ គឺនៅមន្ទីរ ក-៣ ហ្នឹង។ ជាមូលដ្ឋាន ក៏ច្រើននៅកន្លែង ក-៣ ហ្នឹង គាត់។

**ស៖** តើលោកបានយកសំបុត្រទៅឲ្យលោក ខៀវ សំផន នៅមន្ទីរ៨៧០ ទេ?

**ឆ៖** មន្ទីរ៨៧០ ហ្នឹង គឺកន្លែង នែ៎ ពេលខ្លះគាត់នៅ ក-៣ ហ្នឹង ក៏មន្ទីរ៨៧០។ ពេលខ្លះ គាត់នៅ ក-១ ហ្នឹង ក៏មន្ទីរ៨៧០ ហ្នឹងដែរ។ ខ្ញុំច្រើនតែយកទៅឲ្យគាត់តែពីរកន្លែងហ្នឹង កន្លងមកហ្នឹង។ ក-៣ ហើយនិង ក-១ ហ្នឹង។ ហ្នឹងជាមន្ទីររបស់៨៧០ ទាំងអស់។

[១៥:៤១:៥៣]

**ស៖** នៅក្នុងចម្លើយដែលខ្ញុំទើបតែអានជូនលោកស្តាប់នូវបទសម្ភាសន៍របស់លោកនោះ លោកបានបញ្ជាក់ថា ម្តងនោះ ដែល អៀង សារី ហើយនិង ខៀវ សំផន ប្តូរលិខិតឆ្លើយឆ្លងគ្នានោះ ដើម្បីរៀបចំៗ ទស្សនកិច្ចទៅភូមិភាគនោះ តើជាឱកាសដែលលោក អៀង សារី ហើយនិងលោក ខៀវ សំផន ទៅភូមិភាគហ្នឹងឬ?

**ឆ៖** ឱកាសដែលឆ្លើយឆ្លងគ្នាអ៊ីចឹង គឺថាគ្រាន់តែថា គាត់ -- ដូចថាមានប្រតិភូៗ កាលហ្នឹង តាស៊ិន យ៉ុង គុយ មកពីប្រទេសចិនហ្នឹង គាត់ទៅ ទៅទស្សនកិច្ចនៅកំពង់ចាមផង នៅព្រៃវែងផង ដល់ហ្នឹង ទាក់ទងជាមួយគាត់ គឺថា ទាក់ទងជាមួយអ៊ំ ខៀវ សំផន ដើម្បីគាត់ជម្រាបទៅខ្ពាចខាងភូមិភាគគេ ដើម្បីខាងភូមិភាគគេចាំទទួលភ្ញៀវហ្នឹង។ អ៊ំ ខៀវ សំផន អត់បានទៅជាមួយទេ មានតែ អ៊ំ អៀង សារីទ ដែលគាត់ទៅជាមួយភ្ញៀវហ្នឹង។

[១៥:៤៣:៣១]

**ស៖** តើលោកបានធ្វើដំណើរជាមួយលោក អៀង សារី ដែរទេ នៅពេលគាត់ទៅភូមិភាគ ឬក៏ទៅខេត្ត ដែលលោកទើបនិយាយអំមិញនេះ?

**ឆ៖** ខ្ញុំទៅជាមួយដែរ។

**ស៖** ចាតើលោក អៀង សារី ទៅភូមិភាគហ្នឹង ញឹកញាប់ប៉ុន្មានដែរ តាមដែលលោកចាំ?

**ឆ៖** តាមខ្ញុំចាំ គឺថាមានប្រតិភូធំៗ ឬមួយអង្គទូតទេ បានគាត់អញ្ជើញទៅ។ រង្វើលដែលទេ មិនញឹកញាប់ទេ រង្វើល។

**ស៖** នៅពេលដែលលោកធ្វើដំណើរជាមួយលោក អៀង សារី ភូមិភាគ តើលោកអាចសង្កេតមើលលក្ខខណ្ឌរស់នៅជីវភាពរបស់ប្រជាជន ដែលនៅតាមភូមិភាគនោះដែរឬទេ?

**ឆ៖** ខ្ញុំបានសង្កេត និងធ្វើដំណើរជាមួយគាត់ ជាមួយភ្ញៀវ ខ្ញុំបានសង្កេតឃើញថា ប្រជាជនបណ្តោយផ្លូវដែលយើងត្រូវទៅហ្នឹងគឺថា ប្រជាជនយើង គេហៅថា សាច់ឈាមហ្នឹងគឺថា មិនសូវជាៗរីករាយអីប៉ុន្មានទេ ឃើញ។ ហើយធ្វើការវាហាត់ ជីកប្រឡាយផង លើកទំនប់ផង លើកភ្លឺស្រែផង ហើយកន្លែងខ្លះហូបបបរទៀត ឃើញថា វាវេទនាណាស់ដែរ។ ឃើញ ខ្ញុំឃើញដែរ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយ។ ឥឡូវនេះ នៅក្នុងផ្នែកដំបូង នៅក្នុងបទសម្ភាសន៍របស់លោក ដែលលោកបានប្រគល់សំបុត្រទៅអ្នកផ្សេងៗនោះ លោកបាននិយាយថា ជួនកាលលោករង់ចាំការចម្លើយផ្ទាល់មាត់ ឬក៏ចម្លើយលាយលក្ខណ៍អក្សរយកមកវិញ។ តើលោកនៅចាំពេលណាដែលលោកបានប្រគល់សំបុត្រពីលោក អៀង សារី ទៅបុគ្គលម្នាក់ ហើយលោកត្រូវរង់ចាំការណែនាំឬក៏ចាំយកសំបុត្រមកវិញ? តើលោកជួបអ្នកណាដែលអ្នកឆ្លើយៗទៅនឹងសំបុត្រលោក អៀង សារី ដែលចាំឲ្យលោកទទួលយកមកវិញហ្នឹង? តើអ្នកណា? តើលោកនៅចាំទេ?

[១៥:៤៦:៥២]

**ឆ៖** តាមខ្ញុំចាំហ្នឹង គឺថា បើសំបុត្រផ្ញើទៅឲ្យអ៊ំ ប៉ុល ពត។ អ៊ំ ប៉ុល ពត គាត់មើលសំបុត្រហើយគាត់ចារ គាត់ជូនមកវិញក៏មានដែរ។ អ៊ំ ខៀវ សំផន ក៏មានអីចឹងដែរ។ អ៊ំ នួន ជា ក៏មានអីចឹងដែរឃើញអីចឹង ហើយនិង សុន សេន ក៏មានអីចឹងដែរ បើបានបញ្ជូនទៅ។ ជាមូលដ្ឋានគឺថា គាត់ចារក្នុងក្រដាសហ្នឹងហើយស្រេច មិនសូវមាននាំពាក្យអីខាងក្រៅទេ។ ហ្នឹងតាមខ្ញុំសង្កេតជាក់ស្តែងកន្លងមកឃើញអីចឹង។

**ស៖** ឥឡូវនេះ ខ្ញុំនឹងទៅសួរសំណួរផ្សេងទៀត ទាក់ទងទៅនឹងមន្ទីរ៨៧០។ នៅក្នុងកំណត់ហេតុបទសម្ភាសន៍របស់លោកដែលសម្ភាសដោយសហចៅក្រមស៊ើបអង្កេតនោះ គឺថា E3/24 បើលោកមើលទៅខ្មែរទំព័រ 00204071, អង់គ្លេសគឺទំព័រ 00223584, បារាំង ERN 00503924។ ខ្ញុំសូមឲ្យ

លោកពិនិត្យមើលសំណួរ និងចម្លើយត្រង់ចំណុចមួយ។

[១៥:៤៨:៣២]

"សំណួរ តើលោកបានប្រគល់សំបុត្រដោយផ្ទាល់ខ្លួនទៅលោក ខៀវ សំផន ទេ? ចម្លើយ បាទ ខ្ញុំបានយកទៅឲ្យលោក ខៀវ សំផន ខ្ញុំទូរស័ព្ទទៅគាត់មុន ភាគច្រើនខ្ញុំជួបគាត់ផ្ទាល់។ បើមិនជួបគាត់ទេ ដាក់លើតុគាត់។ មន្ទីរ៨៧០ ស្ថិតនៅស្ថានទូតរុស្ស៊ីសព្វថ្ងៃនេះ។" នៅពេលដែលលោកហៅថា មន្ទីរ ៨៧០ ដែលនៅត្រង់ស្ថានទូតរុស្ស៊ីសព្វថ្ងៃនេះ តើនេះជាផ្នែកមួយនៃមន្ទីរ ក-១ ទេ កាលនោះ? ឬក៏មន្ទីរ ឬក៏ជាអគារផ្សេងពីហ្នឹង តើលោកអាចជម្រាបខ្ញុំបាន -- ប្រាប់ខ្ញុំបានទេ?

**ឆ៖** ដូចអំមិញខ្ញុំបានបញ្ជាក់ខ្លះហើយថា មន្ទីររបស់៨៧០ ដែល អ៊ំ ខៀវ សំផន គាត់រស់នៅនុ៎ង នៅ ក-៣ ហ្នឹងក៏មានដែរ។ ហើយនៅ ក-១ នោះក៏មានដែរ ហើយខ្ញុំធ្លាប់ទំនាក់ទំនងនឹងគាត់ មានតែកន្លែងពីរកន្លែងហ្នឹងឯង ដែលខ្ញុំធ្លាប់ទំនាក់ទំនងនឹងគាត់។ ដូចខ្ញុំបានបញ្ជាក់ក្នុងនេះហើយ ពេលខ្លះមុននឹងខ្ញុំទៅខ្ញុំតេទូរស័ព្ទទៅគាត់ បើគាត់នៅខ្ញុំនឹងទៅ បើថាគាត់មិននៅទេ ក៏ខ្ញុំយកសំបុត្រទៅដាក់នៅមន្ទីរ នៅនឹងតុគាត់ហ្នឹងទៅ។ ក៏មានដែរកន្លងមក។

**ស៖** តើមន្ទីរក-១ នោះស្ថិតនៅកន្លែងណា? តើមន្ទីរក-៣ នោះស្ថិតនៅកន្លែងណា?

**ឆ៖** ទីតាំង ក-៣ ហ្នឹង ខ្ញុំ -- នែ៎ឥឡូវហ្នឹង ខ្ញុំដូចជាមិនចាំដែរ ឥឡូវហ្នឹង វាប្លែកអស់ហើយ សាបសិបផ្លាយឆ្នាំហើយ។ អត់ចាំទេ។ ពីមុន បើថាពីមុនហ្នឹង មួយជួរហ្នឹង មួយជួរទូត ដែលរស់នៅអង្កាល់ហ្នឹងដែលយើងដាក់ស្ថានទូតឡាវ យូហ្គោស្លាវី អាល់ម៉ានី រ៉ូម៉ានី គុយបា។ ម្តុំហ្នឹង ក-៣ហ្នឹង ម្តុំហ្នឹង។ ឯមន្ទីរមួយទៀត គេហៅថានៅ ក-១ ហ្នឹងគឺមន្ទីរនៅជាប់នឹងទន្លេបាសាក់ ហ្នឹងទន្លេបាសាក់ ហ្នឹងអាហ្នឹង ក-១។

[១៥:៥១:២៤]

**ស៖** ថាតើអ្នកណាជាប្រធានមន្ទីរ៨៧០?

**ឆ៖** មុនដំបូង គឺថានែ៎ ដូចខ្ញុំបញ្ជាក់ហ្នឹង គឺថាខ្ញុំហៅ បងប៉ង់ ហ្នឹងហើយ គាត់មុនគេ។ បាត់ប៉ង់ ហ្នឹងទៅ ស្រាប់នែ៎ ខឿន។ ដល់ក្រោយបាត់ ខឿន ហ្នឹងបានអ៊ំ ខៀវ សំផន។ ឃើញបីនាក់ហ្នឹងហើយ។

**ស៖** ថាតើមានការបែងចែកការទទួលខុសត្រូវដែរឬទេ នៅមន្ទីរ៨៧០ ដែលថាមានរដ្ឋបាល មានបញ្ហានយោបាយ? តើមានការបែងចែកអ្វីដែរឬទេ?

**ឆ៖** ត្រង់ចំណុចនេះ ដែលខ្ញុំជាក់ស្តែងកន្លងមក គឺថាអ្វីដែលទាក់ទងដល់ភៀវត្រូវទស្សនកិច្ច តាមភូមិភាគ តាមកន្លែងដែលបានកំណត់ អាហ្នឹងគឺទាក់ទងមន្ទីរ ៨៧០ហ្នឹងហើយ។ ៨៧០ ដែលខ្ញុំរៀបរាប់អម្បាញ់មិញអ៊ីចឹង។

**ស៖** ខ្ញុំសូមអនុញ្ញាតអានជូនលោកស្តាប់នូវផ្នែកមួយទៀតនូវសេចក្តីដកស្រង់ នូវបទសម្ភាសន៍របស់លោក ហើយសូមឲ្យលោកពន្យល់ តើលោកចង់និយាយដូចម្តេចដែលលោកឆ្លើយក្នុងសំណួរនេះ នៅក្នុងឯកសារដដែល នៅខ្មែរ ERN 00204071, អង់គ្លេស ERN 00223584, បារាំង ERN 00503924។ ហើយចំណុចដែលខ្ញុំចង់ដកស្រង់ក្នុងចម្លើយរបស់លោកហ្នឹង គឺមានខ្លឹមសារដូចខាងក្រោមនេះ។ ដកស្រង់៖ "អ្នកកាន់មន្ទីរ៨៧០ គឺ ប៉ង់ ជាប្រធាន។ នៅពេល ប៉ង -- នៅពេលបាត់ ប៉ង់ ឌឿន មកជំនួសមួយរយៈក្រោយ។ មួយរយៈក្រោយមកទៀតមាន ខៀវ សំផន។ ប៉ង់ ទទួលខាងរដ្ឋបាលមន្ទីរ៨៧០។ ឌឿន ទទួលខាងនយោបាយ។ ដូចជា ហុង នៅ ប-១ ទទួលខាងនយោបាយ។ ខ្ញុំទទួលរដ្ឋបាលដែរ"។

សូមលោកពន្យល់ខ្ញុំ ថាតើលោកចង់និយាយដូចម្តេចអំពីការបែងចែកថា មានអ្នកទទួលខាងនយោបាយ ហើយនិងមានអ្នកទទួលខាងរដ្ឋបាលនោះ?

[១៥:៥៤:៥៤]

**ឆ៖** ខ្ញុំចង់បញ្ជាក់លើចំណុចនេះ គឺថាមួយខាងនយោបាយ។ មួយខាងផ្នែករដ្ឋបាល។ នយោបាយនេះ គឺថា គឺសំដៅ គឺគាត់ហ្នឹង គឺថាក្នុងសមាជិកក្នុង៨៧០ហ្នឹង គឺគាត់ទទួលខុសត្រូវខាងបើកវគ្គរៀនសូត្រ បំពាក់បំប៉នខាងទស្សនៈគោលជំហរ សតិអារម្មណ៍ និងចាត់តាំង គឺខាងអ្នកៗនយោបាយគិតគូរអាហ្នឹង។ ឯខាងអ្នករដ្ឋបាល គេចាត់ចែងការងាររាល់ថ្ងៃ។ រាល់ថ្ងៃ ឧបមាថាថ្ងៃនេះទៅណា ថ្ងៃនេះទៅផ្លូវណាខ្លះៗ ទៅកន្លែងណាខ្លះ ធ្វើអីខ្លះ ហ្នឹងខាងចាត់ចែងការងារជាក់ស្តែង គឺខាងរដ្ឋបាលហ្នឹង គេក្តាប់ គេចាត់ចែង ទៅភូមិភាគណាៗ។ ត្រូវមានការទាក់ទងទៅខាងភូមិភាគ គ្រប់ភូមិភាគហ្នឹង។

**ស៖** តើលោកដឹងដោយវិធីណាដែលថា ប៉ង់ ហើយនិង ឌឿន ដែលមានការទទួលខុសត្រូវខុសគ្នានៅមន្ទីរ៨៧០ហ្នឹង?

[១៥:៥៦:១៧]

**ឆ៖** បញ្ជាក់អំពីន៎ សំណួរនេះ គឺថាយើងហៅថាខាងនយោបាយហ្នឹង។ ដូចជា ឌឿន ខាងនយោបាយហ្នឹង គឺគាត់នៅទីក្រុងភ្នំពេញហ្នឹង គឺថាគាត់សមាជិកដែលនៅក្នុងមន្ទីរ៨៧០ហ្នឹង គឺគាត់មាន

កម្មវិធីអប់រំ។ អប់រំពីនយោបាយ គេហៅ ជាវគ្គៗ ប៉ុន្មាន មួយវគ្គហ្នឹងប៉ុន្មាន គ្រាន់តែមួយវគ្គហ្នឹង១០០នាក់ ឬមួយវគ្គទៀត២០០នាក់ ឬមួយវគ្គទៀត៥០នាក់ ឬមួយវគ្គទៀតតាមការចាំបាច់ អាហ្នឹងគឺខ្ញុំចង់និយាយថា កន្លងមក ឃើញៗដណើរការរបៀបអ៊ីចឹង។ ដូចជាខាងៗ នៃខាងខ្ញុំហ្នឹង មន្ទីរប-១ ក៏ដូចគ្នាដែរ។ ដូចបង សួរ ហុង គាត់ទទួលខាងផ្នែកនយោបាយអ៊ីចឹង គាត់រឿងរៀនសូត្រ រឿងអីហ្នឹងគឺទៅលើគាត់ហើយ គាត់ផ្តើមឡើង គាត់ដំណើរការអ៊ីចឹងទៅ។ ឯខាងខ្ញុំអ្នករដ្ឋបាលហ្នឹង គិតតែរៀបចំផ្ទះប្រចាំថ្ងៃអីអ៊ីចឹងទៅ ទៅសម្អាតអ៊ីចឹងទៅ រៀបចំអ្នកផ្ទះបាយយ៉ាងម៉េច អ្នកបម្រើភ្ញៀវយ៉ាងម៉េច អ្នកដែលយាមផ្ទះហ្នឹងយ៉ាងម៉េច អ្នកដែលរៀបចំផ្ទះហ្នឹងយ៉ាងម៉េច អាហ្នឹងគឺខ្ញុំឃើញតែការងារជាក់ស្តែងគឺកន្លងមកគេដំណើរការអ៊ីចឹង។

**ស៖** លោកបានប្រាប់ខ្ញុំប្រហែលជាពីរបីនាទីកន្លងទៅនេះ ថាបន្ទាប់ពី ឌឿន បាត់ខ្លួន ខៀវ សំផន បានឡើងមកទទួលខុសត្រូវជំនួស។ តើលោកនៅចាំទេ ពេលណាដែលថា ឌឿន បាត់ខ្លួននោះពេលណា? ហើយ ខៀវ សំផន មកជំនួសតំណែងរបស់ ឌឿន នោះ?

[១៥:៥៨:១០]

**ឆ៖** តាមខ្ញុំចាំក្នុង ពាក់កណ្តាល៧៨ហើយ ជាងពាក់កណ្តាលហើយមើលទៅ គឺចន្លោះហ្នឹងឯងព្រោះរយៈខ្លីដែរ។

**ស៖** តើលោកបានដឹងដោយរបៀបណាថា ឌឿន បាត់ខ្លួននោះ? ហើយដឹងថា ខៀវ សំផន ជាអ្នកមកតតំណែង? តើលោកដឹងហ្នឹង ដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំដឹងហ្នឹង របៀបគឺខ្ញុំដឹងពីអ៊ំ អៀង សារី ទេប្រាប់ខ្ញុំ។ គាត់ថា "ឥឡូវហ្នឹង ប៉ង់ គេផ្លាស់ធ្វើការផ្សេងហើយ។ ឥឡូវហ្នឹង ឌឿន គេអ្នកជំនួស"។ ដល់តែបាត់ ឌឿន ទៀតទៅ គាត់ថា "ឥឡូវនេះមានអ៊ំ ខៀវ សំផន" នៃការងារនេះ គាត់ៗប្រាប់ ដែលខ្ញុំត្រូវទៅទាក់ទងហ្នឹង គឺគាត់ប្រាប់អ៊ីចឹង។

**ស៖** តើលោកធ្លាប់និយាយជាមួយលោក ខៀវ សំផន ផ្ទាល់ទេអំពីការទទួលខុសត្រូវរបស់គាត់នៅមន្ទីរ៨៧០ នោះ?

[១៦:០០:០៤]

**ឆ៖** ខ្ញុំបានសាកសួរគាត់ដែរ បើថាដល់តួនាទីរបស់គាត់ៗទទួលខុសត្រូវ។ បាត់គេហ្នឹងហើយត្រូវទទួលទៅ គឺថាខ្ញុំឆ្ងល់អី ខ្ញុំសួរគាត់។ ខ្ញុំមានការអីទាក់ទងជាមួយគាត់ ខ្ញុំឆ្លើយឆ្លងគ្នាអ៊ីចឹងទៅ។

**ស៖** តើគាត់ប្រាប់លោកថាអ្វីខ្លះ?

**ផ៖** ខ្ញុំចាំល្អិតទាំងអស់វាមិនបានទេ ប៉ុន្តែខ្ញុំចាំចំណុចសំខាន់ៗខ្លះ គឺថាឧទាហរណ៍នៅពេលភៀវទៅទស្សនកិច្ចនៅភូមិភាគ ហ្នឹង។ ហើយមានក្រដាសស្នាមបញ្ជាក់ជូនទៅគាត់ហើយ គាត់បញ្ជាក់ថាគាត់បានបញ្ជូនសារហ្នឹងទៅប្រាប់ខាងភូមិភាគហើយ ឲ្យខាងខ្ញុំហ្នឹងដំណើរការចុះ គាត់ប្រាប់អ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះ ដល់ពេលត្រូវសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី៣០ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះ នឹងបន្តស្តាប់សក្ខីកម្មសាក្សី រ៉ចាម តុន ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាបន្ត។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០១:៤២]

លោក រ៉ចាម តុន ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះត្រូវបន្តធ្វើសវនាការនៅដើមសប្តាហ៍ក្រោយទៀត គឺចាប់ផ្តើមពីថ្ងៃចន្ទ ខែកក្កដា អ៎! ថ្ងៃចន្ទ ទី៣០ ខែកក្កដា ឆ្នាំ២០១២។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ សប្តាហ៍ក្រោយទៀត។ ហើយមេធាវីប្រឹក្សាសាក្សីដូចគ្នាដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយ នៅវេលាម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ។ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីនាក់មកកាន់បន្ទប់សវនាការនេះវិញ នៅថ្ងៃចន្ទ ទី៣០ ខែកក្កដា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយសូមបញ្ជាក់បន្ថែមថា ករណីលោក អៀង សារី នៅព្រឹកថ្ងៃចន្ទ អនុរក្សមន្ទីរឃុំឃាំងត្រូវតែនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*